ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
ក្រុមប្រឹក្សាជាតិគណនេយ្យ

# CIAS 12

# ពន្ធលើប្រាក់ចំណូល

## Income Taxes

ក្រុមប្រឹក្សាស្តង់ដាគណនេយ្យអន្តរជាតិ
International Accounting Standards Board (IASB®)

IFRS™

# អារម្ភកថា

ដោយសារនយោបាយ **"ឈ្នះ-ឈ្នះ"** របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ប្រទេសកម្ពុជាសម្រេចបាននូវឯកភាពជាតិ, បូរណភាពទឹកដី, អធិបតេយ្យ, និងសុខសន្តិភាពពេញលេញទូទាំងប្រទេស ហើយបង្កើតបានជាបុរេលក្ខណៈសម្បត្តិសម្រាប់ពង្រឹងស្ថិរភាពនយោបាយ, សណ្តាប់ធ្នាប់សង្គម និងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ដែលបានលើកកម្ពស់ជីវភាព, សុខមាលភាព និងកាត់បន្ថយភាពក្រីក្ររបស់ប្រជាជនជាបន្តបន្ទាប់។ ដើម្បីបន្ត និងពង្រឹងនូវវឌ្ឍនភាពនេះ រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី** បានដាក់ចេញនិងធ្វើបច្ចុប្បន្នកម្មជាបន្តបន្ទាប់នូវផែនការ និងយុទ្ធសាស្ត្រមួយនានា ដូចជា **"យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី១, ទី២ និង ទី៣"**, **"ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨"**, **"យុទ្ធសាស្ត្រត្រីកោណ"**, **"យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ២០១១-២០២០"** និង **"យុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម ២០១៤-២០១៨"** ព្រមទាំងធ្វើការកែទម្រង់លើគ្រប់វិស័យ ដែលក្នុងនោះ ការកែទម្រង់លើការគ្រប់គ្រងប្រព័ន្ធហិរញ្ញវត្ថុ និងប្រព័ន្ធគណនេយ្យ ទាំងក្នុងវិស័យសាធារណៈ ទាំងក្នុងវិស័យឯកជន ជាអទិភាពចម្បងមួយ។

**ច្បាប់ស្តីពីគណនេយ្យសហគ្រាស សវនកម្មគណនេយ្យសហគ្រាស និងវិជ្ជាជីវៈគណនេយ្យ** ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៧០២/០១១ ចុះថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ ២០០២ និងក្រុមប្រឹក្សាជាតិគណនេយ្យ ដែលត្រូវបានបង្កើតឡើងដោយអនុក្រឹត្យលេខ ០៣ ខែ មីនា ឆ្នាំ ២០០៣ ជាក្របខ័ណ្ឌគតិយុត្ត និងក្របខ័ណ្ឌស្ថាប័ន ក្នុងទិសដៅអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ការកែទម្រង់គណនេយ្យនិងសវនកម្មឯកជន ដើម្បីបង្កើតនូវបរិយាកាសទីផ្សារប្រកួតប្រជែងប្រកបដោយតម្លាភាព សម្រាប់ជំរុញកំណើនធុរៈកិច្ច និងវិនិយោគឆ្លងប្រទេសនៅកម្ពុជា ។ ក្រុមប្រឹក្សាជាតិគណនេយ្យ (ក.ជ.គ) ដែលជាស្ថាប័នបញ្ញត្តិករ និងនិយ័តករនៅក្នុងវិស័យគណនេយ្យនិងសវនកម្ម មានភារកិច្ចចម្បងក្នុងការដាក់ឱ្យអនុវត្តស្តង់ដាគណនេយ្យ, ស្តង់ដាសវនកម្ម និងក្របខ័ណ្ឌទស្សនទានគណនេយ្យតាមស្ថានភាពជាក់ស្តែងនៃសេដ្ឋកិច្ចកម្ពុជា ដោយអនុលោមតាមស្តង់ដាអន្តរជាតិ និងការវិវឌ្ឍជាអន្តរជាតិនៅក្នុងវិស័យនេះ ។

សៀវភៅស្តីពី **"ស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា "** ត្រូវបានបកប្រែទាំងស្រុងចេញពីស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ ដែលបានចេញផ្សាយដោយក្រុមប្រឹក្សាស្តង់ដាគណនេយ្យអន្តរជាតិ (International Accounting Standard Board-IASB) ដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការប្រើប្រាស់របស់សហគ្រាសអាជីវកម្មក្នុងការរៀបចំព័ត៌មានហិរញ្ញវត្ថុរបស់ខ្លួន សំដៅធានាបាននូវតម្លាភាព, គណនេយ្យភាព និងភាពអាចជឿទុកចិត្តបាននៃរបាយការណ៍ហិរញ្ញវត្ថុ។ ការអនុវត្តស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា គឺជាកាតព្វកិច្ចរបស់ម្ចាស់សហគ្រាស, គណនេយ្យករ

និងសវនករផងដែរ។ ការអនុវត្តស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា មិនត្រឹមតែរួម-ចំណែកលើកកម្ពស់ប្រសិទ្ធភាពនៃការប្រមូលពន្ធជូនរដ្ឋប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងផ្តល់ព័ត៌មានហិរញ្ញវត្ថុដ៏មានសារៈប្រយោជន៍ដល់អ្នកប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុនៅក្នុងការសម្រេចចិត្តពាក់ព័ន្ធនឹងការចូលរួមក្នុងសកម្មភាពសេដ្ឋកិច្ចនានា ។

ការដាក់ឱ្យអនុវត្តស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា គឺជាផ្នែកមួយនៃយុទ្ធសាស្ត្រ និងជាផែនការនៃការកសាងហេដ្ឋារចនាសម្ព័ន្ធទីផ្សារហិរញ្ញវត្ថុ ក្នុងផ្នែកអភិបាលកិច្ចសាជីវកម្ម និងហេដ្ឋារចនាសម្ព័ន្ធនៃ "**យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០១១-២០២០**" របស់រាជរដ្ឋា-ភិបាលកម្ពុជា ដែលបានទទួលការអនុម័តពីគណៈរដ្ឋមន្ត្រីនៅក្នុងកិច្ចប្រជុំពេញអង្គ នាថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១១។

ក្នុងនាមក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ខ្ញុំសូមវាយតម្លៃខ្ពស់ និង សម្តែងនូវការកោតសរសើរដ៏ស្មោះចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ឯកឧត្តម **ងី តាយី** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាជាតិគណនេយ្យ និងសមាជិកក្រុមប្រឹក្សាជាតិគណនេយ្យទាំងអស់ ព្រមទាំងថ្នាក់ដឹកនាំ និងមន្ត្រីនៃលេខាធិការដ្ឋាន ក.ជ.គ ដែលបានខិតខំពុះពារគ្រប់ឧបសគ្គ និងលះបង់ពេលវេលា, ធនធាន និងកំលាំងកាយចិត្ត ក្នុងការធ្វើឱ្យឯកសារដ៏មានតម្លៃនេះលេចចេញជារូបរាងឡើង។

*រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៥*

**រដ្ឋមន្ត្រី**

**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**



បណ្ឌិត **អូន ព័ន្ធមុនីរ័ត្ន**

# អារម្ភកថា

៙

យុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា បានរំលេចនូវទិសដៅចម្បង៤ គឺកំណើន ការងារ សមធម៌ និងប្រសិទ្ធភាព ព្រមទាំងបានបង្ហាញយ៉ាងច្បាស់នូវគោលបំណងចម្បងរបស់រាជរដ្ឋាភិបាល ក្នុងការសម្រេចបាននិងការរក្សានូវកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព រួមទាំងកិច្ចអភិវឌ្ឍន៍សង្គមកិច្ចមួយដ៏រឹងមាំនិងជានិរន្តន៍ ដែលធានាកម្រិតជីវភាពនិងសុខដុមភាពរបស់ប្រជាជនឱ្យប្រសើរឡើងជាលំដាប់។ នៅក្នុងបរិការណ៍នេះ វិស័យគណនេយ្យនិងសវនកម្មមានតួនាទីយ៉ាងសំខាន់នៅក្នុងជីវិតសេដ្ឋកិច្ចនិងសង្គម ពិសេសនៅក្នុងការធានាភាពត្រឹមត្រូវច្បាស់លាស់, តម្លាភាព, គណនេយ្យភាព និងអភិបាលកិច្ចល្អ ក្នុងការគ្រប់គ្រងកិច្ចប្រតិបត្តិការហិរញ្ញវត្ថុ ទាំងក្នុងវិស័យសាធារណៈនិងវិស័យឯកជន។ អាស្រ័យហេតុនេះ រាជរដ្ឋាភិបាលបាន ចាត់ទុកវិស័យគណនេយ្យនិងសវនកម្មនេះ ជាផ្នែកមួយដ៏សំខាន់នៅក្នុងការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុរបស់ជាតិ ដូចមានចែងនៅក្នុង “**យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ឆ្នាំ២០១១-២០២០**”។

អនុវត្តតាមស្មារតីនៃយុទ្ធសាស្ត្រខាងលើ រាជរដ្ឋាភិបាលកម្ពុជា ដែលមានក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាសេនាធិការ បានជំរុញការអភិវឌ្ឍន៍វិស័យនេះយ៉ាងសកម្ម ផ្តើមចេញពីការកសាងមូលដ្ឋានគ្រឹះសម្រាប់ការចុះកិច្ចបញ្ជិកាគណនេយ្យនិងការធ្វើសវនកម្ម តាមរយៈការរៀបចំនិងដាក់ឱ្យប្រើនូវច្បាប់ស្តីពី “គណនេយ្យសហគ្រាស សវនកម្មគណនេយ្យសហគ្រាស និងវិជ្ជាជីវៈគណនេយ្យ” នៅឆ្នាំ២០០២។ ផ្អែកតាមស្មារតីនៃច្បាប់ខាងលើ ក្នុងខែមករា ឆ្នាំ២០០៩ ស្តង់ដារគណនេយ្យកម្ពុជា ដែលរួមមាន“ *ស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា* ” និង *“ស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់សហគ្រាសធុនតូចនិងមធ្យម”* ត្រូវបានដាក់ឱ្យប្រើដោយប្រកាស *លេខ ០៦៨ ស.ហ.វ-ប្រ.ក ចុះថ្ងៃទី៨ ខែមករា ឆ្នាំ២០១៥*។ ក្នុងន័យនេះ សហគ្រាសសាធារណៈនិងក្រុមហ៊ុនឯកជននានាដែលកំពុងធ្វើប្រតិបត្តិការអាជីវកម្មនៅកម្ពុជា ត្រូវប្រើស្តង់ដាគណនេយ្យកម្ពុជាដើម្បីធ្វើជាមូលដ្ឋានសារវន្តនិងជាក្របខ័ណ្ឌសម្រាប់រៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួន ដើម្បីធានាបាននូវតម្លាភាព គណនេយ្យភាព និងភាពអាចជឿទុកចិត្តបានលើរបាយការណ៍ហិរញ្ញវត្ថុពីសំណាក់អ្នកប្រើប្រាស់និងសាធារណៈជន ហើយក៏អាចជាបច្ច័យមួយជួយជំរុញកំណើនចំណូលសារពើពន្ធ និងជួយគាំទ្រដល់វឌ្ឍភាពនិងស្ថេរភាពនៃទីផ្សារហិរញ្ញវត្ថុ ក៏ដូចជាជួយជំរុញកំណើនសេដ្ឋកិច្ចជាតិ។

អាស្រ័យហេតុនេះ ខ្ញុំសូមលើកទឹកចិត្តសហគ្រាសដែលមានការពាក់ពន្ធ័ ឱ្យអនុវត្តស្តង់ដាដែលមាននៅក្នុងសៀវភៅនេះដើម្បីរៀបចំរបាយការណ៍ហិរញ្ញវត្ថុទាំងសម្រាប់ការគ្រប់គ្រងផ្ទៃក្នុងនិងសម្រាប់ការដាក់បង្ហាញទៅអ្នកដែលមានការពាក់ព័ន្ធនានា។

*រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៥*

**រដ្ឋលេខាធិការ**

**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជា**

**ប្រធានក្រុមប្រឹក្សាជាតិគណនេយ្យ**

**វ៉ី គាយ៉ី**

## គោលបំណង

កម្មវត្ថុនៃស្តង់ដានេះ គឺអធិប្បាយពីការធ្វើគណនេយ្យកម្មពន្ធលើប្រាក់ចំណូល ។ បញ្ហាចម្បងក្នុង គណនេយ្យកម្មសម្រាប់ពន្ធលើប្រាក់ចំណូលគឺវិធីសាស្រ្ត ដើម្បីធ្វើគណនេយ្យកម្ម អំពីផលវិបាករបស់ពន្ធ នាពេលបច្ចុប្បន្ន និងនាពេលអនាគតនៃ ÷

ក ការទទួលបានមកវិញ (ឬការទូទាត់) នាពេលអនាគតនៃតម្លៃពិតគណនេយ្យនៃទ្រព្យសកម្ម (ឬបំណុល)ដែលត្រូវបានទទួលស្គាល់ក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុរបស់អង្គភាពមួយ និង

ខ ប្រតិបត្តិការ និងព្រឹត្តិការណ៍ផ្សេងៗទៀតនៃការិយបរិច្ឆេទនាពេលបច្ចុប្បន្នដែលត្រូវបានទទួលស្គាល់ក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់អង្គភាពមួយ ។

ជាធម្មតានៅក្នុងការទទួលស្គាល់ទ្រព្យសកម្ម ឬបំណុល ដែលអង្គភាពរាយ-ការណ៍រំពឹងនឹងទទួលបានមកវិញ ឬនឹងទូទាត់តម្លៃពិតគណនេយ្យនៃទ្រព្យសកម្ម ឬបំណុលនោះ។ ប្រសិនបើវាទំនងជាថា ការទទួលបានមកវិញ ឬការទូទាត់នៃតម្លៃពិតគណនេយ្យនោះ នឹងធ្វើឱ្យការបង់ពន្ធនាពេលអនាគតធំ (ឬតូច) ជាងអ្វីដែលត្រូវបង់នោះ ប្រសិនបើការទទួលបានមកវិញ ឬការទូទាត់ពន្ធ មិនមានផលវិបាកអ្វីឡើយ ហើយស្តង់ដានេះតម្រូវឱ្យអង្គភាពមួយទទួលស្គាល់ បំណុលពន្ធពន្យារ (ទ្រព្យសកម្មពន្ធពន្យារ) ជាមួយនឹងការលើកលែងមានកម្រិតជាក់លាក់ ។

ស្តង់ដារនេះ តម្រូវឱ្យអង្គភាពធ្វើគណនេយ្យកម្ម ផលវិបាកពន្ធពី ប្រតិបត្តិការ និងព្រឹត្តិការណ៍ផ្សេងទៀតនៅក្នុង របៀបដូចគ្នាដែល អង្គភាពធ្វើគណនេយ្យកម្មប្រតិបត្តិការ និងព្រឹត្តិការណ៍ ផ្សេងទៀត ដោយផ្ទាល់ ។ ដូច្នេះ សម្រាប់ប្រតិបត្តិការ និង ព្រឹត្តិការណ៍ផ្សេងទៀត ដែលបានទទួល ស្គាល់នៅក្នុងចំណេញ ឬខាតឥទ្ធិពលពន្ធ ដែលទាក់ទិន ផ្សេងទៀតក៏ត្រូវ បានទទួលស្គាល់ផងដែរ នៅក្នុងចំណេញ ឬខាត។ សម្រាប់ប្រតិបត្តិការនិងព្រឹត្តិការណ៍ផ្សេងទៀត ដែលទទួលស្គាល់ខាង ក្រៅប្រាក់ចំណេញ ឬខាត (នៅក្នុងលទ្ធផលសរុប ផ្សេងទៀត ឬដោយផ្ទាល់នៅក្នុង គណនីមូលនិធិ) បើមានឥទ្ធិពល ពន្ធទាក់ទិន ក៏ត្រូវទទួលស្គាល់នៅខាងក្រៅចំណេញ ឬខាត (នៅក្នុង លទ្ធផល ផ្សេងទៀត ឬដោយផ្ទាល់នៅក្នុងគណនីមូលនិធិ តាម លំដាប់លំដោយ)។ ស្រដៀងគ្នានេះដែរ ការទទួលស្គាល់ទ្រព្យសកម្មពន្ធ ពន្យារ និងបំណុល ពន្ធពន្យារនៅក្នុងការបញ្ចូលអាជីវកម្មរួមគ្នាបានប៉ះ ពាល់ដល់ចំនួន ទឹកប្រាក់នៃមូលនិធិពាណិជ្ជកម្មដែលបានកើតឡើង នៅក្នុងការបញ្ចូល អាជីវកម្មរួមគ្នា ឬចំនួនទឹកប្រាក់នៃចំណេញពីការទិញបាន តម្លៃថោក ដែលបានទទួលស្គាល់។

**ស្តង់ដារនេះក៏ជួយដោះស្រាយពីការទទួលស្គាល់ នៃទ្រព្យសកម្មពន្ធពន្យារ ដែលកើតចេញពីប្រាក់ខាតជាប់ពន្ធមិនបានប្រើ ឬ ឥណទានពន្ធមិនបាន ប្រើ ។ ការបង្ហាញពន្ធលើប្រាក់ចំណូលនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ និង ការលាតត្រដាងព័ត៌មានដែលទាក់ទិននឹងពន្ធលើប្រាក់ចំណូល ។**

## វិសាលភាព

**១ ស្តង់ដារនេះត្រូវបានអនុវត្តនៅក្នុងការធ្វើគណនេយ្យកម្មពន្ធលើប្រាក់ចំណូល**

២ សម្រាប់គោលបំណងនៃស្តង់ដារនេះ

ពន្ធលើប្រាក់ចំណូលរួមបញ្ចូលពន្ធក្នុង ស្រុក និងក្រៅប្រទេសទាំងអស់ ដែលត្រូវបានផ្អែកលើប្រាក់ចំណេញជាប់ពន្ធ។ ពន្ធលើប្រាក់ចំណូល ក៏បញ្ចូលផងដែរនូវពន្ធ ដូចជាពន្ធកាត់ទុក ដែលត្រូវបង់ដោយក្រុមហ៊ុន បុត្រសម្ព័ន្ធ ក្រុមហ៊ុនញាតិសម្ព័ន្ធ ឬក្រុមហ៊ុន រួមទុននៅពេលដែល បែងចែក ទៅឲ្យអង្គភាពរាយការណ៍ ។

៣ លុបចោល

៤ ស្តង់ដារនេះ មិនជាប់ពាក់ព័ន្ធជាមួយនឹង វិធីសាស្រ្តនៃគណនេយ្យ សម្រាប់អំណោយរដ្ឋាភិបាល (សូមមើល ស.គ.អ.ក ២០ *គណនេយ្យសម្រាប់អំណោយរដ្ឋាភិបាល និង ការលាតត្រដាងពីជំនួយរបស់ រដ្ឋាភិបាល)* ឬ ឥណទានពន្ធវិនិយោគ។ ប៉ុន្តែ ស្តង់ដារនេះដោះស្រាយលើការធ្វើគណ-នេយ្យកម្មលើភាពខុសគ្នាបណ្តោះអាសន្នដែលអាចកើតចេញពីអំណោយ ឬ ឥណទានពន្ធវិនិយោគទាំងអស់នោះ ។

## និយមន័យ

**៥ វាក្យស័ព្ទខាងក្រោមត្រូវបានប្រើនៅក្នុងស្តង់ដារនេះមានអត្ថន័យដូចខាងក្រោម:**

*ប្រាក់ចំណេញគណនេយ្យ* **គឺជាចំណេញ ឬខាតសម្រាប់គ្រាមួយមុនដកចេញចំណាយពន្ធ**

*ប្រាក់ចំណេញជាប់ពន្ធ (ប្រាក់ខាតជាប់ពន្ធ)* **គឺជាចំណេញ (ខាត) សម្រាប់គ្រា ដែលត្រូវបានកំណត់ដោយ អនុលោមតាមច្បាប់ ដែលបង្កើតដោយអាជ្ញាធរពន្ធដារ ដែលពន្ធលើប្រាក់ចំណូលត្រូវបង់ (ត្រូវទទួលបាន)។**

*ចំណាយពន្ធ (ចំណូលពន្ធ)* **គឺជាចំនួនទឹកប្រាក់សរុប ដែលបានបញ្ចូលក្នុងការកំណត់ប្រាក់ចំណេញ ឬខាត សម្រាប់គ្រាទាក់ទងនឹងពន្ធបច្ចុប្បន្ន និងពន្ធពន្យារ។**

*ពន្ធបច្ចុប្បន្ន* **គឺជាចំនួនទឹកប្រាក់នៃពន្ធលើប្រាក់ចំណូលត្រូវបង់ (ត្រូវទទួលបាន ) ទាក់ទងនឹងប្រាក់ ចំណេញ ជាប់ពន្ធ (ប្រាក់ខាតជាប់ពន្ធ ) សម្រាប់គ្រាមួយ។**

*បំណុលពន្ធពន្យារ* **គឺជាចំនួនទឹកប្រាក់នៃពន្ធលើប្រាក់ចំណូលដែលត្រូវបង់នៅក្នុងគ្រាអនាគតទាក់ទង និង ភាពខុសគ្នាបណ្តោះអាសន្នជាប់ពន្ធ។**

*ទ្រព្យសកម្មពន្ធពន្យារ* **គឺជាចំនួនទឹកប្រាក់នៃពន្ធលើប្រាក់ចំណូលដែលត្រូវទទួលបាននៅក្នុងគ្រា អនាគត ទាក់ទងនឹង:**

(ក) ភាពខុសគ្នាបណ្តោះអាសន្នដែលអាចកាត់កងបាន

(ខ) ការយោងបន្តនៃប្រាក់ខាតជាប់ពន្ធមិនបានប្រើ

(គ) ការយោងបន្តឥណទានពន្ធដែលមិនបានប្រើ

*ភាពខុសគ្នាបណ្តោះអាសន្ន* គឺជាភាពខុសគ្នារវាងតម្លៃពិតគណនេយ្យនៃទ្រព្យសកម្ម ឬបំណុល នៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ និងមូលដ្ឋានពន្ធរបស់វា។ ភាពខុសគ្នាបណ្តោះអាសន្នអាចជា:

*(ក) ភាពខុសគ្នាបណ្តោះអាសន្នជាប់ពន្ធ* **ដែលជាភាពខុសគ្នាបណ្តោះអាសន្ន ដែលនឹងបង្ហាញជាចំនួនទឹកប្រាក់ជាប់ពន្ធ ក្នុងការកំណត់ប្រាក់ចំណេញជាប់ពន្ធ (ប្រាក់ខាតជាប់ពន្ធ) នៃគ្រាអនាគតនៅពេលដែល**

**តម្លៃពិតគណនេយ្យនៃទ្រព្យសកម្មឬបំណុលត្រូវបានទទួលមកវិញ ឬទូទាត់ ឬ**

*(ខ) ភាពខុសគ្នាបណ្ដោះអាសន្នអាចកាត់កង* **ដែលជាភាពខុសគ្នាបណ្ដោះអាសន្នដែលនឹងបង្ហាញជាចំនួន ទឹកប្រាក់ដែលអាចកាត់កងបានក្នុងការកំណត់ប្រាក់ចំណេញជាប់ពន្ធ (ប្រាក់ខាតជាប់ពន្ធ) នៃគ្រាអនាគត នៅពេលដែលតម្លៃពិតគណនេយ្យនៃទ្រព្យសកម្ម ឬបំណុលត្រូវបានទទួល ឬត្រូវបានទូទាត់។**

*មូលដ្ឋានពន្ធ* **នៃទ្រព្យសកម្មឬបំណុលគឺជាចំនួនទឹកប្រាក់ដែលបែងចែកទៅទ្រព្យសកម្ម ឬបំណុលនោះ សម្រាប់គោលបំណងពន្ធ។**

៦ ចំណាយពន្ធ (ចំណូលពន្ធ) រួមបញ្ចូលចំណាយពន្ធបច្ចុប្បន្ន (ចំណូលពន្ធបច្ចុប្បន្ន) និង ចំណាយពន្ធពន្យារ (ចំណូលពន្ធពន្យារ)។

**មូលដ្ឋានពន្ធ**

៧ មូលដ្ឋានពន្ធនៃទ្រព្យសកម្មគឺជាចំនួនទឹកប្រាក់ ដែលនឹងអាចកាត់កងបានសម្រាប់គោលបំណងពន្ធទល់នឹង អត្ថប្រយោជន៍សេដ្ឋកិច្ចជាប់ពន្ធណាមួយ ដែលនឹងហូរមកកាន់អង្គភាពនៅពេល ដែលអង្គភាពទទួលបានពីតម្លៃពិត គណនេយ្យនៃទ្រព្យសកម្ម។ ប្រសិនបើអត្ថប្រយោជន៍សេដ្ឋកិច្ចទាំងនោះ មិនជាប់ពន្ធទេ នោះមូលដ្ឋានពន្ធនៃ ទ្រព្យសកម្មស្មើនឹងតម្លៃពិតគណនេយ្យ របស់ទ្រព្យសកម្មនោះ ។

| ឧទាហរណ៍ | |
|---|---|
| ១ | ម៉ាស៊ីនមួយមានថ្លៃដើម ១០០។ សម្រាប់គោលបំណងពន្ធរំលស់ ៣០ ត្រូវបានកាត់ចេញ នៅក្នុងគ្រាបច្ចុប្បន្ន និងគ្រាមុនរួមហើយ និងថ្លៃដើមនៅសល់នឹងត្រូវកាត់កងនៅក្នុងគ្រាអនាគត ជារំលស់ ឬតាមរយៈការកាត់ចេញនៅពេលលក់ចោល។ ចំណូលដែលរកបាន ពីការប្រើប្រាស់ម៉ាស៊ីនត្រូវជាប់ពន្ធ ចំណេញពីការលក់ចោលម៉ាស៊ីននឹងត្រូវជាប់ពន្ធ ហើយការខាតពីការលក់ចោល នឹងត្រូវបានកាត់កង សម្រាប់គោលបំណងពន្ធដារ។ *មូលដ្ឋានពន្ធនៃម៉ាស៊ីនគឺ ៧០។* |
| 2 | ការប្រាក់ត្រូវទទួលមានតម្លៃពិតគណនេយ្យ ១០០។ ចំណុលការប្រាក់ទាក់ទិននឹង ត្រូវជាប់ពន្ធតាមមូលដ្ឋានសាច់ប្រាក់ ។ *មូលដ្ឋានពន្ធនៃការប្រាក់ត្រូវទទួលគឺគ្មាន* ។ |
| 3 | គណនីពាណិជ្ជកម្មត្រូវទទួល មានតម្លៃពិតគណនេយ្យ ១០០។ ចំណូលទាក់ទិនត្រូវបានរួមបញ្ចូលនៅក្នុងប្រាក់ចំណេញជាប់ពន្ធរួចហើយ (ប្រាក់ខាតជាប់ពន្ធ) ។ *មូលដ្ឋានពន្ធគណនីពាណិជ្ជកម្មត្រូវទទួលគឺ១០០។* |
| 4 | ភាគលាភត្រូវទទួលពីក្រុមហ៊ុនបុត្រសម្ព័ន្ធមានតម្លៃពិតគណនេយ្យ១០០។ ភាគលាភ មិនជាប់ពន្ធទេ។ *តាមភាពពិត តម្លៃពិតគណនេយ្យសរុបនៃទ្រព្យសកម្មអាច កាត់កងបានទល់នឹងអត្ថប្រយោជន៍សេដ្ឋកិច្ច។ ដូច្នេះមូលដ្ឋានពន្ធនៃភាគលាភត្រូវទទួលគឺ១០០*[ក] ។ |
| 5 | កម្ចីត្រូវទទួលមានតម្លៃពិតគណនេយ្យ ១០០។ ការសងកម្ចីនឹងមិនមាន |

ផលវិបាកពន្ធទេ។ មូលដ្ឋានពន្ធនៃកម្ចី ១០០ ។

(ក) ក្រោមការវិភាគនេះ មិនមានភាពខុសគ្នាបណ្តោះជាប់ពន្ធទេ។ ការវិភាគជំរើស ផ្សេងមួយទៀតគឺថា ភាគលាភបង្គរត្រូវទទួលមានមូលដ្ឋានពន្ធសូន្យ និងអត្រាពន្ធសូន្យដែរ ត្រូវបានអនុវត្តចំពោះភាពខុសគ្នាបណ្តោះអាសន្នជាប់ពន្ធ ១០០ ។ ក្រោមការវិភាគទាំងពីរនេះ ពុំមានបំណុលពន្ធពន្យារទេ ។

៨ មូលដ្ឋានពន្ធនៃបំណុលគឺតម្លៃពិតគណនេយ្យ ដកចេញនូវចំនួនទឹកប្រាក់ដែលអាចកាត់កងបានសម្រាប់គោលបំណងពន្ធ ដែលទាក់ទងនឹងបំណុលនោះក្នុងគ្រាអនាគត។ នៅក្នុងករណីចំណូលដែលបានទទួលជាមុនមូលដ្ឋានពន្ធនៃបំណុល គឺជាតម្លៃពិតគណនេយ្យរបស់បំណុលនោះដកចេញចំនួនទឹកប្រាក់នៃចំណូលដែលមិនជាប់ពន្ធនៅគ្រាអនាគត។

| ឧទាហរណ៍ |
|---|
| 1 បំណុលបច្ចុប្បន្នរួមបញ្ចូលចំណាយបង្គរតាមតម្លៃពិតគណនេយ្យ ១០០។ ចំណាយទាក់ទិននឹងត្រូវកាត់កង សម្រាប់គោលបំណងពន្ធដារតាមមូលដ្ឋានសាច់ប្រាក់។ *មូលដ្ឋានពន្ធនៃចំណាយបង្គរគឺ សូន្យ។* |
| 2 បំណុលបច្ចុប្បន្នរួមបញ្ចូលចំណូលពីការប្រាក់ ដែលបានទទួលជាមុនតាមតម្លៃពិតគណនេយ្យ ១០០។ ចំណូលការប្រាក់ទាក់ទិនត្រូវជាប់ពន្ធតាមមូលដ្ឋានសាច់ប្រាក់។ *មូលដ្ឋានពន្ធនៃការប្រាក់ ដែលបានទទួលជាមុនគឺសូន្យ។* |

3 បំណុលបច្ចុប្បន្នរួមបញ្ចូលទាំងចំណាយបង្គរដែលមានតម្លៃពិតគណនេយ្យ ១០០។ ចំណាយពាក់ព័ន្ធ ត្រូវបានកាត់កងរួចហើយសម្រាប់គោលបំណងពន្ធដារ។ *មូលដ្ឋានពន្ធនៃចំណាយបង្គរគឺ ១០០។*

4 បំណុលបច្ចុប្បន្នរួមបញ្ចូលប្រាក់ពិន័យបង្គរនិងទោសទណ្ឌដែល មានតម្លៃពិតគណនេយ្យ ១០០។ ប្រាក់ពិន័យនិងទោសទណ្ឌមិនអាចកាត់កងបានទេសម្រាប់គោលបំណងពន្ធ។ *មូលដ្ឋានពន្ធនៃប្រាក់ពិន័យបង្គរ និងទោសទណ្ឌគឺ ១០០។*[ក]

5 កម្ចីត្រូវសងមានតម្លៃពិតគណនេយ្យ ១០០។ ការទូទាត់សងកម្ចីមិនមានផលវិបាកពន្ធទេ។ *មូលដ្ឋានពន្ធនៃកម្ចីគឺ១០០។*

(ក) ក្រោមការវិភាគនេះ មានភាពខុសគ្នាបណ្តោះអាសន្នមិនអាចកាត់កងបាន។ ការវិភាគផ្សេងទៀតគឺថា ប្រាក់ពិន័យនិងទោសទណ្ឌត្រូវសងមានមូលដ្ឋានពន្ធស្មើនឹងសូន្យ ហើយអត្រាពន្ធស្មើនឹងសូន្យ ត្រូវបានអនុវត្តចំពោះភាពខុសគ្នាបណ្តោះអាសន្នដែលមានអាចកាត់កងបាន ១០០។ ក្រោមការវិភាគទាំងពីរនេះមិនមានទ្រព្យសកម្មពន្ធពន្យារទេ។

៩ ធាតុមួយចំនួនមានមូលដ្ឋានពន្ធ ប៉ុន្តែមិនត្រូវបានទទួលស្គាល់ជា ទ្រព្យសកម្មនិងបំណុលទេនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ។ ឧទាហរណ៍ ចំណាយលើការស្រាវជ្រាវ ត្រូវបានទទួលស្គាល់ជាចំណាយនៅក្នុងការ កំណត់ប្រាក់ចំណេញគណនេយ្យ នៅក្នុងគ្រាដែលចំណាយនោះបានកើតឡើង ប៉ុន្តែមិនត្រូវបានអនុញ្ញាតិជា ការកាត់ចេញពីការកំណត់ប្រាក់ចំណេញ ជាប់ពន្ធ (ខាតជាប់ពន្ធ) រហូតដល់គ្រាក្រោយឡើយ។ ភាពខុសគ្នា

រវាងមូលដ្ឋានពន្ធនៃចំណាយស្រាវជ្រាវ ជាចំនួនទឹកប្រាក់ដែលអាជ្ញាធរពន្ធដារនឹងអនុញ្ញាត សម្រាប់ការកាត់កងនៅក្នុងគ្រាអនាគត និងតម្លៃពិតគណនេយ្យស្មើនឹងសូន្យ គឺជាភាពខុសគ្នាបណ្តោះអាចកាត់កងបានដែលផ្តល់លទ្ធផលជាទ្រព្យសកម្មពន្ធពន្យារ។

១០ ពេលដែលមូលដ្ឋានពន្ធនៃទ្រព្យសកម្ម ឬបំណុលមិនកើតមានភ្លាមគោល-ការណ៍គ្រឹះ ដែលស្តង់ដារបានចែង នឹងមានប្រយោជន៍ ដើម្បីធ្វើការពិចារណាៈ នោះគឺថា ជាមួយនឹងការលើកលែងមានកម្រិតណាមួយ អង្គភាព ត្រូវទទួលស្គាល់បំណុល (ទ្រព្យសកម្ម) ពន្ធពន្យារនៅពេលណាក៏ដោយ ដែលការទទួលបានមកវិញ ឬការទូទាត់តម្លៃពិតគណនេយ្យនៃ ទ្រព្យសកម្ម ឬបំណុលអាចបង្កើតឡើងនូវការ បង់ប្រាក់ពន្ធនាពេលអនាគត ធំជាង (តូចជាង) ការទទួលបានមកវិញ ឬការទូទាត់គួរមាន ប្រសិនបើការទទួលបានមកវិញ ឬការទូទាត់មិនត្រូវមានផលវិបាកពន្ធ ទេនោះ ។ ឧទាហរណ៍ ដោយអនុវត្តតាមកថាខណ្ឌ ៥១ក បានពន្យល់ពីហេតុការណ៍ពេល ដែលគេគិតថាវាមានប្រយោជន៍ ដើម្បីពិចារណាពីគោលការណ៍គ្រឹះនេះ ឧទាហរណ៍នៅពេលមូលដ្ឋានពន្ធ នៃទ្រព្យសកម្ម ឬ បំណុលផ្អែកលើកិរិយាបទ ដែលបានរំពឹងពីការទទួលបានមកវិញ និងការទូទាត់ ។

១១ នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរួម ភាពខុសគ្នាបណ្តោះត្រូវបានកំណត់ដោយការប្រៀបធៀបតម្លៃពិតគណនេយ្យនៃទ្រព្យសកម្ម និង បំណុលនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរួម តាមមូលដ្ឋានពន្ធត្រឹមត្រូវ ។ មូលដ្ឋានពន្ធត្រូវបានកំណត់ដោយយោងតាមលិខិតប្រកាសពន្ធរួមនៅក្នុងប្រទេសទាំងនោះ

ដែលនៅក្នុងលិខិតនោះ ត្រូវបានបំពេញ។ នៅក្នុងប្រទេសផ្សេងទៀត មូលដ្ឋានពន្ធ ត្រូវបានកំណត់ដោយយោងតាមលិខិត ប្រកាសពន្ធរបស់អង្គភាពនៅក្នុងក្រុម ។

## ការទទួលស្គាល់បំណុលពន្ធបច្ចុប្បន្ននិងទ្រព្យសកម្មពន្ធបច្ចុប្បន្ន

**១២ ពន្ធបច្ចុប្បន្នសម្រាប់គ្រាមុននឹងបច្ចុប្បន្ន ចំពោះទំហំទឹកប្រាក់មិនទាន់បង់ត្រូវបានទទួលស្គាល់ជាបំណុល ។ ប្រសិនចំនួនទឹកប្រាក់បានបង់រួចទាក់ទងនឹងគ្រាមុននឹងគ្រាបច្ចុប្បន្នលើសចំនួនទឹកប្រាក់ ដែលត្រូវសងសម្រាប់គ្រាទាំងនោះ ផ្នែកលើសត្រូវបានទទួលស្គាល់ជាទ្រព្យសកម្ម ។**

**១៣ អត្ថប្រយោជន៍ទាក់ទងនឹងប្រាក់ខាតជាប់ពន្ធដែលអាចយោងត្រឡប់ក្រោយដើម្បីទទួលបានពន្ធបច្ចុប្បន្ន នៃគ្រាមុនត្រូវបានទទួលស្គាល់ជាទ្រព្យសកម្ម ។**

១៤ នៅពេលដែលប្រាក់ខាតជាប់ពន្ធត្រូវបានប្រើដើម្បីទទួលប្រាក់បច្ចុប្បន្ន នៃគ្រាមុនមកវិញ អង្គភាពមួយទទួល ស្គាល់អត្ថប្រយោជន៍នោះជា ទ្រព្យ-សកម្មនៅក្នុងគ្រា ដែលប្រាក់ខាតជាប់ពន្ធនោះបានកើតឡើង ពីព្រោះវាទំនងថាអត្ថប្រយោជន៍នឹងហូរមកកាន់អង្គភាព និង អត្ថប្រយោជន៍អាចត្រូវបានវាស់វែងដោយជឿជាក់ ។

**ភាពខុសគ្នាជាប់ពន្ធបណ្តោះអាសន្ន**

**១៥ បំណុលពន្ធពន្យារត្រូវបានទទួលស្គាល់សម្រាប់គ្រប់ភាពខុសគ្នាជាប់ពន្ធបណ្តោះអាសន្ន លើកលែងតែបំណុល ពន្ធពន្យារកើតចេញពីៈ**

**(ក) ការទទួលស្គាល់មូលនិធិពាណិជ្ជកម្មដំបូង ឬ**

**(ខ) ការទទួលស្គាល់ទ្រព្យសកម្ម ឬបំណុលដំបូងក្នុងប្រតិបត្តិការដែល**

**(១) មិនមែនជាការបញ្ចូលអាជីវកម្មរួមគ្នា និង**

**(២) នៅពេលដែលប្រតិបត្តិការ មិនប៉ះពាល់ប្រាក់ចំណេញគណនេយ្យ និង មិនប៉ះពាល់ប្រាក់ចំណេញជាប់ពន្ធ (ប្រាក់ខាតជាប់ពន្ធ)**

**ប៉ុន្តែ សម្រាប់ភាពខុសគ្នាបណ្តោះអាសន្នជាប់ពន្ធដែលជាប់ពាក់ពន្ធជាមួយនឹងការវិនិយោគនៅក្នុង ក្រុមហ៊ុនបុត្រសម្ព័ន្ធក្រុមហ៊ុនជាសាខា និង ក្រុមហ៊ុនញ្ញាតិសម្ព័ន្ធ និងភាគកម្មនៅក្នុងក្រុមរួមទុន បំណុលពន្ធពន្យារត្រូវបាន ទទួលស្គាល់ដោយអនុលោមតាមកថាខណ្ឌ ៣៩ ។**

១៦ វាមានភាពទាក់ទិនផងដែរនៅក្នុងការទទួលស្គាល់ទ្រព្យសកម្ម ដែលតម្លៃពិតគណនេយ្យនៃ ទ្រព្យសកម្មធំជាងមូលដ្ឋានពន្ធ ចំនួនទឹកប្រាក់នៃ អត្ថប្រយោជន៍សេដ្ឋកិច្ចជាប់ពន្ធ នឹងលើសពីចំនួនទឹកប្រាក់ដែលនឹងត្រូវបានអនុញ្ញាតឱ្យកាត់កង សម្រាប់គោលបំណងពន្ធ។ នៅពេលដែលអង្គភាពទទួលបានមកវិញនូវតម្លៃពិតគណនេយ្យនៃទ្រព្យសកម្ម ភាពខុសគ្នាជាប់ពន្ធបណ្តោះអាសន្ននឹងត្រឡប់មកវិញ ហើយអង្គភាពមានប្រាក់ចំណេញជាប់ពន្ធ។ នេះបានធ្វើឱ្យមានភាពទំនងថាអត្ថប្រយោជន៍សេដ្ឋកិច្ចនឹងហូរ

ពីអង្គភាពនៅក្នុងទម្រង់នៃការបង់ពន្ធ។ ដូច្នេះ ស្តង់ដារនេះតម្រូវឱ្យទទួលស្គាល់បំណុលពន្ធពន្យារទាំងអស់ លើកលែងតែក្នុងកាលៈទេសៈជាក់លាក់មួយចំនួនដូចមានបរិយាយក្នុងកថា ១៥ និង ៣៩។

| ឧទាហរណ៍ |
|---|
| ទ្រព្យសកម្មមួយមានថ្លៃដើម ១៥០ មានតម្លៃពិតគណនេយ្យ ១០០។ រំលស់បង្គរសម្រាប់គោលបំណងពន្ធគឺ ៩០ និង អត្រាពន្ធ ២៥%។ *មូលដ្ឋានពន្ធនៃទ្រព្យសកម្ម ៦០ (ថ្លៃដើម១៥០ ដក រំលស់ពន្ធបង្គរ៩០) ដើម្បីទទួលបានតម្លៃពិតគណនេយ្យ១០០ អង្គភាពត្រូវរកបានចំណូលជាប់ពន្ធ១០០ ប៉ុន្តែអាចកាត់កងរំលស់ពន្ធបានតែ៦០។ ជាផលវិបាក អង្គភាពនឹងបង់ពន្ធលើប្រាក់ចំណូល ១០ (៤០ តាមអត្រា ២៥%) នៅពេលដែលអង្គភាពទទួលបានមកវិញតម្លៃពិតគណនេយ្យនៃទ្រព្យសកម្ម។ ភាពខុសគ្នារវាងតម្លៃពិតគណនេយ្យ ១០០ និងមូលដ្ឋានពន្ធ ៦០ គឺជាភាពខុសគ្នាបណ្តោះអសន្ន ៤០។ ដូច្នេះ អង្គភាពទទួលស្គាល់បំណុលពន្ធពន្យារ ១០ (៤០ តាមអត្រា ២៥%) តំណាងឱ្យពន្ធលើប្រាក់ចំណូល ដែលនឹងបង់ពេលអង្គភាព ទទួលបានមកវិញនូវតម្លៃពិតគណនេយ្យនៃទ្រព្យសកម្ម។* |

១៧ ភាពខុសគ្នាបណ្តោះអាសន្នខ្លះកើតឡើងនៅពេលចំណូល ឬចំណាយត្រូវបានបញ្ចូលនៅក្នុងប្រាក់ចំណេញ គណនេយ្យ ប៉ុន្តែត្រូវបានបញ្ចូលនៅក្នុងប្រាក់ចំណេញជាប់ពន្ធនៅក្នុងគ្រាខុសគ្នា។ ភាពខុសគ្នាបណ្តោះអាសន្នបែបនេះជារឿយៗ ត្រូវបានចាត់ទុកជាភាពខុសគ្នាលើពេលវេលា។ ខាង

ក្រោមគឺជាឧទាហរណ៍នៃភាព ខុសគ្នានៃប្រភេទនេះដែលជាភាពខុសគ្នាបណ្ដោះអាសន្នជាប់ពន្ធ ហើយចុងក្រោយផ្ដល់លទ្ធផលបំណុលពន្ធ ពន្យារៈ

(ក)ចំណូលការប្រាក់ត្រូវបានបញ្ចូលនៅក្នុងប្រាក់ចំណេញគណនេយ្យតាមសមាមាត្រពេលវេលា ប៉ុន្តែនៅក្នុងប្រទេសខ្លះអាចត្រូវបាន បញ្ចូលនៅក្នុងប្រាក់ចំណេញជាប់ពន្ធនៅពេលដែលសាច់ប្រាក់ត្រូវបាន ប្រមូល ។ មូលដ្ឋានពន្ធនៃគណនីត្រូវទទួលណាមួយ ដែលបានទទួល ស្គាល់នៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុទាក់ទិននឹងចំណូល បែបនេះស្មើនឹងសូន្យ ពីព្រោះចំណូលមិនប៉ះពាល់ប្រាក់ចំណេញជាប់ពន្ធ រហូតដល់សាច់ប្រាក់ ត្រូវបានប្រមូល ។

(ខ)រំលស់ត្រូវបានប្រើនៅក្នុងការកំណត់ប្រាក់ចំណេញដែលជាប់ពន្ធ (ប្រាក់ខាតជាប់ពន្ធ ) អាចខុសពីរំលស់ដែលបានប្រើ ដើម្បីកំណត់ប្រាក់ចំណេញគណនេយ្យ។ ភាពខុសគ្នាបណ្ដោះអាសន្នគឺជាភាពខុសគ្នារវាងតម្លៃពិតគណនេយ្យនៃទ្រព្យសកម្ម និង មូលដ្ឋានពន្ធ ដែលថ្លៃដើមប្រវត្តិសាស្ត្រទ្រព្យសកម្មដកចេញការ កាត់កងទាំងអស់ដែលទាក់ទិននឹងទ្រព្យ-សកម្មនោះ ដែលបានអនុញ្ញាតដោយអាជ្ញាធរពន្ធដារនៅក្នុងកំណត់ប្រាក់ចំណេញជាប់ពន្ធនៃគ្រាបច្ចុប្បន្ននិងគ្រាមុន ។ ភាពខុសគ្នាបណ្ដោះអាសន្នជាប់ពន្ធកើតឡើងនិងផ្ដល់លទ្ធផលនៅក្នុងបំណុលពន្ធពន្យារ រនៅពេលដែលរំលស់តាមពន្ធ ត្រូវបានបង្កើនឡើង (ប្រសិនបើរំលស់តាមពន្ធតិចជាងរំលស់គណនេយ្យ នោះនឹងមានភាពខុសគ្នាបណ្ដោះអាសន្នអាចកាត់កងបាន និង ផ្ដល់លទ្ធផលនៅក្នុងទ្រព្យសកម្មពន្ធពន្យារ) និង

(គ) ចំណាយលើការអភិវឌ្ឍអាចត្រូវបានធ្វើមូលធនកម្មនិងរំលស់លើរយៈពេលគ្រាអនាគតនៅក្នុង ការកំណត់ប្រាក់ចំណេញគណនេយ្យ ប៉ុន្តែត្រូវបានកាត់ចេញនៅក្នុងការកំណត់ប្រាក់ចំណេញជាប់ពន្ធ នៅក្នុងគ្រាដែល ចំណាយទាំងនោះកើតឡើង។ ភាពខុសគ្នាបណ្តោះអាសន្នគឺជាភាពខុសគ្នា រវាងតម្លៃពិតគណនេយ្យនៃចំណាយអភិវឌ្ឍ និងមូលដ្ឋានពន្ធស្មើនឹងសូន្យ។

១៨ ភាពខុសគ្នាបណ្តោះអសន្នក៏កើតឡើងផងដែរនៅពេលៈ

(ក) ទ្រព្យសកម្មអាចកំណត់បានដែលបានទិញ និងបំណុលដែលកើតមាននៅក្នុងការបញ្ចូលអាជីវកម្មរួម គ្នាត្រូវបានទទួលស្គាល់តាមតម្លៃទីផ្សារដោយអនុលោមតាម ស.រ.ហ.អ.ក ៣ *ការបញ្ចូលអាជីវកម្មរួមគ្នា* ប៉ុន្តែមិនមានការកែសំរួលសមមូល ត្រូវបានធ្វើឡើងទេសម្រាប់គោលបំណងពន្ធដារ
(សូមមើលកថាខណ្ឌ ១៩)

(ខ) ទ្រព្យសកម្មត្រូវបានវាយតម្លៃ និងមិនមានការកែសំរួលសមមូល ត្រូវបានធ្វើឡើងទេសម្រាប់គោលបំណងពន្ធដារ
(សូមមើលកថា- ខណ្ឌ ២០)

(គ) មូលនិធិពាណិជ្ជកម្ម កើតឡើងនៅក្នុងការបញ្ចូលអាជីវកម្មរួមគ្នា
(សូមមើលកថាខណ្ឌ ២១)

(ឃ) មូលដ្ឋានពន្ធនៃទ្រព្យសកម្ម ឬបំណុលនៅពេលទទួលស្គាល់លើកដំបូងខុសពីតម្លៃពិតគណនេយ្យលើកដំបូង ឧទាហរណ៍ នៅពេល

ដែលអង្គភាពទទួលអត្ថប្រយោជន៍ ពីអំណោយរបស់រដ្ឋាភិបាល ដែលមិនជាប់ពន្ធទាក់ទងនឹងទ្រព្យសកម្ម (សូមមើលកថាខណ្ឌ ២២ និង ៣៣) ឬ

(ង) តម្លៃពិតគណនេយ្យ នៃការវិនិយោគក្នុង ក្រុមហ៊ុនបុត្រសម្ព័ន្ធ សាខា និងញ្ញាតិសម្ព័ន្ធ និងភាគកម្ម ក្នុងក្រុមហ៊ុនរួមទុនខុសពី មូលដ្ឋានពន្ធនៃការវិនិយោគ ឬភាគកម្ម (សូមមើលកថាខណ្ឌ ៣៨-៤៥)។

## ការបញ្ចូលអាជីវកម្មរួមគ្នា

១៩ ជាមួយនឹងការលើកលែងមានកម្រិត ទ្រព្យសកម្មអាចកំណត់ដែលបានទិញ និង បំណុលដែលបានកើតឡើង នៅក្នុងការបញ្ចូលអាជីវកម្មរួមគ្នាត្រូវបាន ទទួលស្គាល់តាមតម្លៃទីផ្សារនៅថ្ងៃទិញ។ ភាពខុសគ្នាបណ្តោះអាសន្នកើត ឡើងនៅពេលមូលដ្ឋានពន្ធនៃទ្រព្យសកម្មអាចកំណត់បានដែលបានទិញ និង បំណុលដែលកើត មានមិនមានផលប៉ះពាល់ពីការបញ្ចូលអាជីវកម្ម រួមគ្នា ឬ ត្រូវប៉ះពាល់ដាច់ដោយឡែក។ ឧទាហរណ៍ នៅពេលតម្លៃពិត គណនេយ្យនៃទ្រព្យសកម្មត្រូវបានបង្កើនដល់តម្លៃទីផ្សារ ប៉ុន្តែមូលដ្ឋាន ពន្ធនៃទ្រព្យសកម្មរក្សានៅត្រឹមថ្លៃដើម ចំពោះម្ចាស់មុន នោះភាពខុសគ្នា បណ្តោះអាសន្នជាប់ពន្ធកើតឡើងដែលជាបំណុលពន្ធពន្យារ។ បំណុលពន្ធ ពន្យារ ដែលមានប៉ះពាល់ដល់ មូលនិធិពាណិជ្ជកម្ម (សូមមើលកថាខណ្ឌ ៦៦)។

## ទ្រព្យសកម្មកត់ត្រាតាមតម្លៃទីផ្សារ

២០ ស.រ.ហ.អ.ក អនុញ្ញាត ឬតម្រូវឲ្យទ្រព្យសកម្មជាក់លាក់មួយចំនួនត្រូវកត់ត្រាតាមតម្លៃទីផ្សារ ឬត្រូវវាយតម្លៃឡើងវិញ (សូមមើលឧទាហរណ៍ ស.គ.អ.ក ១៦ *ទ្រព្យ រោងចក្រ និងបរិក្ខារ* ស.គ.អ.ក ៣៨ *ទ្រព្យសកម្មអរូបី* ស.គ.អ.ក ៤០ *ទ្រព្យវិនិយោគ* និង ស.រ.ហ.អ.ក ៩ *ឧបករណ៍ហិរញ្ញវត្ថុ*)។ នៅក្នុងប្រទេសខ្លះ ការវាយតម្លៃឡើងវិញ ឬការបង្ហាញឡើងវិញផ្សេងទៀតពីទ្រព្យសកម្មតាមតម្លៃទីផ្សារប៉ះពាល់ដល់ ប្រាក់ចំណេញជាប់ពន្ធ (ខាតជាប់ពន្ធ ) សម្រាប់គ្រាបច្ចុប្បន្ន។ ជាលទ្ធផល មូលដ្ឋាននៃទ្រព្យសកម្មត្រូវបានកែសំរួល និងមិនមានភាពខុសគ្នាបណ្តោះអាសន្នកើតឡើងទេ។ នៅក្នុងប្រទេសផ្សេងទៀត ការវាយតម្លៃ ឬការបង្ហាញឡើងវិញនៃទ្រព្យសកម្មមិនប៉ះពាល់ដល់ប្រាក់ចំណេញជាប់ពន្ធនៅក្នុងគ្រានៃការវាយតម្លៃ ឬ ការបង្ហាញឡើងវិញ និងជាផលវិបាក មូលដ្ឋានពន្ធនៃទ្រព្យសកម្មមិនត្រូវបានកែសំរួលទេ។ តែទោះបីជាយ៉ាងណាក៏ដោយ ការទទួលបានមកវិញនៃតម្លៃពិតគណនេយ្យនាពេលអនាគតនឹងនាំឲ្យមានលំហូរអត្ថប្រយោជន៍សេដ្ឋកិច្ចជាប់ពន្ធចំពោះអង្គភាព និងចំនួនទឹកប្រាក់ ដែលអាច កាត់កងបានសម្រាប់គោលបំណងពន្ធនឹងខុសពីចំនួនទឹកប្រាក់នៃអត្ថប្រយោជន៍សេដ្ឋកិច្ចទាំងនោះ។ ភាពខុសគ្នារវាងតម្លៃពិតគណនេយ្យនៃ ទ្រព្យសកម្មវាយតម្លៃរួច និងមូលដ្ឋានពន្ធ គឺជាភាពខុសគ្នាបណ្តោះអាសន្ន ហើយនឹងផ្តល់ឲ្យ ការកើនឡើងចំពោះបំណុលពន្ធពន្យារ ឬទ្រព្យសកម្មពន្ធ ពន្យារ។ នេះជាការពិតប្រសិនបើៈ

(ក) អង្គភាពមិនមានបំណងលក់ទ្រព្យសកម្ម។ នៅក្នុងករណីបែបនេះ តម្លៃពិតគណនេយ្យនៃ ទ្រព្យសកម្មវាយតម្លៃរួច នឹងត្រូវបាន

ទទួលមកវិញ តាមរយៈការប្រើប្រាស់ ហើយវានឹងបង្កើតឱ្យមានចំណូលជាប់ពន្ធ ដែលលើសពីតម្លៃរំលស់ ដែលនឹងអាចកាត់កងបានសម្រាប់គោលបំណងពន្ធដារនៅក្នុងគ្រាអនាគតឬ

(ខ) ពន្ធលើប្រាក់ចំណេញមូលធន ត្រូវបានពន្យារប្រសិនបើប្រាក់ទទួល បានពីការលក់ទ្រព្យសកម្ម ត្រូវបានវិនិយោគនៅក្នុង ទ្រព្យសកម្មស្រដៀងគ្នា ។ នៅក្នុងករណីបែបនេះ ចុងក្រោយបង្អស់ពន្ធនឹងក្លាយជាបំណុលត្រូវសងលើការលក់ឬប្រើប្រាស់នៃទ្រព្យសកម្មស្រដៀងគ្នា ។

## មូលនិធិពាណិជ្ជកម្ម

២១ មូលនិធិពាណិជ្ជកម្ម ដែលកើតឡើងនៅក្នុងការបញ្ចូលអាជីវកម្មរួមគ្នាត្រូវបានវាស់វែងជាតម្លៃលើសនៃ (ក) លើ (ខ) ខាងក្រោមៈ

(ក) តម្លៃសរុបៈ

(១) តម្លៃតបស្នងផ្ទេរដែកវាស់វែងតាម ស.រ.ហ.អ.ក ៣ ដែល ជាទូទៅតម្រូវឱ្យប្រើតម្លៃទីផ្សារនៅថ្ងៃ ទិញ

(២) ចំនួនទឹកប្រាក់នៃភាគកម្មអប្បភាគនៅក្នុងក្រុមហ៊ុនលក់ដែលបានទទួលស្គាល់តាម ស.រ.ហ.អ.ក ៣ និង

(៣) នៅក្នុងការបញ្ចូលអាជីវកម្មរួមគ្នា ដែលបានបញ្ចូលតាមដំណាក់កាល តម្លៃទីផ្សារនៅថ្ងៃទិញនៃភាគកម្មមូលនិធិដែលបាន រក្សាទុកគ្រាមុនរបស់ក្រុមហ៊ុនទិញ នៅក្នុងក្រុមហ៊ុនលក់ ។

(ខ) ចំនួនទឹកប្រាក់ថ្លៃទិញសុទ្ធនៃទ្រព្យសកម្មអាចកំណត់បាន ដែលបានទិញ និងបំណុលដែលបានកើត ឡើងត្រូវបានវាស់វែងតាម ស.រ.ហ. អ.ក ៣

អាជ្ញាធរពន្ធដារមួយចំនួនមិនអនុញ្ញាតឱ្យកាត់ចេញនៅក្នុងតម្លៃពិតគណនេយ្យនៃមូលនិធិពាណិជ្ជកម្ម ជាចំណាយដែលអាចកាត់កងបានទេនៅក្នុងកំណត់ប្រាក់ចំណេញជាប់ពន្ធ។ លើសពីនេះ នៅក្នុងប្រទេសខ្លះថ្លៃដើមនៃមូលនិធិពាណិជ្ជកម្មជារឿយៗមិនមានកាត់កងបានទេពេលដែលក្រុមហ៊ុនបុត្រសម្ព័ន្ធលក់ អាជីវកម្មរបស់ខ្លួន ។ នៅក្នុងប្រទេសខ្លះទៀត មូលនិធិពាណិជ្ជកម្មមានមូលដ្ឋានពន្ធ ស្មើនឹងសូន្យ។ ភាពខុសគ្នារវាងតម្លៃពិតគណនេយ្យនៃមូលនិធិពាណិជ្ជកម្ម និងមូលដ្ឋានពន្ធសូន្យ គឺជាភាពខុសគ្នាជាប់ពន្ធបណ្តោះអាសន្ន ។ ប៉ុន្តែ ស្តង់ដារនេះមិនអនុញ្ញាតឱ្យមានការទទួលស្គាល់បំណុលពន្ធពន្យារដែលមានពីព្រោះ មូលនិធិពាណិជ្ជកម្មត្រូវបានវាស់វែងជាតម្លៃសំណល់ ហើយការទទួលស្គាល់បំណុលពន្ធពន្យារនឹងអាចបង្កើតតម្លៃពិតគណនេយ្យនៃមូលនិធិពាណិជ្ជកម្ម ។

២១ក ការកាត់ចេញពេលក្រោយ នៅក្នុងបំណុលពន្ធពន្យារ ដែលមិនត្រូវបានទទួលស្គាល់ ពីព្រោះវាកើតឡើងពីការ ទទួលស្គាល់ដំបូងនៃមូលនិធិពា-ណិជ្ជកម្ម ក៏ត្រូវបានចាត់ទុកជាកើតឡើងពីការទទួលស្គាល់លើកដំបូងនៃមូល និធិពាណិជ្ជកម្ម និងដូច្នេះមិនត្រូវបានទទួលស្គាល់តាម កថាខណ្ឌ ១៥(ក) ទេ ។ ឧទាហរណ៍ ប្រសិនបើនៅក្នុងការបញ្ចូល អាជីវកម្មរួមគ្នា អង្គភាពទទួលស្គាល់មូលនិធិពាណិជ្ជកម្ម ១០០ ដែលមានមូលដ្ឋានពន្ធសូន្យកថាខណ្ឌ ១៥ (ក) ហាមឃាត់អង្គភាពពីការទទួលស្គាល់បំណុលពន្ធពន្យារ។ ប្រសិនបើអង្គភាពនៅឆ្នាំបន្ទាប់ទទួលស្គាល់ការខាតពីការធ្លាក់

ចុះតម្លៃ ២០ សម្រាប់មូលនិធិពាណិជ្ជកម្ម នោះចំនួនទឹកប្រាក់នៃភាពខុសគ្នាបណ្តោះអាសន្នជាប់ពន្ធ ទាក់ទិននឹងមូលនិធិពាណិជ្ជកម្មត្រូវបានកាត់បន្ថយពី១០០ មកត្រឹម៨០ ជាមួយនឹងការធ្លាក់តម្លៃនៃបំណុលពន្ធពន្យារដែលមិនបានទទួលស្គាល់។ ការធ្លាក់ចុះនៅក្នុងតម្លៃបំណុលពន្ធពន្យារមិនទទួលស្គាល់នោះក៏ត្រូវបានចាត់ទុកថាមានជាប់ពាក់ព័ន្ធនឹងការទទួលស្គាល់មូលនិធិលើកដំបូង ដូច្នេះហើយ ត្រូវបានហាមឃាត់ពីការទទួលស្គាល់តាម កថាខណ្ឌ១៥ (ក) ។

២១ខ ប៉ុន្តែ បំណុលពន្ធពន្យារសម្រាប់ភាពខុសគ្នាបណ្តោះអាសន្នជាប់ពន្ធទាក់ទិន នឹងមូលនិធិពាណិជ្ជកម្ម ត្រូវបានទទួលស្គាល់រហូតដល់ភាពខុសគ្នាទាំង នោះ មុនកើតឡើងពីការទទួលស្គាល់លើកដំបូងនៃមូលនិធិពាណិជ្ជកម្ម។ ឧទាហរណ៍ ប្រសិនបើការបញ្ចូលអាជីវកម្មរួមគ្នាអង្គភាពទទួលស្គាល់ មូលនិធិពាណិជ្ជកម្ម ១០០ ដែលអាចកាត់កងបានសម្រាប់គោលបំណង ពន្ធតាមអត្រា២០%ក្នុងមួយឆ្នាំដោយចាប់ផ្តើមនៅក្នុងឆ្នាំទិញ មូលដ្ឋាន ពន្ធនៃ មូលនិធិពាណិជ្ជកម្ម ១០០ នៅពេលទទួលស្គាល់លើកដំបូង និង ៨០ នៅចុងគ្រានៃការទិញ។ ប្រសិនបើតម្លៃពិតគណនេយ្យនៃមូលនិធិ ពាណិជ្ជកម្ម នៅចុងឆ្នាំនៃការទិញនៅ ១០០ ដដែលនោះ ភាពខុសគ្នា បណ្តោះអាសន្នជាប់ពន្ធ ២០ កើតឡើងនៅចុងឆ្នាំនោះ ។ ដោយសារតែ ភាពខុសគ្នាបណ្តោះអាសន្នជាប់ពន្ធ មិនពាក់ព័ន្ធនឹងការទទួលស្គាល់លើក ដំបូងនៃមូលនិធិពាណិជ្ជកម្ម ដូច្នេះបំណុលពន្ធពន្យារ ដែលមានត្រូវបានទទួលស្គាល់ ។

ការទទួលស្គាល់លើកដំបូងនៃទ្រព្យសកម្ម ឬ បំណុល

២២ ភាពខុសគ្នាបណ្តោះអាសន្នអាចកើតឡើង នៅពេលទទួលស្គាល់លើកដំបូងនៃទ្រព្យសកម្ម ឬបំណុល ជាឧទាហរណ៍ ប្រសិនបើមួយផ្នែក ឬផ្នែកទាំងអស់នៃថ្លៃដើមទ្រព្យសកម្ម នឹងមិនអាចកាត់កងបានសម្រាប់គោលបំណង ។ វិធីសាស្ត្រសម្រាប់ធ្វើគណនេយ្យកម្មលើភាពខុសគ្នាបណ្តោះអាសន្នផ្អែកលើ ប្រភេទប្រតិបត្តិការដែលនាំដល់ការទទួលស្គាល់លើកដំបូងនៃទ្រព្យសកម្ម ឬ បំណុលៈ

(ក) ក្នុងការបញ្ចូលអាជីវកម្មរួមគ្នា អង្គភាព ទទួលស្គាល់បំណុលពន្ធពន្យារ ឬទ្រព្យសកម្មពន្ធពន្យារណាមួយ ហើយការបញ្ចូលអាជីវកម្មរួមគ្នា នេះនឹងប៉ះពាល់ដល់ចំនួនទឹកប្រាក់មូលនិធិ-ពាណិជ្ជកម្ម ឬចំណេញពីការទិញបានថោក ដែលអង្គភាពទទួលស្គាល់ (សូមមើលកថាខណ្ឌ ១៩)

(ខ) ប្រសិនបើប្រតិបត្តិការប៉ះពាល់ដល់ប្រាក់ចំណេញគណនេយ្យ ឬប្រាក់ចំណេញជាប់ពន្ធ អង្គភាពមួយទទួលស្គាល់បំណុលពន្ធពន្យារ ឬទ្រព្យសកម្មណាមួយ ហើយទទួលស្គាល់ ចំណាយឬចំណូលពន្ធពន្យារ ដែលកើតមាន នៅក្នុងរបាយការណ៍ចំណេញ ឬ ខាត (សូមមើលកថាខណ្ឌ៥៩)

(គ) ប្រសិនប្រតិបត្តិការប៉ះពាល់ដល់ប្រាក់ចំណេញគណនេយ្យឬប្រាក់ចំណេញជាប់ពន្ធ អង្គភាពមួយទទួលស្គាល់បំណុល ឬ ទ្រព្យសកម្មពន្ធពន្យារ ហើយទទួលស្គាល់ចំណាយ ឬចំណូលពន្ធពន្យារដែលកើតមាននៅក្នុងរបាយការណ៍ចំណេញ ឬ ខាត (សូមមើលកថាខណ្ឌ៥៩)

(ឃ) ប្រសិនបើប្រតិបត្តិការមិនមែនជាការបញ្ចូលអាជីវកម្មរួមគ្នា ហើយមិនប៉ះពាល់ដល់ប្រាក់ចំណេញគណនេយ្យ និងមិនប៉ះពាល់ដល់ប្រាក់ចំណេញជាប់ពន្ធ នៅពេលអវត្តមានការលើកលែងដែលបានផ្តល់នៅក្នុង កថាខណ្ឌ ១៥ និង២៤ អង្គភាពគួរទទួលស្គាល់បំណុល ឬទ្រព្យសកម្មពន្ធពន្យារដែលកើតមាន និងកែសំរួលតម្លៃពិតគណនេយ្យនៃទ្រព្យសកម្ម ឬបំណុលតាមចំនួនទឹកប្រាក់ដូចគ្នា ។ ការកែសំរួលទាំងនេះ អាចធ្វើឱ្យរបាយការណ៍ហិរញ្ញវត្ថុមានតម្លាភាពតិច ។ ដូច្នេះ ស្តង់ដារនេះមិនអនុញ្ញាត ឱ្យអង្គភាពទទួលស្គាល់បំណុល ឬទ្រព្យសកម្មពន្ធពន្ធ ដែលកើតមាននៅពេលទទួលស្គាល់លើកដំបូង ឬឆ្នាំបន្តបន្ទាប់ (សូមមើលឧទាហរណ៍ខាងក្រោម)។ លើសពីនេះទៅទៀត អង្គភាពមួយមិនទទួលស្គាល់ការប្រែប្រួលនៅឆ្នាំបន្តបន្ទាប់ នៅក្នុងបំណុល ឬទ្រព្យសកម្មពន្ធពន្យារ មិនបានទទួលស្គាល់ខណៈពេលដែលទ្រព្យសកម្មត្រូវបានដករំលស់ ។

**ឧទាហរណ៍ពន្យល់បង្ហាញកថាខណ្ឌ ២២(គ)**

អង្គភាពមួយមានបំណងដើម្បីប្រើប្រាស់ទ្រព្យសកម្មមួយដែលមានថ្លៃដើម ១.០០០ ពេញអាយុកាល៥ ឆ្នាំ និងក្រោយមកលក់ចោលទ្រព្យសកម្មនោះ ដោយមិនមានតម្លៃកាកសំណល់ទេ។ អត្រាគឺ៤០%។ រំលស់នៃទ្រព្យសកម្មមិនអាចកាត់កងសម្រាប់គោលបំណងពន្ធបានទេ។ នៅពេលលក់ចំណេញមូលធន មិនត្រូវបានជាប់ពន្ធទេ ហើយការខាតមូលធនក៏មិនអាចកាត់កងបានដែរ។

*ខណៈពេលដែលអង្គភាពទទួលបានមកវិញនូវតម្លៃពិតគណនេយ្យនៃទ្រព្យសកម្ម អង្គភាពនឹងរកបាន ចំណូលជាប់ពន្ធ ១.០០០ និង បង់ពន្ធ ៤០០។ អង្គភាពមិនទទួលស្គាល់បំណុលពន្ធពន្យារ ៤០០ ទេ ពីព្រោះពន្ធពន្យារកើត ចេញពីការទទួលស្គាល់ទ្រព្យសកម្ម។*

*នៅឆ្នាំបន្តបន្ទាប់ តម្លៃពិតគណនេយ្យនៃទ្រព្យសកម្ម គឺ មានតម្លៃ ៨០០។ នៅក្នុងរកបានចំណូលជាប់ពន្ធ៨០០ អង្គភាពនឹងបង់ពន្ធ ៣២០។ អង្គភាពមិនទទួលស្គាល់បំណុលពន្ធពន្យារ ៣២០ ពីព្រោះបំណុលពន្ធពន្យារកើតឡើងពីការទទួលស្គាល់ទ្រព្យសកម្មលើកដំបូង។*

២៣ ដោយអនុលោមតាម ស.គ.អ.ក ៣២ *ឧបករណ៍ហិរញ្ញវត្ថុៈ ការបង្ហាញ* ក្រុមហ៊ុនបោះផ្សាយឧបករណ៍ហិរញ្ញវត្ថុផ្គួប (ឧទាហរណ៍ សញ្ញាបណ្ណអាចបំលែងបាន ) ចាត់ថ្នាក់សមាសធាតុរបស់ឧបករណ៍បំណុលជាបំណុល និងសមាសធាតុមូលនិធិជាមូលនិធិ ។ នៅក្នុងប្រទេសខ្លះ មូលដ្ឋានពន្ធនៃសមាសធាតុបំណុលនៅ ពេលទទួលស្គាល់លើកដំបូងស្មើនឹងតម្លៃពិត

គណនេយ្យដំបូង នៃផលបូកនៃសមាសធាតុបំណុល និងសមាសធាតុមូលនិធិ ។ ភាពខុសគ្នាបណ្តោះ អាសន្នជាប់ពន្ធ កើតពីការទទួលស្គាល់លើកដំបូងនៃសមាសធាតុមូលនិធិដាច់ដោយឡែកពីសមាសធាតុបំណុល។ ដូច្នេះ ការលើកលែងដែលកំ ណត់នៅក្នុង កថាខណ្ឌ១៥ (ខ) មិនអនុវត្តទេ។ ជាវិបាក អង្គភាពមួយទទួលស្គាល់បំណុលពន្ធពន្យារ ដោយអនុលោមតាមកថាខណ្ឌ៦១ក ពន្ធពន្យារត្រូវគិតដោយផ្ទាល់ទៅតម្លៃពិតគណនេយ្យនៃសមាសធាតុមូលនិធិ។ អនុលោមតាមកថាខណ្ឌ ៥៨ ការផ្លាស់ប្តូរបន្តបន្ទាប់ នៅក្នុងបំណុលពន្ធ ពន្យារត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ចំណេញ ឬខាតជាចំណាយ (ចំណូល) ពន្ធពន្យារ ។

**ភាពខុសគ្នាបណ្តោះអាសន្នអាចកាត់កងបាន**

**២៤ ទ្រព្យសកម្មពន្ធពន្យារត្រូវបានទទួលស្គាល់សម្រាប់គ្រប់ភាពខុសគ្នាបណ្តោះអាសន្នអាចកាត់កងបានរហូតដល់វាទំនងថាប្រាក់ចំណេញជាប់ពន្ធមានកើតមានទល់នឹងភាពខុសគ្នាបណ្តោះអាសន្នអាចកាត់កងបានត្រូវបានប្រើប្រាស់ លើកលែងតែទ្រព្យសកម្មពន្ធពន្យារកើតពីការទទួលស្គាល់លើកដំបូងនៃទ្រព្យសកម្ម ឬ បំណុល នៅក្នុងប្រតិបត្តិការដែលៈ**

(ក) **មិនមែនជាការបញ្ចូលអាជីវកម្មរួមគ្នា និង**

(ខ) **នៅពេលមានប្រតិបត្តិការ មិនប៉ះពាល់ទាំងប្រាក់ចំណេញគណនេយ្យ និង ប្រាក់ចំណេញគិតពន្ធ ។**

**ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ភាពខុសគ្នាបណ្តោះអាសន្នដែលជាប់ពាក់ពន្ធនៅក្នុងក្រុមហ៊ុនបុត្រសម្ព័ន្ធ សាខា និងក្រុមញ្ញាតិសម្ព័ន្ធ និង ភាគកម្មនៅក្នុង ក្រុមហ៊ុនរួមទុន ទ្រព្យសកម្មពន្ធពន្យារត្រូវបានទទួលស្គាល់ ដោយអនុលោមតាមកថាខណ្ឌ ៤៤ ។**

២៥ វាមានការពាក់ព័ន្ធ នៅក្នុងការទទួលស្គាល់បំណុល ដែលតម្លៃពិតគណនេយ្យនឹងត្រូវបានទូទាត់ក្នុងគ្រាអនាគតតាមរយៈការហូរចេញពីអង្គភាពនូវធនធាន ដែលមានអត្ថប្រយោជន៍សេដ្ឋកិច្ច ។ នៅពេលដែលធនធានហូរចេញពីអង្គភាពផ្នែក ឬចំនួនទឹកប្រាក់ទាំងអស់អាចកាត់កងបាននៅក្នុងការកំណត់ប្រាក់ចំណេញជាប់ពន្ធ នៃគ្រាមួយយឺតជាងគ្រាដែលបំណុលត្រូវបានទទួលស្គាល់។ នៅក្នុងករណីបែបនេះ ភាពខុសគ្នាបណ្តោះអាសន្នកើតឡើងរវាងតម្លៃពិតគណនេយ្យនៃបំណុល និងមូលដ្ឋានពន្ធ ។ ដូច្នេះទ្រព្យសកម្មពន្ធពន្យារកើតឡើងទាក់ទងនឹងពន្ធលើប្រាក់ចំណូល ដែលនឹងអាចទទួលបានមកវិញនៅក្នុងគ្រាអនាគតពេល ដែលផ្នែកនៃបំណុលត្រូវបានអនុញ្ញាតឱ្យ មានការកាត់កងនៅក្នុង ការកំណត់ប្រាក់ចំណេញជាប់ពន្ធ។ ស្រដៀងគ្នានេះដែរ ប្រសិនបើតម្លៃពិតគណនេយ្យនៃទ្រព្យសកម្មតូចជាងមូលដ្ឋានពន្ធ នោះភាពខុសគ្នាបណ្តោះអាសន្នផ្តល់ការកើនឡើងចំពោះទ្រព្យសកម្មពន្ធពន្យារទាក់ទងនឹងពន្ធលើប្រាក់ចំណូលដែលនឹងអាចទទួលបានមក វិញនៅក្នុងគ្រាអនាគត ។

**ឧទាហរណ៍**

អង្គភាពមួយទទួលស្គាល់បំណុល១០០ សម្រាប់ចំណាយបង្គរដែលធានាលើផលិតផល។ សម្រាប់គោលបំណងពន្ធ ចំណាយធានាលើផលិតផលនឹងមិន អាចកាត់កង បានរហូតល់អង្គភាពបានចំណាយប្រាក់លើការទាមទារនោះ។ អត្រាពន្ធគឺ ២៥%។

*មូលដ្ឋានពន្ធនៃបំណុលគឺស្មើនឹងសូន្យ (តម្លៃពិតគណនេយ្យ ១០០ ដកនឹងចំនួនទឹកប្រាក់ ដែលអាចកាត់កងបានសម្រាប់គោលបំណងពន្ធ ទាក់ទងនឹងបំណុលនោះ នៅក្នុងគ្រាអនាគត)។ នៅក្នុងការទូទាត់បំណុលសម្រាប់តម្លៃពិតគណនេយ្យ អង្គភាពនឹងកាត់បន្ថយប្រាក់ចំណេញជាប់ពន្ធនាពេលអនាគតដោយចំនួនទឹកប្រាក់ ១០០ និង ជាវិបាក កាត់បន្ថយការទូទាត់ ពន្ធអនាគត ២៥ (១០០ x២៥%)។ ភាពខុសគ្នាបណ្តោះអាសន្ន រវាងតម្លៃពិតគណនេយ្យ ១០០ និងមូលដ្ឋានពន្ធសូន្យ គឺជាភាពខុសគ្នាបណ្តោះអាសន្ន ដែលអាចកាត់កងបាន ១០០។ ដូច្នេះ អង្គភាពទទួលស្គាល់ជាទ្រព្យសកម្មពន្ធពន្យារ ២៥ (១០០ x ២៥%) ដោយដឹងថា វាទំនងថាអង្គភាពនឹងរកបានប្រាក់ចំណេញជាប់ពន្ធគ្រប់គ្រាន់នៅក្នុងគ្រាអនាគតដើម្បីទទួលបានផលប្រយោជន៍ពីការកាត់បន្ថយនៅក្នុងការទូទាត់ប្រាក់ពន្ធ ។*

២៦ ខាងក្រោមនេះជាឧទាហរណ៍នៃភាពខុសគ្នាបណ្តោះអាសន្ន ដែលអាចកាត់កងបានដែលកើតឡើងនៅក្នុង ទ្រព្យសកម្មពន្ធពន្យារៈ

(ក) ចំណាយលើអត្ថប្រយោជន៍ចូលនិវត្តន៍ អាចត្រូវបានកាត់កងនៅក្នុងការកំណត់ប្រាក់ចំណេញគណនេយ្យខណៈពេលដែលសេវាត្រូវបានផ្តល់ដោយនយោជិក ប៉ុន្តែត្រូវបានកាត់កងនៅក្នុងការកំណត់ប្រាក់ចំណេញជាប់ពន្ធ ពេលវិភាគទាន ត្រូវបានបង់ទៅចូលមូលនិធិដោយអង្គភាព ឬ ពេលអត្ថប្រយោជន៍ចូលនិវត្តន៍ត្រូវបានបង់ដោយអង្គភាព ។ ភាពខុសគ្នាបណ្តោះអាសន្នកើតឡើងរវាងតម្លៃពិតគណនេយ្យនៃបំណុល និងមូលដ្ឋានពន្ធរបស់វាមូលដ្ឋានពន្ធនៃបំណុលជាធម្មតាស្មើនឹងសូន្យ ។ ភាពខុសគ្នាបណ្តោះអាសន្នអាចកាត់កងបាននាំ ឱ្យមានទ្រព្យសកម្មពន្ធពន្យារពីព្រោះអត្ថប្រយោជន៍សេដ្ឋកិច្ចនឹង ហូរចូលមកអង្គភាពក្នុងទម្រង់ នៃការកាត់កងពីប្រាក់ចំណេញជាប់ ពន្ធពេល វិភាគទាន ឬ អត្ថប្រយោជន៍ចូលនិវត្តន៍ត្រូវបានបង់

(ខ) ចំណាយស្រាវជ្រាវ ត្រូវបានទទួលស្គាល់ជាចំណាយ ក្នុងការកំណត់ប្រាក់ចំណេញគណនេយ្យនៅក្នុងគ្រា ដែលចំណាយទាំងនោះកើតឡើង ប៉ុន្តែអាចមិនត្រូវបានអនុញ្ញាតជាការកាត់កងក្នុងការកំណត់ប្រាក់ចំណេញជាប់ពន្ធ (ប្រាក់ខាតពន្ធ) រហូតដល់គ្រាក្រោយទៀត។ ភាពខុសគ្នារវាងមូលដ្ឋានពន្ធ ចំណាយស្រាវជ្រាវ ជាចំនួនទឹកប្រាក់ដែលអាជ្ញាធរពន្ធដារនឹងអនុញ្ញាតជាការកាត់កងនៅក្នុងគ្រាអនាគត និង តម្លៃពិតគណនេយ្យស្មើសូន្យ គឺជាភាពខុសគ្នាបណ្តោះអាសន្នដែលអាចកាត់កងដែលនាំឱ្យមានទ្រព្យសកម្មពន្ធពន្យារ ។

(គ) ជាមួយនឹងការលើកលែងដែលមានកម្រិត អង្គភាពមួយទទួលស្គាល់ទ្រព្យសកម្មអាចកំណត់បានដែលបានទិញ និងបំណុល ដែលមានកើតមាននៅក្នុងការបញ្ចូលអាជីវកម្មតាមតម្លៃទីផ្សារនៃទ្រព្យសកម្ម និង បំណុលនៅថ្ងៃទិញ។ នៅពេលបំណុលត្រូវបានទទួលស្គាល់នៅថ្ងៃទិញ ប៉ុន្តែចំណាយពាក់ព័ន្ធមិន ត្រូវបានកាត់កងនៅក្នុងប្រាក់ចំណេញជាប់ពន្ធរ ហូតដល់គ្រាក្រោយ ភាពខុសគ្នាបណ្តោះអាសន្នអាចកាត់ កងបានកើតឡើងដែលនាំឱ្យមានទ្រព្យសកម្មពន្ធពន្យារ។ ទ្រព្យសកម្មពន្ធពន្យារក៏កើតឡើងនៅពេលតម្លៃទីផ្សារនៃទ្រព្យសកម្មអាចកំណត់បានដែលបានទិញតូចជាងមូលដ្ឋានពន្ធ។ នៅក្នុងករណីទាំងពីរនេះ ទ្រព្យសកម្មពន្ធពន្យារប៉ះពាល់ដល់ មូលនិធិពាណិជ្ជកម្ម (សូមមើលកថាខណ្ឌ ៦៦) និង

(ឃ) ទ្រព្យសកម្មជាក់លាក់អាចត្រូវបានកត់ត្រាតាមតម្លៃទីផ្សារ ឬអាចត្រូវបានវាយតម្លៃឡើងវិញ ដោយពុំមានការការសំរួលសមមូល ដែលកំពុងធ្វើឡើងសម្រាប់គោលបំណងពន្ធ (សូមមើលកថាខណ្ឌ ២០) ។ ភាពខុសគ្នាបណ្តោះអាសន្នអាចកាត់កងកើតឡើងប្រសិនបើមូលដ្ឋានពន្ធនៃទ្រព្យសកម្មលើសពីតម្លៃពិតគណនេយ្យ ។

២៧ ការត្រឡប់វិញនៃភាពខុសគ្នាបណ្តោះអាសន្ន អាចកាត់កងបាននាំឱ្យមានការកាត់កងនៅក្នុងការកំណត់ប្រាក់ ចំណេញជាប់ពន្ធនៃគ្រាអនាគត ។ ប៉ុន្តែអត្ថប្រយោជន៍សេដ្ឋកិច្ចនៅក្នុងទម្រង់កាត់បន្ថយនៅក្នុងការបង់ពន្ធនឹងហូរមកកាន់អង្គភាពតែប៉ុណ្ណោះប្រសិនបើអង្គភាពរកបាននូវប្រាក់ចំណេញជាប់ពន្ធគ្រប់គ្រាន់ទល់នឹងការកាត់កងណាមួយអាចត្រូវបានទូទាត់។ ដូច្នេះ

អង្គភាពមួយ ទទួលស្គាល់ទ្រព្យសកម្មពន្ធពន្យារ តែពេលដែលវាទំនងថាប្រាក់ចំណេញជាប់ពន្ធ នឹងកើតមានទល់នឹង ភាពខុសគ្នាបណ្ដោះអាសន្នអាចកាត់កងបានអាចត្រូវបានប្រើ ។

២៨ វាទំនងថាប្រាក់ចំណេញជាប់ពន្ធនឹងអាចមានទល់នឹងភាពខុសគ្នាបណ្ដោះអាសន្នអាចកាត់កងបានអាចត្រូវបានប្រើនៅពេលមានភាពខុសគ្នាបណ្ដោះអាសន្នជាប់ពន្ធដែលទាក់ទងនឹងអាជ្ញាធរពន្ធដារដូចគ្នា និងអង្គភាពជាប់ពន្ធដូចគ្នាដែលអាចត្រូវបានរពឹងថានឹងត្រឡប់វិញៈ

(ក) នៅក្នុងគ្រាដូចគ្នា ជាការត្រឡប់វិញបានរំពឹងទុកនៃ ភាពខុសគ្នាជាបណ្ដោះអាសន្នអាចកាត់កងបាន ឬ

(ខ) នៅក្នុងគ្រាចំពោះប្រាក់ខាតជាប់ពន្ធដែលកើតពីទ្រព្យសកម្មពន្ធពន្យារ អាចត្រូវបានកត់ត្រាត្រឡប់ក្រោយ ឬកត់ត្រាទៅពេលខាងមុខ ។

នៅក្នុងកាលៈទេសៈបែបនេះ ទ្រព្យសកម្មពន្ធពន្យារត្រូវបានទទួលស្គាល់នៅក្នុងគ្រាដែលភាពខុសគ្នាបណ្ដោះ អាសន្នអាចកាត់កងបានកើតឡើង។

២៩ នៅពេលដែល ភាពខុសគ្នាបណ្ដោះអាសន្នជាប់ពន្ធមិនគ្រប់គ្រាន់ ដែលទាក់ទងនឹងអាជ្ញារធរពន្ធដារ និងអង្គភាពជាប់ពន្ធដូចគ្នា នោះទ្រព្យសកម្មពន្ធ ពន្យារត្រូវបានទទួលស្គាល់រហូតដល់ៈ

វាទំនងថា អង្គភាពនឹងមានប្រាក់ចំណេញជាប់ពន្ធគ្រប់គ្រាន់ ទាក់ទងនឹងអាជ្ញាធរពន្ធដារនិងអង្គភាពជាប់ពន្ធ នៅក្នុងគ្រាដូចគ្នាជាការត្រឡប់ក្រោយនៃភាពខុសគ្នាបណ្ដោះអាសន្នអាចកាត់កងបាន (ឬនៅក្នុងគ្រាចំពោះ ប្រាក់

ខាតជាប់ពន្ធ ដែលកើតឡើងពីទ្រព្យសកម្មពន្ធពន្យារ អាចត្រូវបានកត់ត្រាត្រឡប់ក្រោយ ឬទៅមុខ )។ នៅក្នុងការវាយតម្លៃថាអង្គភាពនឹងមានប្រាក់ចំណេញជាប់ពន្ធគ្រប់គ្រាន់នៅក្នុងពេលអនាគត ឬអត់ អង្គភាព មិនអើពើនឹងទឹកប្រាក់ជាប់ពន្ធដែលកើតឡើងពីភាពខុសគ្នាបណ្ដោះអាសន្នអាចកាត់កងបានដែលត្រូវបានរំពឹងថានឹងបង្កើតមាននៅក្នុងគ្រាអនាគត ពីព្រោះទ្រព្យសកម្មពន្ធពន្យារ ដែលកើតឡើងពីភាពខុសគ្នាបណ្ដោះអាសន្ន អាចកាត់កងបាននឹងតម្រូវឲ្យមានប្រាក់ចំណេញជាប់ពន្ធពេលអនាគតដើម្បីប្រើប្រាស់ ឬ

(ខ) ឱកាសនៃការធ្វើផែនការពន្ធកើតមានចំពោះអង្គភាពដែលនឹងបង្កើត ឲ្យប្រាក់ចំណេញជាប់ពន្ធនៅក្នុងគ្រា សមស្របមួយ។

៣០ ឱកាសនៃការធ្វើផែនការពន្ធ គឺជាសកម្មភាពដែលអង្គភាពនឹងធ្វើ ដើម្បីបង្កើត ឬបង្កើនចំណូលជាប់ពន្ធនៅក្នុង គ្រាជាក់លាក់មួយមុនពេលអស់សុពលភាពនៃប្រាក់ខាតជាប់ពន្ធ ឬ ឥណទានពន្ធយោងបន្ត ។ ឧទាហរណ៍ នៅក្នុងប្រទេសខ្លះ ប្រាក់ចំណេញជាប់ពន្ធអាចត្រូវបានបង្កើតឡើងឬបង្កើនដោយៈ

(ក) ជ្រើសរើសដើម្បីជាប់ពន្ធចំណូលពីការប្រាក់លើមូលដ្ឋានបានទទួលសាច់ប្រាក់ ឬ មូលដ្ឋានត្រូវទទួល

(ខ) ពន្យារការទាមទារសម្រាប់ការកាត់កងជាក់លាក់ពីប្រាក់ចំណេញជាប់ពន្ធ

(គ) លក់ និងប្រហែលជាធ្វើភតិសន្យាត្រឡប់វិញ ទ្រព្យសកម្មដែលបានបង្កើនតម្លៃ ប៉ុន្តែសម្រាប់មូលដ្ឋានពន្ធមិនត្រូវបានកែសំរួលដើម្បីឆ្លុះបញ្ចាំង ពីការបង្កើនតម្លៃនោះទេ និង

(ឃ) លក់ទ្រព្យសកម្មដែលបង្កើតចំណូលមិនជាប់ពន្ធ (នៅក្នុងប្រទេសខ្លះដូចជាសញ្ញាបណ្ណរដ្ឋាភិបាល) ដើម្បីទិញការវិនិយោគផ្សេងទៀត ដែលបង្កើតចំណូលជាប់ពន្ធ

ពេលឱកាសនៃការធ្វើផែនការពន្ធបង្កើនប្រាក់ចំណេញជាប់ពន្ធពីគ្រាក្រោយទៅគ្រាមុន នោះការប្រើប្រាក់ខាតពន្ធ ឬ ឥណទានពន្ធយោងបន្តរនៅតែអាស្រ័យលើអត្ថិភាពនៃ ប្រាក់ចំណេញជាប់ពន្ធពីប្រភពជាច្រើន ជាជាងភាពខុសគ្នាបណ្តោះអាសន្នដែលកកើតឡើងនាពេលអនាគត។

៣១ នៅពេលដែលអង្គភាពមានប្រវត្តិខាតនាពេលថ្មីៗនេះ អង្គភាពពិចារណាពីសេចក្តីណែនាំនៅក្នុងកថាខណ្ឌ ៣៥ និង ៣៦ ។

៣២ លុបចោល

## មូលនិធិពាណិជ្ជកម្ម

៣២ក ប្រសិនបើតម្លៃពិតគណនេយ្យនៃមូលនិធិពាណិជ្ជកម្ម ដែលកើតឡើងនៅក្នុងការបញ្ចូលអាជីវកម្មរួមតិចជាង មូលដ្ឋានពន្ធ នោះភាពខុសគ្នាផ្តល់ការកើនឡើងចំពោះទ្រព្យសកម្មពន្ធពន្យារ។ ទ្រព្យសកម្មពន្ធពន្យារ ដែលកើតឡើងពីការទទួលស្គាល់ មូលនិធិពាណិជ្ជកម្មលើកដំបូង ត្រូវបានគេទទួលស្គាល់ជាផ្នែកមួយនៃការធ្វើ គណនេយ្យកម្មសម្រាប់ការបញ្ចូលអាជីវកម្មរួមគ្នារហូតដល់វាទំនងថាប្រាក់ចំណេញជាប់ពន្ធនឹងមានទល់នឹង ភាពខុសគ្នាបណ្តោះអាសន្នអាចកាត់កងបានអាចត្រូវបានប្រើ។

## ការទទួលស្គាល់ទ្រព្យសកម្ម ឬ បំណុលលើកដំបូង

៣៣ ករណីមួយនៅពេលដែល ទ្រព្យសកម្មពន្ធពន្យារកើតឡើង នៅពេលទទួលស្គាល់លើកដំបូងនៃទ្រព្យសកម្ម គឺនៅពេលដែល ការផ្តល់អំណោយរដ្ឋាភិបាលមិនជាប់ពន្ធដែលទាក់ទងនឹងទ្រព្យសកម្មត្រូវបានកាត់កងដើម្បីទទួលបានតម្លៃពិតគណនេយ្យនៃទ្រព្យសកម្ម ប៉ុន្តែសម្រាប់គោលបំណងពន្ធ មិនត្រូវបានកាត់កងពីចំនួនទឹក ប្រាក់នៃទ្រព្យសកម្មអាចដករំលស់បាន (អាចនិយាយម្យ៉ាងទៀត ជាមូលដ្ឋានពន្ធ) តម្លៃពិតគណនេយ្យនៃទ្រព្យ សកម្ម គឺតិចជាងមូលដ្ឋានពន្ធ និង តម្លៃនឹងផ្តល់ការកើនឡើងចំពោះភាព ខុសគ្នាបណ្តោះអាសន្នអាចកាត់កងបាន។ អំណាយរបស់រដ្ឋាភិបាលក៏អាច ត្រូវបានបង្កើតជាចំណូលពន្យារនៅក្នុងករណីដែលភាពខុសគ្នារវាង ចំណូលពន្យារ និងមូលដ្ឋានពន្ធស្មើសូន្យ គឺជាភាពខុសគ្នាបណ្តោះអាសន្ន អាចកាត់កងបាន។ វិធីសាស្រ្ត បង្ហាញណាមួយក៏ដោយ ដែលអង្គភាព មួយប្រើប្រាស់ អង្គភាពមិនទទួលស្គាល់ពីទ្រព្យសកម្មពន្ធពន្យារ សម្រាប់ហេតុផលដែលចែងនៅក្នុងកថាខណ្ឌ ២២ ។

## *ប្រាក់ខាតពន្ធមិនបានប្រើ និង ឥណទានពន្ធមិនបានប្រើ*

៣៤ **ទ្រព្យសកម្មពន្ធពន្យារត្រូវបានទទួលស្គាល់សម្រាប់ការយោងបន្ត នៃប្រាក់ខាតពន្ធមិនបានប្រើ និងឥណទានពន្ធ មិនបានប្រើរហូតដល់វាទំនងថាប្រាក់ចំណេញជាប់ពន្ធអនាគតនឹងមានទល់នឹងប្រាក់ខាតពន្ធមិនបានប្រើ និង ឥណទានពន្ធមិនបានប្រើអាចត្រូវបានប្រើ។**

៣៥ លក្ខណៈវិនិច្ឆ័យសម្រាប់ទទួលស្គាល់ទ្រព្យសកម្មពន្ធពន្យារ ដែលកើតឡើងពីការយោងបន្តនៃប្រាក់ខាតពន្ធ និងឥណទានពន្ធមិនបានប្រើ គឺដូចគ្នានឹងលក្ខណៈវិនិច្ឆ័យសម្រាប់ទទួលស្គាល់ទ្រព្យសកម្មពន្ធពន្យារដែលកើតឡើង ពីភាពខុសគ្នាបណ្តោះអាសន្នអាចកាត់កងបាន ។ ប៉ុន្តែអត្ថិភាពនៃប្រាក់ខាតពន្ធមិនបានប្រើ គឺជាភស្តុតាងដ៏រឹងមាំ ដែលប្រាក់ចំណេញជាប់ពន្ធ អនាគតអាចមិនមាន។ ដូច្នេះ ពេលដែលអង្គភាពមួយមានប្រវត្តិខាតថ្មីៗ អង្គភាពទទួលស្គាល់ទ្រព្យសកម្មពន្ធពន្យារដែលកើតឡើងពីប្រាក់ខាតពន្ធ ឬ ឥណទានពន្ធ មិនបានប្រើរហូតដល់អង្គភាពមានភាពខុសគ្នាបណ្តោះ អាសន្នជាប់ពន្ធគ្រប់គ្រាន់ ឬក៏មានភស្តុតាងផ្សេងទៀតដែលប្រាក់ចំណេញ ជាប់ពន្ធគ្រប់គ្រាន់ នឹងមានទល់នឹងប្រាក់ខាតពន្ធ ឥណទានពន្ធមិនបាន ប្រើណាមួយអាចត្រូវបានប្រើប្រាស់ដោយអង្គភាព។ នៅក្នុងកាលៈទេសៈ បែបនេះ កថាខណ្ឌ៨២ តម្រូវឱ្យមានការលាតត្រដាងពីចំនួនទឹក ប្រាក់នៃ ទ្រព្យសកម្មពន្ធពន្យារ និងលក្ខណៈនៃភស្តុតាង ដែលគាំទ្រដល់ការទទួល ស្គាល់របស់អង្គភាព ។

៣៦ អង្គភាពពិចារណានូវលក្ខណៈវិនិច្ឆ័យ នៅក្នុងការវាយតម្លៃពីភវនីយភាពដែលប្រាក់ចំណេញជាប់ពន្ធនឹងមាន ទល់នឹងប្រាក់ខាតពន្ធមិនបានប្រើ ឬ ឥណទានមិនបានប្រើអាចត្រូវបានប្រើប្រាស់:

(ក) ថាតើអង្គភាពមានភាពខុសគ្នាបណ្តោះអាសន្នជាប់ពន្ធគ្រប់គ្រាន់ ដែលទាក់ទងនឹងអាជ្ញាធរពន្ធដារ និងអង្គភាពជាប់ពន្ធដូចគ្នា ដែលនឹងនាំឱ្យ មានទឹកប្រាក់ជាប់ពន្ធទល់នឹងប្រាក់ខាតពន្ធ មិន

បានប្រើ ឬឥណទានពន្ធ មិនបានប្រើអាចត្រូវបានប្រើប្រាស់ មុនពេលដែលពួកគេអស់សុពលភាព ឬ អត់

(ខ) ថាតើវាទំនងថាអង្គភាពនឹងមានប្រាក់ចំណេញជាប់ពន្ធមុនពេលប្រាក់ខាតពន្ធមិនបានប្រើ ឬ ឥណទានពន្ធមិនបានប្រើអស់សុពលភាព ឬអត់

(គ) ថាតើវាទំនងថា ប្រាក់ខាតពន្ធមិនបានប្រើ កើតពីមូលហេតុអាចកំណត់បានដែលមិនទំនងជាកើតឡើង ម្តងទៀត និង

(ឃ) ថាតើឱកាសនៃការធ្វើផែនការពន្ធ (សូមមើលកថាខណ្ឌ ៣០) មានចំពោះអង្គភាព ដែលនឹងបង្កើតប្រាក់ចំណេញជាប់ពន្ធ នៅក្នុងគ្រាដែលប្រាក់ខាតពន្ធមិនបានប្រើ ឬឥណទានពន្ធ មិនបានប្រើអាចត្រូវបានប្រើប្រាស់ ។

រហូតដល់វាមិនទំនងថាប្រាក់ចំណេញជាប់ពន្ធនឹងមិនមានទល់នឹងប្រាក់ខាតពន្ធមិនបានប្រើ ឬឥណទានពន្ធមិនបានប្រើអាចត្រូវបានប្រើ នោះទ្រព្យ-សកម្មពន្ធពន្យារមិនត្រូវបានប្រើទេ ។

## ការកំណត់ឡើងវិញនៃទ្រព្យសកម្មពន្ធពន្យារ

៣៧ នៅចុងគ្រារាយការណ៍នីមួយៗ អង្គភាពមួយកំណត់ឡើងវិញនូវទ្រព្យសកម្មពន្ធពន្យារដែលមិនបានទទួលស្គាល់។ អង្គភាពទទួលស្គាល់ ទ្រព្យសកម្មពន្ធពន្យារ ដែលមិនបានទទួលពីគ្រាមុនរហូតដល់វាទំនងថាប្រាក់ចំណេញជាប់ពន្ធអនាគត នឹងអនុញ្ញាតឲ្យទទួលបានមកវិញនូវ ទ្រព្យសកម្មពន្ធពន្យារ ។ ឧទាហរណ៍ ការធ្វើឲ្យប្រសើរឡើងនៅក្នុងលក្ខខណ្ឌជួញដូរ អាច

បង្កើតវាកាន់តែទំនងថា អង្គភាពនឹងអាចមានលទ្ធភាពរកប្រាក់ចំណេញជាប់ពន្ធគ្រប់គ្រាន់នៅពេលអនាគតសម្រាប់ទ្រព្យសកម្មពន្ធពន្យារដើម្បីបំពេញលក្ខណៈវិនិច្ឆ័យទទួល ស្គាល់ដែលបានកំណត់នៅក្នុងកថាខណ្ឌ ២៤ ឬ ៣៤។ ឧទាហរណ៍ផ្សេងមួយទៀតគឺនៅពេលដែលអង្គភាព មួយកំណត់ឡើងវិញនូវ ទ្រព្យសកម្មពន្ធពន្យារ នៅថ្ងៃបញ្ចូលអាជីវកម្មរួមគ្នា ឬឆ្នាំបន្តបន្ទាប់(សូមមើលកថា ខណ្ឌ៦៧ និង ៦៨)។

## ការវិនិយោគនៅក្នុងក្រុមហ៊ុនបុត្រសម្ព័ន្ធ សាខា និង ក្រុមហ៊ុនញ្ញាតិសម្ព័ន្ធ និង ភាគកម្មនៅក្នុងក្រុមហ៊ុន រួមទុន

៣៨ ភាពខុសគ្នាបណ្តោះអាសន្នកើតឡើង នៅពេលដែលតម្លៃពិតគណនេយ្យនៃការវិនិយោគនៅក្នុងក្រុមហ៊ុន បុត្រសម្ព័ន្ធ សាខា និងក្រុមហ៊ុនញ្ញាតិសម្ព័ន្ធ ឬ ភាគកម្មនៅក្នុងក្រុមហ៊ុនរួមទុន (ឲ្យឈ្មោះថា ក្រុមហ៊ុនមេ ឬភាគហ៊ុនរបស់អ្នកវិនិយោគនៃទ្រព្យសកម្មសុទ្ធរបស់ក្រុមហ៊ុនបុត្រសម្ព័ន្ធ សាខា ក្រុមហ៊ុនញ្ញាតិសម្ព័ន្ធ ឬ ក្រុមហ៊ុនរងការវិនិយោគ រួមបញ្ចូលទាំងតម្លៃពិតគណនេយ្យនៃ មូលនិធិពាណិជ្ជកម្ម) បានខុសពីមូលដ្ឋានពន្ធ (ដែលជាញឹកញ៉ាប់ជាថ្លៃដើម) នៃការវិនិយោគ ឬ ភាគកម្ម ។ ភាពខុសគ្នាបែបនេះអាចកើតឡើងនៅក្នុង កាលៈទេសៈខុសគ្នាមួយចំនួន ឧទាហរណ៍ៈ

(ក) អត្ថិភាពនៃប្រាក់ចំណេញមិនទានបែងចែករបស់ក្រុមហ៊ុនបុត្រសម្ព័ន្ធ សាខា ក្រុមហ៊ុនញ្ញាតិសម្ព័ន្ធ និង ក្រុមហ៊ុនរួមទុន

(ខ) ការប្រែប្រួលអត្រាប្តូរប្រាក់បរទេសនៅពេលដែលក្រុមហ៊ុនមេ និង ក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់គេត្រូវបានផ្អែកនៅក្នុងប្រទេសផ្សេងគ្នា និង

(គ) ការថយចុះក្នុងតម្លៃពិតគណនេយ្យនៃ ការវិនិយោគនៅក្នុងការក្រុមហ៊ុនញ្ញាតិសម្ព័ន្ធចំពោះទឹកប្រាក់អាច ទទួលបានមកវិញ ។

នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរួម ភាពខុសគ្នាបណ្តោះអាសន្នអាចខុសពីភាពខុសគ្នាបណ្តោះអាសន្ន ដែលជាប់ពាក់ព័ន្ធជាមួយការវិនិយោជកនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុដាច់ដោយឡែក របស់ក្រុមហ៊ុនមេ ប្រសិនបើក្រុមហ៊ុនមេកត់ត្រាការវិនិយោគនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុដាច់ដោយឡែកតាមថ្លៃដើមឬទឹកប្រាក់វាយតម្លៃឡើងវិញ ។

**៣៩ អង្គភាពមួយត្រូវទទួលស្គាល់បំណុលពន្ធពន្យារសម្រាប់ភាពខុសគ្នាបណ្តោះអាសន្នជាប់ពន្ធទាំងអស់ដែល ជាប់ទាក់ទងនឹងការវិនិយោគនៅក្នុងក្រុមហ៊ុនបុត្រសម្ព័ន្ធ សាខា ក្រុមហ៊ុនញ្ញាតិសម្ព័ន្ធ និង ភាគកម្មនៅក្នុងក្រុមហ៊ុនរួមទុន លើកលែងរហូតដល់លក្ខខណ្ឌទាំងពីរខាងក្រោមត្រូវបានបានបំពេញ:**

(ក) ក្រុមហ៊ុនមេ អ្នកវិនិយោគ ឬក្រុមហ៊ុនរួមទុនអាចគ្រប់គ្រងពេលវេលានៃការត្រឡប់វិញនៃភាពខុសគ្នា បណ្តោះអាសន្ន និង

(ខ) វាទំនងថាភាពខុសគ្នាបណ្តោះអាសន្ននឹងមិនត្រឡប់វិញនៅក្នុងពេលអនាគតអាចប៉ាន់ស្មានបាននោះទេ

៤០ ខណៈពេលដែល ក្រុមហ៊ុនមេគ្រប់គ្រង គោនយោបាយភាគលាភរបស់ក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ខ្លួន នោះក្រុមហ៊ុនមេអាចគ្រប់គ្រងពីពេលវេលានៃការត្រឡប់វិញនៃភាពខុសគ្នាបណ្តោះអាសន្នដែលជាប់ទាក់ទងនឹងជាមួនឹងការវិនិយោគ (រួមបញ្ចូលភាពខុសគ្នាបណ្តោះអាសន្ន ដែលកើតឡើងមិនគ្រាន់តែពីប្រាក់ចំណេញមិនទាន់បែងចែកនោះទេ ប៉ុន្តែថែមទាំងពីភាពខុសគ្នាការប្រែសំរួលអត្រាប្តូរប្រាក់បរទេស) ។ លើសពីនេះទៅទៀតជារឿយៗវានឹងមិនអាចប្រើបានដើម្បីកំណត់ពីទឹកប្រាក់ពន្ធលើប្រាក់ចំណូលដែល ត្រូវបង់នៅពេលភាពខុសគ្នាបណ្តោះអាសន្នត្រឡប់វិញ ។ ដូច្នេះនៅពេលដែលក្រុមហ៊ុនមេបានកំណត់ថា ប្រាក់ចំណេញទាំងនោះនឹងមិនត្រូវបានបែងចែកនៅក្នុងពេលអនាគតអាចដឹងបាន ក្រុមហ៊ុនមេមិនត្រូវទទួលស្គាល់ បំណុលពន្ធពន្យារ ។ ការពិចារណាដូចគ្នាត្រូវបានអនុវត្តចំពោះការ វិនិយោគនៅក្នុងសាខា ។

៤១ ទ្រព្យសកម្ម និងបំណុល មិនមែនរូបិយវត្ថុរបស់អង្គភាព ត្រូវបានវាស់វែងតាមរូបិយប័ណ្ណមុខងារ (សូមមើល ស.គ.អ.ក ២១ *ឥទ្ធិពលនៃការបម្លាស់ប្តូរអត្រាប្តូរប្រាក់បរទេស* ) ។ ប្រសិនបើប្រាក់ចំណេញជាប់ពន្ធរបស់អង្គភាព ឬប្រាក់ខាតពន្ធ (និងដូច្នេះ មូលដ្ឋានពន្ធនៃទ្រព្យសកម្ម និងបំណុលមិនមែនរូបិយវត្ថុ) ត្រូវបានកំណត់ជារូបិយប័ណ្ណផ្សេង ការផ្លាស់ប្តូរអត្រាប្តូរប្រាក់ផ្តល់ការកើនឡើងចំពោះភាពខុសគ្នាបណ្តោះអាសន្ន ដែលនាំឱ្យមានបំណុល ឬទ្រព្យសកម្មពន្ធពន្យារបានទទួលស្គាល់រួច (កម្មវត្ថុចំពោះ កថាខណ្ឌ ២៤ ) ។ ទ្រព្យសកម្មដែលកើតមានត្រូវបានគិត ឬកត់ត្រាខាង ឥណទានចំពោះរបាយការណ៍ចំណេញឬខាត (សូមមើល កថាខណ្ឌ ៥៨ ) ។

៤២ អ្នកវិនិយោគនៅក្នុងក្រុមហ៊ុនញ្ញាតិសម្ព័ន្ធមិនគ្រប់គ្រងអង្គភាពនោះ ហើយជាធម្មតាមិនឋិតក្នុងជំហរដើម្បីកំណត់គោលនយោបាយភាគលាភ។ ដូច្នេះ នៅក្នុងអវត្តមាននៃកិច្ចព្រមព្រៀងដែលបានតម្រូវថា ប្រាក់ចំណេញរបស់ក្រុមហ៊ុនញ្ញាតិសម្ព័ន្ធ នឹងមុនត្រូវបានបែងចែកនៅពេលអនាគតអាចដឹងបានទេនោះ អ្នកវិនិយោគទទួលស្គាល់បំណុលពន្ធពន្យារ ដែលកើតពីភាពខុសគ្នាបណ្តោះអាសន្នជាប់ពន្ធដែលជាប់ទាក់ទង នឹងការវិនិយោគនៅក្នុងក្រុមហ៊ុនញ្ញាតិសម្ព័ន្ធ។ នៅក្នុងករណីខ្លះ អ្នកវិនិយោគមិនអាចកំណត់ទឹកប្រាក់ពន្ធ ដែលនឹងត្រូវបង់ប្រសិនបើ អ្នកវិនិយោគទទួលបានមកវិញនូវថ្លៃដើមវិនិយោគនៅក្នុងក្រុមហ៊ុនញ្ញាតិសម្ព័ន្ធ ប៉ុន្តែអាចកំណត់ ដែលថាវានឹងមានតម្លៃស្មើ ឬលើសទឹកប្រាក់អប្បបរមា។ នៅក្នុងករណីបែបនេះបំណុលពន្ធពន្យារត្រូវបានវាស់វែងតាមទឹកប្រាក់នេះ ។

៤៣ ការរៀបចំរវាងភាគីចំពោះក្រុមហ៊ុនរួមទុន ជាធម្មតាជាប់ទាក់ទងនឹងការចែកប្រាក់ចំណេញ និងធ្វើអត្តសញ្ញាណថាតើការសំរេចចិត្តលើបញ្ហា ដែលទាមទារឲ្យមានការយល់ពី អ្នកចូលរួមទុនទាំងអស់ ឬចំនួនលើសលុបនៃអ្នកចូលរួមទុនដែលបានបញ្ជាក់ច្បាស់លាស់។ នៅពេលដែលអ្នកចូលរួមទុនអាចគ្រប់គ្រងការបែងចែកប្រាក់ចំណេញ ហើយវាទំនងថាប្រាក់ចំណេញនឹងមិនអាចត្រូវបានបែងចែកនៅពេលអនាគតអាច ដឹងបាននោះ បំណុលពន្ធពន្យារមិនត្រូវបានទទួលស្គាល់ទេ ។

**៤៤ អង្គភាពមួយ ត្រូវទទួលស្គាល់ទ្រព្យសកម្មពន្ធពន្យារសម្រាប់ភាពខុសគ្នាបណ្តោះអាសន្នដែលអាចកាត់កងបានទាំងអស់ដែលកើតចេញពីការ**

**វិនិយោគនៅក្នុងក្រុមហ៊ុនបុត្រសម្ព័ន្ធ សាខា និង ក្រុមហ៊ុនញ្ញាតិសម្ព័ន្ធ និង ភាគកម្មនៅក្នុងក្រុមហ៊ុនរួមទុន រហូតដល់ និង តែរហូតដល់ វាទំនងថា៖**

(ក) **ភាពខុសគ្នាបណ្តោះអាសន្ននឹងត្រឡប់វិញនៅពេលអនាគតអាចដឹងបាន និង**

(ខ) **ប្រាក់ចំណេញជាប់ពន្ធនឹងមានភាពខុសគ្នាបណ្តោះអាសន្នណាដែលភាពខុសគ្នាបណ្តោះអាសន្ន ត្រូវបានប្រើប្រាស់ ។**

៤៥ នៅក្នុងការសំរេចចិត្តថាទ្រព្យសកម្មពន្ធពន្យារ ត្រូវបានទទួលស្គាល់សម្រាប់ ភាពខុសគ្នាបណ្តោះអាសន្នអាចកាត់កងបានដែលជាប់ទាក់ទងនឹងការវិ និយោគនៅក្នុងក្រុមហ៊ុនបុត្រសម្ព័ន្ធ សាខា និង ក្រុមហ៊ុនញ្ញាតិសម្ព័ន្ធ និង ភាគកម្មនៅក្នុងក្រុមហ៊ុនរួមទុន នោះអង្គភាពពិចារណាពីសេចក្តីណែនាំ ដែលបានកំណត់នៅក្នុងកថាខណ្ឌ ២៨ ដល់ ៣១ ។

## ការវាស់វែង

**៤៦ បំណុល (ទ្រព្យសកម្ម)ពន្ធបច្ចុប្បន្ន សម្រាប់គ្រាបច្ចុប្បន្ន និងគ្រាមុនត្រូវបានវាស់វែង តាមទឹកប្រាក់ដែលរំពឹងថា នឹងបង់ទៅឲ្យ (ទទួលបានមកវិញពី) អាជ្ញាធរពន្ធដារ ដោយប្រើអត្រាពន្ធ (និងច្បាប់ពន្ធ ) ដែលត្រូវបានអនុម័ត ឬ ត្រូវបានអនុម័តជាសំខាន់នៅចុងគ្រារាយការណ៍។**

**៤៧ ទ្រព្យសកម្ម និងបំណុលពន្ធព្យាត្រូវបានវាស់វែងតាមអត្រា ដែលរំពឹងថានឹងប្រើចំពោះគ្រានៅពេលដែល ទ្រព្យសកម្មត្រូវបានទទួលស្គាល់ ឬ**

**បំណុលត្រូវបានទូទាត់ ដោយផ្អែកលើអត្រាពន្ធ (និងច្បាប់ពន្ធ) ដែលត្រូវបានអនុម័ត ឬ ត្រូវបានអនុម័តជាសំខាន់នៅចុងគ្រារាយការណ៍ ។**

៤៨ ទ្រព្យសកម្ម និងបំណុលពន្ធពន្យារ និងពន្ធបច្ចុប្បន្នត្រូវបានវាស់វែងដោយប្រើអត្រាពន្ធ (និងច្បាប់ពន្ធ)ដែលត្រូវអនុម័តរួច។ ប៉ុន្តែនៅក្នុងប្រទេសខ្លះ សេចក្តីជូនដំដឹងពីអត្រាពន្ធ (និងច្បាប់ពន្ធ) ដោយរដ្ឋាភិបាលមានប្រសិទ្ធិ-ភាពសំខាន់ ដូចការអនុម័តជាក់ស្តែងដែរ ដែលអាចតាមដានសេចក្តីជូនដំណឹងនៅគ្រាដែលមានរយៈ ពេលប៉ុន្មានខែដែរ។ នៅក្នុងកាលៈទេសៈទាំងនេះ ទ្រព្យសកម្មនិងបំណុលពន្ធត្រូវបានវាស់វែងដោយប្រើ អត្រាពន្ធដែលមានប្រកាសរួច (និងច្បាប់ពន្ធ) ។

៤៩

នៅពេលដែលអត្រាពន្ធអនុវត្តចំពោះកម្រិតប្រាក់ចំណូលខុសគ្នា ទ្រព្យសកម្ម និងបំណុលពន្ធពន្យារត្រូវបាន វាស់វែងអត្រាមធ្យមដែលត្រូវបានរំពឹងថា នឹងអនុវត្តចំពោះប្រាក់ចំណេញជាប់ពន្ធ (ប្រាក់ខាតពន្ធ) នៃគ្រាដែលភាពខុសគ្នាបណ្តោះអាសន្ន ត្រូវបានរំពឹងថានឹងត្រឡប់វិញ។

៥០ [លុបចោល]

៥១ **ការវាស់វែងពីបំណុលពន្ធពន្យារ និងទ្រព្យសកម្មពន្ធព្យាត្រូវឆ្លុះបញ្ចាំងពីផលវិបាកពន្ធដែលគួរស្របតាមឥរិយាបទ ដែលអង្គភាពរំពឹងទុកនៅចុងគ្រារាយការណ៍ ដើម្បីទទួលបានមកវិញ ឬ ទូទាត់តម្លៃពិតគណនេយ្យនៃទ្រព្យសកម្ម និង បំណុល។**

៥១ក នៅក្នុងប្រទេសខ្លះ ឥរិយាបទដែលអង្គភាពទទួលបានមកវិញ (ទូទាត់) តម្លៃពិតគណនេយ្យនៃទ្រព្យសកម្ម (បំណុល) អាចប៉ះពាល់មួយ ឬទាំងពីរ ដូចខាងក្រោមៈ

(ក) អត្រាពន្ធអាចអនុវត្តនៅពេលដែលអង្គភាពទទួលបានមកវិញ (ទូទាត់) តម្លៃពិតគណនេយ្យនៃទ្រព្យសកម្ម (បំណុល) និង

(ខ) មូលដ្ឋានពន្ធនៃទ្រព្យសកម្ម (បំណុល)

នៅក្នុងករណីបែបនេះ អង្គភាពវាស់វែងបំណុលពន្ធពន្យារ និងទ្រព្យសកម្មពន្ធពន្យារដោយប្រើអត្រាពន្ធ និងមូលដ្ឋានពន្ធ ដែលស្របនឹងឥរិយាបទនៃការទទួលបានមកវិញឬការទូទាត់រំពឹងទុក

| **ឧទាហរណ៍ ក** |
| --- |
| ទ្រព្យ រោងចក្រ និង បរិក្ខារមានតម្លៃពិតគណនេយ្យ១០០ និងមូលដ្ឋានពន្ធ អត្រាពន្ធ ២០% នឹងអនុវត្តប្រសិនបើធាតុខាងលើ មិនត្រូវបានលក់ហើយ អត្រា ពន្ធ ៣០% នឹងអនុវត្តចំពោះចំណូលផ្សេងទៀត។<br>*អង្គភាពទទួលស្គាល់បំណុលពន្ធពន្យារ៨ (៤០ x ២០%) ប្រសិនបើអង្គភាព រំពឹងថានឹងលក់ធាតុដោយគ្មានការប្រើប្រាស់បន្ថែម និងបំណុលពន្ធពន្យារ ១២ (៤០ x៣០%) ប្រសិនបើអង្គភាពរក្សាធាតុ និងទទួលបានមកវិញនូវ តម្លៃពិតគណនេយ្យ តាមរយៈការប្រើប្រាស់។* |

**ឧទាហរណ៍ ខ**

ទ្រព្យ រោងចក្រ និង ឧបករណ៍ ដែលមានថ្លៃដើម ១០០ និង តម្លៃពិតគណនេយ្យ ៨០ ត្រូវបានវាយតម្លៃឡើងវិញថា ១៥០។ ពុំមានការកែសំរួលសមមូលណាមួយ ត្រូវបានធ្វើឡើងសម្រាប់ គោលបំណងពន្ធទេ។ រំលស់បូកបន្តសម្រាប់គោលបំណងគឺ ៣០ និង អត្រាពន្ធគឺ ៣០%។ ប្រសិន បើធាតុត្រូវបានលក់លើសថ្លៃដើមនោះរំលស់ពន្ធបូកបន្ត ៣០ នឹងត្រូវបាន បញ្ចូលនៅក្នុងចំណូលជាប់ពន្ធ ប៉ុន្តែចំណូលពីការលក់លើសថ្លៃដើមនឹង មិនជាប់ពន្ធទេ ។

*មូលដ្ឋានពន្ធនៃធាតុ គឺ ៧០ និងមានភាពខុសគ្នាបណ្ដោះអាសន្នជាប់ពន្ធ ៨០។ ប្រសិនបើ អង្គភាពរំពឹងថានឹងទទួលបានមកវិញនូវតម្លៃពិតគណ-នេយ្យដោយប្រើធាតុនោះ អង្គភាពត្រូវរកឲ្យមាននូវចំណូលជាប់ពន្ធ ១៥០ ប៉ុន្តែនឹងអាចកាត់កង រំលស់តែ៧០ ប៉ុណ្ណោះ។ ឈរលើមូលដ្ឋាននេះមានបំណុលពន្ធពន្យារ ២៤ (៨០x៣០%)។ ប្រសិនបើអង្គភាពរំពឹងថានឹងទទួលបានមកវិញនូវតម្លៃពិតគណនេយ្យ ដោយការលក់ធាតុភ្លាមៗក្នុងតម្លៃ ១៥០ នោះបំណុលពន្ធពន្យារត្រូវបាន គណនាដូចខាងក្រោម:*

| | ភាពខុសគ្នា បណ្ដោះអាសន្នជាប់ពន្ធ | អត្រាពន្ធ | បំណុលពន្ធពន្យារ |
|---|---|---|---|
| រំលស់ពន្ធបូកបន្ត | 30 | 30% | 9 |

| | | | |
|---|---|---|---|
| ចំណូលលើសថ្លៃដើម | 50 | សូន្យ | - |
| សរុប | 80 | | 9 |

(ចំណាំៈ អនុលោមតាមកថាខណ្ឌ ៦១ក ពន្ធពន្យារបន្ថែមកើតឡើងពីការវាយតម្លៃឡើងវិញត្រូវបានទទួលស្គាល់នៅក្នុងចំណូលលម្អិតផ្សេងទៀត)

*ឧទាហរណ៍ គ*

ហេតុការនៅក្នុងឧទាហរណ៍ (ខ )លើកឡើងថា ប្រសិនបើធាតុត្រូវបានលក់លើសថ្លៃដើម នោះរំលស់ពន្ធបូកបន្ត នឹងត្រូវបានបញ្ចូលនៅក្នុងចំណូលជាប់ពន្ធ (ជាប់ពន្ធតាមអត្រា៣០%) និងចំណូលពីការលក់នឹងត្រូវបានជាប់ពន្ធតាមអត្រា៤០% បន្ទាប់ពីកាត់កងថ្លៃដើមបានកែសំរួលជាមួយអតិផរណារួច ១១០។

*ប្រសិនបើអង្គភាពរំពឹងថានឹងទទួលបានមកវិញនូវតម្លៃពិតគណនេយ្យដោយប្រើប្រាស់ធាតុ នោះអង្គភាពត្រូវតែរកឲ្យបាននូវចំណូលជាប់ពន្ធ១៥០ ប៉ុន្តែនឹងអាចកាត់កងតែរំលស់៧០ប៉ុណ្ណោះ។ ឈរលើមូលដ្ឋាននេះមូលដ្ឋានពន្ធគឺ ៧០ មានភាពខុសគ្នាបណ្តោះអាសន្នជាប់ពន្ធ៨០ និងមានបំណុលពន្ធពន្យារ ២៤(៨០ x ៣០%) ដូចមានក្នុងឧទាហរណ៍ ខ ។*

*ប្រសិនបើ អង្គភាពរំពឹងថានឹងទទួលបានមកវិញនូវតម្លៃពិតគណនេយ្យដោយ ការលក់ធាតុភ្លាមក្នុងតម្លៃ ១៥០ នោះអង្គភាពនឹងអាចកាត់កងថ្លៃ*

*ដើម ១១០។ ចំណូលសុទ្ធ៤០ នឹងត្រូវជាប់ពន្ធតាមអត្រា៤០%។ លើសពីនេះទៅទៀតរំលស់ពន្ធបូកបន្ត៣០ នឹងត្រូវបានបញ្ចូលនៅក្នុងប្រាក់ចំណូលជាប់ពន្ធនិងគិតពន្ធតាមអត្រា ៣០%។ ឈរលើមូលដ្ឋាននេះ មូលដ្ឋានពន្ធគឺ៨០ (១១០ ដក ៣០) មានភាពខុស គ្នាបណ្តោះអាសន្នជាប់ពន្ធ ៧០ និងមានបំណុលពន្ធពន្យារ ២៥ (៤០ x៤០% បូក ៣០ x ៣០%)។ ប្រសិនបើ មូលដ្ឋានពន្ធមិនកើតមានភ្លាមៗនៅក្នុងឧទាហរណ៍នេះទេ វាអាចមានប្រយោជន៍ ដើម្បីពិចារណាពីគោលការណ៍សំខាន់ៗ ដែលកំណត់នៅក្នុងកថាខណ្ឌ១០។*

*(ចំណាំ: អនុលោមតាម កថាខណ្ឌ ៦១ក ពន្ធពន្យារបន្ថែម ដែលកើតឡើងនៅពេល ការវាយតម្លៃឡើងវិញត្រូវបានទទួលស្គាល់នៅក្នុងចំណូលលម្អិតផ្សេងទៀត ។*

៥១ខ ប្រសិនបើបំណុលពន្ធពន្យារ ឬទ្រព្យសកម្មពន្ធពន្យារកើតឡើងពីទ្រព្យសកម្ម មិនអាចដករំលស់ដែលបានវាស់ វែងដោយប្រើវិធីសាស្ត្រវាយតម្លៃឡើងវិញនៅក្នុង ស.គ.អ.ក ១៦ ការវាស់វែងបំណុលពន្ធពន្យារ ឬទ្រព្យសកម្ម ពន្ធពន្យារ ត្រូវឆ្លុះបញ្ចាំងពីផលវិបាកពន្ធនៃការទទួលបានមកវិញនូវតម្លៃពិតគណនេយ្យនៃទ្រព្យសកម្ម មិនអាចដករំលស់តាមរយៈការលក់ដោយ មិនគិតពីមូលដ្ឋាននៃការវាស់ វែងតម្លៃពិតគណនេយ្យនៃទ្រព្យសកម្មនោះ ។ ដូច្នេះ ប្រសិនបើច្បាប់ពន្ធបញ្ជាក់ពី អត្រាពន្ធអាចអនុវត្តមានចំពោះទឹកប្រាក់ជាប់ពន្ធ ដែលទទួលបានពីការលក់ទ្រព្យសកម្មដែលខុសពីអត្រាពន្ធ អាចអនុវត្តមាន ចំពោះទឹកប្រាក់ជាប់ពន្ធ

ដែលទទួលបានពីការប្រើប្រាក់ទ្រព្យសកម្ម អត្រាពីមុនត្រូវបាន ប្រើក្នុងការវាស់វែងបំណុលពន្ធពន្យារ ឬទ្រព្យសកម្មដែលជាប់ទាក់ទិននឹងទ្រព្យសកម្មមិនអាចដករំលស់បាន ។

៥១គ ប្រសិនបើ បំណុលពន្ធពន្យារ ឬទ្រព្យសកម្មពន្ធពន្យារកើតឡើងពីទ្រព្យវិនិយោគដែលត្រូវបានវាស់វែងដោយប្រើ វិធីសាស្ត្រទីផ្សារនៅក្នុង ស.គ.អ.ក ៤០ ការសន្មតដែលអាចទាត់ចោលបានដែលតម្លៃពិតគណនេយ្យនៃទ្រព្យវិនិយោគនឹងត្រូវបានទទួលមកវិញតាមរយៈការលក់។ ដូច្នេះ ប្រសិនបើការសន្មតមិនត្រូវបានបដិសេធទេ ការវាស់វែងនៃ បំណុលពន្ធពន្យារ ឬទ្រព្យសកម្មពន្ធពន្យារត្រូវឆ្លុះបញ្ចាំងពីផលវិបាកនៃការទទួលបានមកវិញនូវតម្លៃពិត គណនេយ្យនៃទ្រព្យវិនិយោគទាំងស្រុងតាមរយការលក់ ។ ការសន្មតនេះត្រូវបានបដិសេធប្រសិនទ្រព្យវិនិយោគអាចដករំលស់បាន និងត្រូវបានរក្សាទុកនៅក្នុងគំរូអាជីវកម្មដែលគោលបំណងរបស់គេ គឺត្រូវប្រើអត្ថប្រយោជន៍សេដ្ឋកិច្ចទាំងអស់ដែលមាននៅក្នុងទ្រព្យវិនិយោគក្នុងរយៈពេលមួយជាងតាមរយៈការលក់ ។ ប្រសិនបើការសន្មត់ត្រូវបានបដិសេធនេះសេចក្តីតម្រូវនៃកថាខណ្ឌ ៥១ និង ៥១ក ត្រូវបានយកទៅអនុវត្ត ។

| **ឧទាហរណ៍ដែលពន្យល់ពីកថាខណ្ឌ ៥១គ** |
|---|
| ទ្រព្យវិនិយោគមួយមានថ្លៃដើម១០០ និងតម្លៃទីផ្សារ១៥០។ វាត្រូវបានវាស់វែង ដោយប្រើវិធីសាស្ត្រតម្លៃទីផ្សារនៅក្នុង ស.គ.អ.ក ៤០។ វារួមមានដីមានថ្លៃដើម ៤០ និង តម្លៃទីផ្សារ៦០ និងអគារមានថ្លៃដើម ៦០ |

និងតម្លៃទីផ្សារ៩០។ ដីមានអាយុកាលមិនកំណត់ទេ។

វិលស់ប្ដូកបន្តនៃអគារសម្រាប់គោលបំណងពន្ធ៣០ ។ ការផ្លាស់ប្ដូរ ដែលមិនបានទទួលស្គាល់ក្នុងតម្លៃទីផ្សារនៃ ទ្រព្យវិនិយោគមិនបានប៉ះពាល់ដល់ប្រាក់ចំណេញជាប់ពន្ធទេ។ ប្រសិនបើ ទ្រព្យវិនិយោគត្រូវបានលក់លើសពីថ្លៃដើម នោះការត្រឡប់វិញនៃរំលស់ពន្ធប្ដូកបន្ត៣០ នឹងត្រូវបានបញ្ចូលក្នុងប្រាក់ចំណេញជាប់ពន្ធ និងគិតពន្ធតាមអត្រាពន្ធធម្មតា ៣០ %។ សម្រាប់ចំណូលពីការលក់លើសថ្លៃដើមច្បាប់ពន្ធបញ្ជាក់អត្រ ២៥% សម្រាប់ ទ្រព្យសកម្ម ដែលរក្សាទុកតិចជាង ២ឆ្នាំ និង២០% សម្រាប់ទ្រព្យសកម្ម រក្សាទុករយៈពេល២ឆ្នាំ ឬ ច្រើនជាងនេះ។

*ដោយសារតែ ទ្រព្យវិនិយោគត្រូវបានវាស់វែង ដោយប្រើវិធីសាស្ត្រតម្លៃទីផ្សារនៅក្នុង ស.គ.អ.ក ៤០ មានការសន្មត់ផ្ទុយ ដែលអង្គភាពនឹងទទួលបានមកវិញនូវតម្លៃពិតគណនេយ្យនៃទ្រព្យវិនិយោគទាំងមូលតាមរយៈការលក់។ ប្រសិនបើ ការសន្មតទុកជាមុននោះ មិនត្រូវបានបដិសេធទេនោះ ពន្ធពន្យារឆ្លុះបញ្ចាំងពី ផលវិបាកពន្ធនៃការទទួលបានមកវិញនូវតម្លៃពិតក្នុងបញ្ជីទាំងស្រុងតាមរយៈ ការលក់ទោះបីជាអង្គភាពរំពឹងថានឹងរកបានចំណូលពីការជួលពីទ្រព្យមុនពេលលក់។*

*មូលដ្ឋានពន្ធនៃដីប្រសិនបើ លក់គឺមានតម្លៃ៤០ និងមានភាពខុសគ្នាបណ្ដោះអាសន្ន ៦០ (៩០-៣០). ជាលទ្ធផល ភាពខុសគ្នាបណ្ដោះអាសន្ន*

ជាប់ពន្ធសរុបដែលទាក់ទិននឹងទ្រព្យវិនិយោគគឺ ៨០ (២០+ ៦០)។

ដោយអនុលោមតាមកថាខណ្ឌ ៤៧ អត្រាពន្ធគឺជាអត្រាដែលបានរំពឹងថា នឹងអនុវត្តចំពោះគ្រានៅពេលដែលទ្រព្យវិនិយោគត្រូវបានទទួលស្គាល់។ ដូច្នេះ បំណុលពន្ធពន្យារ ដែលកើតមានត្រូវបានគណនាដូចខាងក្រោម ប្រសិនបើអង្គភាពរំពឹងថានឹងលក់ទ្រព្យបន្ទាប់ពីកាន់កាប់វាអស់រយៈពេល លើសពី២ឆ្នាំ:

| | ភាពខុសគ្នាបណ្ដោះអាសន្នជាប់ពន្ធ | អត្រាពន្ធ | បំណុលពន្ធពន្យា |
|---|---|---|---|
| រំលស់ពន្ធបូកបន្ត | 30 | 30% | 9 |
| ចំណូលលើសពីថ្លៃដើម | 50 | 20% | 10 |
| សរុប | 80 | | 19 |

ប្រសិនបើ អង្គភាពរំពឹងថានឹងលក់ទ្រព្យបន្ទាប់ពីការកាន់កាប់វាអស់រយៈពេលតិចជាង២ឆ្នាំ ការគណនានឹងត្រូវបានកែប្រែដើម្បីអនុវត្តអត្រាពន្ធ ២៥% ជាជាងអត្រា ២០% ចំពោះចំណូលលើសពីថ្លៃដើម។

ជំនួសមកវិញ ប្រសិនបើអង្គភាពរក្សាទុកអគារនៅក្នុងគំរូអាជីវកម្ម ដែលគោលបំណង នឹងត្រូវប្រើប្រាស់អត្ថប្រយោជន៍សេដ្ឋកិច្ចសំខាន់ៗទាំងអស់ ដែលមានជាប់ ជាមួយនឹងអគារលើវេលាមួយ ជាជាងតាមរយៈការលក់ ការសន្មតទុកជាមុននេះអាចត្រូវបានបដិសេធសម្រាប់អគារ។ ប៉ុន្តែដីមិន

*អាចដកវិលស់បានទេ។ ដូច្នេះការសន្មតទុកជាមុននូវការទទួលបានមកវិញតាមរយៈការលក់នឹងមិនត្រូវបានបដិសេធសម្រាប់ដី។ ប្រសិនបើអង្គភាពធ្វើតាមនោះ បំណុលពន្ធពន្យារអាចឆ្លុះបញ្ចាំងផលវិបាកពន្ធនៃ ការទទួលបានមកវិញនូវ តម្លៃពិតគណនេយ្យនៃអគារតាមរយៈការប្រើប្រាស់ និងតម្លៃពិតគណនេយ្យនៃដីតាមរយៈការប្រើប្រាស់។*

*មូលដ្ឋានពន្ធនៃអគារ ប្រសិនបើត្រូវបានប្រើប្រាស់ គឺ ៣០ (៦០-៣០) និងភាពខុសគ្នាបណ្តោះអាសន្នជាប់ពន្ធ ៦០ (៩០-៣០) ដែលនាំឲ្យកើតមានបំណុលពន្ធពន្យារ ១៨(៦០x ៣០%) ។*

*មូលដ្ឋានពន្ធនៃដីប្រសិនបើត្រូវបានលក់៤០ និងមានភាពខុសគ្នាបណ្តោះអាសន្នជាប់ពន្ធ ២០ (៦០-40) ដែលនាំឲ្យកើតមានបំណុលពន្ធពន្យារ ៤ (២០x២០%)។*

*ជាលទ្ធផលប្រសិនបើការសន្មត់ជាមុននៃការទទួលបានមកវិញតាមរយៈការលក់ត្រូវបានបដិសេធសម្រាប់អគារ*
*នោះបំណុលពន្ធពន្យារដែលទាក់ទិន និងទ្រព្យវិនិយោគគឺ ២២(១៨+៤)។*

៥១ឃ ការសន្មត់ដែលផ្ទុយនៅក្នុងកថាខណ្ឌ ៥១គ ក៏អនុវត្តផងដែរ នៅពេលដែលបំណុលពន្ធពន្យារ ឬទ្រព្យសកម្មពន្ធពន្យារកើតឡើងពីការវាស់វែងទ្រព្យវិនិយោគ នៅក្នុងការបញ្ចូលអាជីវកម្មរួមគ្នា ប្រសិនបើអង្គភាពនឹងប្រើវិធីសាស្ត្រតម្លៃទីផ្សារនៅពេលវាស់វែង ទ្រព្យវិនិយោគនោះនៅគ្រាបន្ទាប់។

៥១ង កថាខណ្ឌ ៥១ខ - ៥១ឃ មិនផ្លាស់ប្តូរការសេចក្តីតម្រូវដើម្បីអនុវត្តគោល- ការណ៍ នៅក្នុង កថាខណ្ឌ ២៤ - ៣៣ (ភាពខុសគ្នាបណ្តោះអាសន្ន) និង កថាខណ្ឌ ៣៤ - ៣៦ (ប្រាក់ខាតពន្ធមិនបានប្រើ និងឥណទានពន្ធមិនបានប្រើ) នៃស្តង់ដារនេះពេលដែលទទួលស្គាល់ និងវាស់វែងទ្រព្យសកម្ម ពន្ធពន្យារ ។

៥២ [ផ្លាស់ចេញ និងដាក់លេខឡើងវិញ៥១ក]

៥២ក នៅក្នុងប្រទេសខ្លះ ពន្ធលើប្រាក់ចំណូលត្រូវសងតាមអត្រាខ្ពស់ជាងឬទាបជាងប្រសិនបើផ្នែកឬប្រាក់ចំណេញសុទ្ធទាំងអស់ ឬប្រាក់ចំណេញរក្សាទុកត្រូវបានបង់ជាភាគលាភទៅឱ្យម្ចាស់ភាគហ៊ុនរបស់អង្គភាព ។ នៅក្នុងប្រទេសខ្លះទៀត ពន្ធលើប្រាក់ចំណូល អាចត្រូវបានបង្វិលមកវិញ ឬសងប្រសិនបើផ្នែក ឬប្រាក់ចំណេញសុទ្ធទាំអស់ឬប្រាក់ចំណេញរក្សាទុកត្រូវបានបង់ជាភាគលាភទៅឱ្យ ម្ចាស់ភាគហ៊ុនរបស់អង្គភាព ។ នៅក្នុងករណីទាំងនេះ ទ្រព្យសកម្មនិងបំណុលពន្ធពន្យារ ត្រូវបានវាស់វែងតាមអត្រាពន្ធដែលអាចអនុវត្តចំពោះប្រាក់ចំណេញមិនទាន់បែងចែក ។

៥២ខ នៅក្នុងកាលៈទេសៈទាំងឡាយដែលបានរៀបរាប់នៅក្នុងកថាខណ្ឌ ៥២ក ផលវិបាកពន្ធលើប្រាក់ចំណូលនៃ ភាគលាភត្រូវបានទទួលស្គាល់នៅពេលដែលបំណុលត្រូវបង់ភាគលាភត្រូវបានបានទទួលស្គាល់ ។ ផលវិបាកពន្ធលើប្រាក់ចំណូលនៃភាគលាភគឺមានការពាក់ពន្ធ័ដោយផ្ទាល់ច្រើនចំពោះប្រតិបត្តិការ ឬព្រឹត្តការណ៍ពីអតីតកាល ជាងចំពោះការបែងចែកទៅឱ្យម្ចាស់ភាគហ៊ុន ។ ដូច្នេះផលវិបាកពន្ធលើប្រាក់ចំណូលនៃភាគលាភត្រូវបានទទូស្គាល់នៅក្នុង របាយការណ៍ចំណេញ ឬខាតសម្រាប់គ្រា

ដូចបាន តម្រូវនៅក្នុងកថាខណ្ឌ ៥៨ លើកលែងរហូតដល់ផលវិបាកពន្ធលើប្រាក់ នៃភាគលាភ កើតឡើងពីហេតុការណ៍ដូចបានរៀបចំនៅក្នុងកថាខណ្ឌ ៥៨(ក) និង (ខ)

| ឧទាហរណ៍ដែលពន្យល់កថាខណ្ឌ ៥២ក និង ៥២ខ |
| --- |
| ឧទាហរណ៍នេះជាប់ទាក់ទងជាមួយការវាស់វែងទ្រព្យសកម្ម និងពន្ធពន្យារ និងពន្ធបច្ចុប្បន្នសម្រាប់អង្គភាពមួយនៅក្នុងប្រទេសមួយដែលពន្ធលើប្រាក់ចំណូលត្រូវសងតាម អត្រាខ្ពស់ជាងលើប្រាក់ចំណេញមិនទាន់បង់ពន្ធ (៥0%) ជាមួយនឹងទឹកប្រាក់ដែលអាចបង្វិលសងវិញនៅពេលប្រាក់ចំណេញត្រូវបានបែងចែក។ អត្រាពន្ធលើប្រាក់ចំណេញបានបែងចែករួច ៣៥%។ នៅ ចុងគ្រារាយការណ៍ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២0x១ អង្គភាពមិនទទួលស្គាល់បំណុលសម្រាប់ភាគលាភដែលបានស្នើសុំ ឬប្រកាស បន្ទាប់ពីគ្រារាយការណ៍។ ជាលទ្ធផលមិនភាគលាភណាមួយត្រូវបាន ទទួលស្គាល់នៅក្នុង ឆ្នាំ២0X១ ទេ។ ប្រាក់ចំណូលជាប់ពន្ធសម្រាប់ឆ្នាំ២0x១ គឺ ១00.000។ ភាពខុសគ្នា បណ្តោះអាសន្នជាប់ពន្ធសុទ្ធសម្រាប់ ឆ្នាំ២0X1 គឺ ៤0.000។ <br><br> *អង្គភាពទទួលស្គាល់បំណុលពន្ធបច្ចុប្បន្ន និងចំណាយពន្ធលើប្រាក់ចំណូលបច្ចុប្បន្ន គឺ ៥0.000។* <br><br> *មិនមានទ្រព្យសកម្មណាមួយត្រូវបានទទួលស្គាល់សម្រាប់ចំនួនទឹកប្រាក់ដែលទំនង ថានឹងអាចទទួលបានមកវិញដែលជាលទ្ធផលនៃភាគលាភអនាគត។ អង្គភាពក៏ទទួលស្គាល់បំណុលពន្ធពន្យារនិងចំណាយពន្ធពន្យារ* |

*២០.០០០ (៤០.០០០ x ៥០%) តំណាងឲ្យពន្ធលើប្រាក់ចំណូលដែលអង្គភាពនឹង ទូទាត់សងនៅពេលអង្គភាពទទួលបានមកវិញ ឬទូទាត់សងតម្លៃពិតគណ- នេយ្យនៃទ្រព្យសកម្ម និងបំណុលដោយផ្អែកលើអត្រាពន្ធដែលអាចប្រើ ប្រាស់បានចំពោះប្រាក់ចំណេញ មិនទាន់បែងចែក។*

នៅឆ្នាំបន្ទាប់ ថ្ងៃទី១៥ ខែមីនា ឆ្នាំ២០x២ អង្គភាពទទួលស្គាល់ការទទួលបាន មកវិញនៃពន្ធលើប្រាក់ចំណូល ១.៥០០ (១៥% នៃភាគលាភដែលបានទទួលស្គាល់ជាបំណុល) ជាទ្រព្យសកម្មពន្ធបច្ចុប្បន្ន និងជាការកាត់បន្ថយនៃចំណាយប្រាក់ពន្ធលើប្រាក់ចំណូលបច្ចុប្បន្នសម្រាប់ឆ្នាំ ២០x២។

## ៥៣ ទ្រព្យសកម្មពន្ធពន្យារ និងបំណុលពន្ធពន្យារមិនត្រូវបានធ្វើអប្បហារ

ការកំណត់គួរជឿជាក់នៃទ្រព្យសកម្មនិងបំណុលពន្ធពន្យារលើមូលដ្ឋានអប្បហារតម្រូវឲ្យមានការកំណត់ពេលវេលានៃការត្រឡប់វិញនៃភាពខុសគ្នាបណ្ដោះអាសន្ន។ នៅក្នុងករណីជាច្រើនដូចជាការកំណត់ពេលវេលាមិនអាចអនុវត្តបាន ឬមានភាពស្មុគស្មាញច្រើន ។ ដូច្នេះវាមិនសមស្របទេដែលទាមទារឲ្យធ្វើអប្បហារលើ ទ្រព្យសកម្មនិងបំណុលពន្ធពន្យារ។ ដើម្បីអនុញ្ញាតិ ប៉ុន្តែមិនតម្រូវទេ ការធ្វើអប្បហារកើតមានទ្រព្យសកម្មនិងបំណុល ពន្ធពន្យារ ដែលនឹងមិនអាចប្រៀបធៀបគ្នា រវាងអង្គភាពនិងអង្គភាព ។ ដូច្នេះ ស្តង់ដារនេះមិនតម្រូវ ឬអនុញ្ញាតឲ្យធ្វើអប្បហារនៃទ្រព្យសកម្ម និង បំណុលពន្ធពន្យារ ។

៥៥ ភាពខុសគ្នាបណ្ដោះអាសន្ន ត្រូវបានកំណត់ដោយយោងទៅលើតម្លៃពិតគណនេយ្យនៃទ្រព្យសកម្ម ឬបំណុល។ នេះអនុវត្តទោះជាតម្លៃពិតគណនេយ្យនោះត្រូវបានកំណត់ដោយខ្លួនឯងលើមូលដ្ឋានអប្បហារ ឧទាហរណ៍នៅក្នុងករណីកាតព្វកិច្ចអត្ថប្រយោជន៍ចូលនិវត្តន៍ (សូមមើល ស.គ.អ.ក ១៩ *អត្ថប្រយោជន៍និយោជិក*)។

**៥៦ តម្លៃពិតគណនេយ្យនៃទ្រព្យសកម្មពន្ធពន្យារត្រូវបានពិនិត្យឡើងវិញរហូតដល់វាមិនទំនងថា ប្រាក់ចំណេញជាប់ពន្ធនឹងមាន ដើម្បីអនុញ្ញាតិអត្ថប្រយោជន៍នៃផ្នែក ឬទ្រព្យសកម្មពន្ធពន្យារនោះនឹងត្រូវបានប្រើទៀតទេ។ ការកាត់បន្ថយណាមួយបែបនេះ ត្រូវបានត្រឡប់វិញរហូតដល់វាទំនងថា ប្រាក់ចំណេញជាប់ពន្ធគ្រាប់គ្រាន់នឹងកើតមាន ។**

## ការទទួលស្គាល់ពន្ធបច្ចុប្បន្ននិងពន្ធពន្យារ

៥៧ កាធ្វើគណនេយ្យកម្មសម្រាប់ឥទ្ធិពលពន្ធពន្យារ និងពន្ធបច្ចុប្បន្ន ឬព្រឹត្តិការណ៍ផ្សេងទៀត ដែលស្របនឹងការធ្វើគណនេយ្យកម្មសម្រាប់ប្រតិបត្តិការឬព្រឹត្តិការណ៍ខ្លួនឯង ។ កថាខណ្ឌ៥៨ ដល់ ៦៨គ ប្រើប្រាស់គោលការណ៍នេះ ។

### ធាតុដែលបានទទួលស្គាល់នៅក្នុងរបាយការណ៍ចំណេញ ឬ ខាត

**៥៨ ពន្ធពន្យារនិងពន្ធបច្ចុប្បន្នត្រូវបានទទួលស្គាល់ជាចំណូលឬចំណាយ ហើយត្រូវបានបញ្ចូលនៅក្នុង របាយការណ៍ចំណេញ ឬ ខាតសម្រាប់គ្រាលើកលែងរហូតដល់ពន្ធកើតពីៈ**

(ក) ប្រតិបត្តិការឬព្រឹត្តការណ៍ដែលត្រូវបានទទួលស្គាល់នៅក្នុងគ្រាដូចគ្នា ឬគ្រាខុសគ្នា ខាងក្រៅរបាយការណ៍ចំណេញឬខាត នៅក្នុងចំណូលលម្អិតផ្សេងទៀត ឬនៅក្នុងមូលនិធិដោយផ្ទាល់ (សូមមើល កថាខណ្ឌ៦១ក ដល់ ៦៥) ឬ

(ខ) ការបញ្ចូលអាជីវកម្មរួមគ្នា (សូមមើលកថាខណ្ឌ ៦៦ ដល់ ៦៨)។

៥៩ បំណុលពន្ធពន្យារ និងទ្រព្យសកម្មពន្ធពន្យារភាគច្រើនកើតឡើងពេលដែលចំណូល ឬចំណាយត្រូវបានបញ្ចូល នៅក្នុងប្រាក់ចំណេញគណនេយ្យនៅក្នុងគ្រាមួយ ប៉ុន្តែត្រូវបានបញ្ចូលនៅក្នុងប្រាក់ចំណេញជាប់ពន្ធ (ប្រាក់ខាតពន្ធ) នៅក្នុងគ្រាផ្សេងទៀត ។ ពន្ធពន្យារនេះត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ប្រាក់ចំណេញឬខាត។
ឧទាហរណ៍គឺនៅពេលា÷

(ក) ចំណូលការប្រាក់ ចំណូលសួយសារ ឬចំណូលភាគលាភត្រូវបានទទួលនៅពេលក្រោយ ហើយត្រូវបានបញ្ចូលនៅក្នុងប្រាក់-ចំណេញគណនេយ្យតាមមូលដ្ឋានសមាមាត្រពេលវេលាដោយអនុលោមតាម ស.គ.អ.ក ១៨ *ចំណូល* ប៉ុន្តែត្រូវបានបញ្ចូលនៅក្នុងប្រាក់ចំណេញជាប់ពន្ធ (ប្រាក់ខាតពន្ធ) តាមមូលដ្ឋានសាច់ប្រាក់ និង

(ខ) ចំណាយទ្រព្យសកម្មអរូបីដែលត្រូវបានធ្វើមូលធនកម្មតាម ស.គ.អ.ក ៣៨ និងត្រូវបានដករំលស់នៅក្នុងរបាយការណ៍ចំណេញ ឬខាតប៉ុន្តែ មិនត្រូវបានកាត់កងសម្រាប់គោលបំណងពន្ធ នៅពេលចំណាយនោះបានកើតឡើង ។

៦០ តម្លៃពិតគណនេយ្យនៃទ្រព្យសកម្មពន្ធពន្យារ និងបំណុលពន្ធពន្យារអាចប្រែប្រួលទោះបីជាមិនមានការផ្លាស់ប្តូរចំនួនទឹកប្រាក់នៃភាពខុសគ្នាបណ្តោះអាសន្ន ។ ករណីនេះអាចកើតមកពី ឧទាហរណ៍:

(ក) ការផ្លាស់ប្តូរអត្រាពន្ធ ឬ ច្បាប់ពន្ធ

(ខ) ការវាយតម្លៃឡើងវិញនៃភាពអាចទទួលបានមកវិញនៃទ្រព្យ-សកម្ម ពន្ធពន្យារ ឬ

(គ) ការផ្លាស់ប្តូរនៅក្នុងឥរិយាបទបានរំពឹងនៃការទទួលបានមកវិញនៃទ្រព្យសកម្ម ។

ពន្ធពន្យារត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ចំណេញ ឬខាតលើកលែងរហូតដល់ពន្ធពន្យារនោះទាក់ទងទៅនឹងធាតុ ដែលត្រូវបានទទួលស្គាល់ពីគ្រាមុន នៅខាងក្រៅរបាយការណ៍ចំណេញ ឬខាត (សូមមើលកថាខណ្ឌ ៦៣) ។

## ធាតុដែលបានទទួលស្គាល់ខាងក្រៅប្រាក់ចំណេញឬខាត

៦១ [លុបចោល]

៦១ក **ពន្ធបច្ចុប្បន្ននិងពន្ធពន្យារត្រូវបានទទួលស្គាល់នៅខាងក្រៅប្រាក់ចំណេញ ឬខាតប្រសិនបើពន្ធទាក់ទង នឹងធាតុដែលត្រូវបានទទួលស្គាល់នៅក្នុងគ្រាដូចគ្នា ឬ នៅក្នុងគ្រាខុសគ្នា នៅខាងក្រៅរបាយការណ៍ចំណេញ ឬខាត ។ ដូច្នេះ ពន្ធបច្ចុប្បន្ន និងពន្ធពន្យារដែលពាក់ព័ន្ធនឹងធាតុត្រូវបានទទួលស្គាល់នៅក្នុងគ្រាដូចគ្នា ឬគ្រាខុសគ្នា:**

**(ក) នៅក្នុងចំណូលលម្អិតផ្សេងទៀត ត្រូវបានទទួលស្គាល់នៅក្នុងចំណូល លម្អិតផ្សេងទៀត (សូមមើល កថាខណ្ឌ៦២) ។**

**(ខ) នៅក្នុងគណនីមូលនិធិដោយផ្ទាល់ ត្រូវបានទទួលស្គាល់ដោយផ្ទាល់នៅក្នុងគណនីមូលនិធិ (សូមមើល កថាខណ្ឌ៦២ក) ។**

៦២ ស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាតម្រូវ ឬអនុញ្ញាត ធាតុជាក់លាក់ ដែលត្រូវបានទទួលស្គាល់នៅក្នុងចំណូលលម្អិតផ្សេងទៀត។ ឧទាហរណ៍នៃធាតុទាំងនោះគឺ÷

(ក) ការប្រែប្រួលតម្លៃពិតគណនេយ្យដែលកើតចេញពីការវាយតម្លៃនៃទ្រព្យ រោងចក្រ និងបរិក្ខារ (សូមមើល ស.គ.អ.ក១៦) និង

(ខ) [លុបចោល]

(គ) ភាពខុសគ្នាពីការប្តូរប្រាក់ ដែលកើតឡើងនៅពេលប្រែសំរួលរបាយការណ៍ហិរញ្ញវត្ថុនៃប្រតិបត្តិការបរទេស (សូមមើលស.គ.អ.ក ២១)។

(ឃ) [លុបចោល]

៦២ក ស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាតម្រូវ ឬអនុញ្ញាតនូវធាតុជាក់លាក់ដែលនឹងត្រូវចុះក្នុងផ្នែកឥណទាន ឬត្រូវបានដាក់បន្ទុកដោយផ្ទាល់ទៅគណនីមូលនិធិ។ ឧទាហរណ៍នៃធាតុទាំងនេះគឺ÷

(ក) ការកែសំរួលចំពោះសមតុល្យដើមគ្រានៃប្រាក់ចំណេញរក្សាទុកពីគោលនយោបាយគណនេយ្យដែលត្រូវបានអនុវត្តត្រឡប់ក្រោយ ឬការកែតម្រូវនៃកំហុស(សូមមើល ស.គ.អ.ក ៨

*គោលនយោបាយគណនេយ្យ ការផ្លាស់ប្តូរការប៉ាន់ស្មាន និងកំហុស)* និង

(ខ) ចំនួនទឹកប្រាក់ ដែលកើតឡើងនៅពេលការទទួលស្គាល់លើកដំបូងនៃសមាសធាតុមូលនិធិនៃ ឧបករណ៍ ហិរញ្ញវត្ថុផ្គួប (សូមមើលកថាខណ្ឌ ២៣) ។

៦៣ នៅក្នុងកាលៈទេសៈពិសេស អង្គភាពអាចពិបាកក្នុងការកំណត់ពីចំនួនទឹកប្រាក់នៃពន្ធបច្ចុប្បន្ននិងពន្ធពន្យារដែលទាក់ទិននឹងធាតុដែលបានទទួលស្គាល់ខាងក្រៅរបាយការណ៍ចំណេញ ឬខាត(អាចនៅក្នុងចំណូលលម្អិតផ្សេងទៀត ឬនៅក្នុងគណនីមូលនិធិដោយផ្ទាល់)។ នេះអាចជាករណីមួយនៅពេល ជាឧទាហរណ៍ៈ

(ក) មានអត្រាពន្ធលើប្រាក់ចំណូល និងវាមិនអាចទៅរួច ដើម្បីកំណត់ពីអត្រា ដែលសមាសធាតុជាក់លាក់នៃ ប្រាក់ចំណេញជាប់ពន្ធ (ប្រាក់ខាតពន្ធ) ត្រូវបានគិតពន្ធ

(ខ) ការផ្លាស់ប្តូរអត្រាពន្ធ ឬច្បាប់ពន្ធផ្សេងទៀតប៉ះពាល់ដល់ទ្រព្យ-សកម្ម ពន្ធពន្យារ ឬបំណុលពន្ធពន្យារ ដែលទាក់ទងនឹងធាតុមួយដែលត្រូវបាន ទទួលស្គាល់ខាងក្រៅរបាយការណ៍ចំណេញឬខាត ឬ

(គ) អង្គភាពមួយកំណត់ថាទ្រព្យសកម្មពន្ធពន្យារត្រូវបានទទួលស្គាល់ ឬមិនឈប់ទទួលស្គាល់ទាំងអស់ និងទ្រព្យសកម្មពន្ធពន្យារទាក់ទងនឹងធាតុដែលត្រូវបានទទួលស្គាល់ពីគ្រាមុននៅខាងក្រៅរបាយការណ៍ចំណេញ ឬខាត ។

នៅក្នុងករណីបែបនេះ ពន្ធពន្យារនិងពន្ធបច្ចុប្បន្នដែលមានទាក់ទងនឹងធាតុដែលត្រូវបានទទួលស្គាល់ខាងក្រៅរបាយការណ៍ចំណេញ ឬខាតត្រូវផ្អែក លើការបែងចែកតាមសមាមាត្រនៃពន្ធពន្យារ និងពន្ធបច្ចុប្បន្នរបស់អង្គភាព នៅក្នុងស្ថាប័នពន្ធពាក់ព័ន្ធ ឬវិធីសាស្ត្រផ្សេងទៀត ដែលសំរេចបាននូវការ បែងចែកសមស្របជាងមុននៅក្នុងកាលៈទេសៈទាំងអស់ ។

៦៤ ស.គ.អ.ក ១៦ មិនបញ្ជាក់ថាតើអង្គភាពមួយគួរផ្ទេរជារៀងរាល់ឆ្នាំពីការគណនីអតិរេកពីការវាយតម្លៃទៅគណនីប្រាក់ចំណេញរក្សាទុកនូវចំនួនទឹកប្រាក់ ដែលស្មើនឹងភាពខុសគ្នារវាង រំលស់/ដករំលស់លើ ទ្រព្យសកម្មវាយតម្លៃរួចនឹងរំលស់/ដករំលស់ដែលផ្អែកលើថ្លៃដើមនៃ ទ្រព្យសកម្មនោះ។ ប្រសិនបើអង្គភាពធ្វើការផ្ទេរបែបនេះ ទឹកប្រាក់ដែលផ្ទេរ គឺជាតម្លៃសុទ្ធនៃពន្ធពន្យារទាក់ទិន។ ការពិចារណាស្រដៀងគ្នាអនុវត្តចំពោះការផ្ទេរដែលបានធ្វើឡើងពេលលក់ចោលធាតុមួយនៃទ្រព្យ រោងចក្រ ឬឧបករណ៍ ។

៦៥ នៅពេលទ្រព្យសកម្មមួយត្រូវបានវាយតម្លៃឡើងសម្រាប់គោលបំណងពន្ធនិង ការវាយតម្លៃឡើងវិញនោះត្រូវពាក់ព័ន្ធនឹងការវាយតម្លៃឡើងវិញតាមគណនេយ្យនៃគ្រាមុន ឬចំពោះការវាយតម្លៃឡើងវិញតាមគណនេយ្យដែលត្រូវរំពឹងទុកនឹងអនុវត្តនៅក្នុងគ្រាអនាគត ឥទ្ធិពលពន្ធនៃការវាយតម្លៃឡើងវិញលើទ្រព្យសកម្ម និងការកែសំរួលនៃមូលដ្ឋានពន្ធត្រូវបានទទួលស្គាល់នៅក្នុងចំណូលលម្អិតផ្សេងទៀតនៅក្នុងគ្រាដែលពួកគេកើតឡើង ។ ប៉ុន្តែប្រសិនបើការវាយតម្លៃ សម្រាប់គោលបំណងពន្ធមិនត្រូវបានជាប់ពាក់ព័ន្ធនឹងការវាយ តម្លៃឡើងវិញតាមគណនេយ្យនៃគ្រាមុនទេ ឬ

ចំពោះការវាយតម្លៃឡើងវិញ តាមគណនេយ្យដែលត្រូវបានរំពឹងថា នឹងត្រូវបានប្រើនៅក្នុងគ្រាអនាគតទេ នោះឥទ្ធិពលនៃការកែសំរួលមូលដ្ឋានពន្ធត្រូវបានទទួលស្គាល់ នៅក្នុងរបាយការណ៍ចំណេញ ឬខាត ។

៦៥ក នៅពេលដែលអង្គភាពបង់ភាគលាភទៅឲ្យម្ចាស់ភាគហ៊ុន អង្គភាពអាចត្រូវបានតម្លៃឲ្យបង់ផ្នែកខ្លះ នៃភាគលាភទៅឲ្យអាជ្ញាធរពន្ធដារជំនួសម្ចាស់ភាគហ៊ុន។ នៅក្នុងប្រទេសជាច្រើនទឹកប្រាក់នេះត្រូវបានគេហៅថាពន្ធកាត់ទុក។ ទឹកប្រាក់ដែបានបង់ ឬនឹងត្រូវបង់ទៅឲ្យអាជ្ញាធរពន្ធត្រូវបានគិតបញ្ចូលទៅក្នុងគណនីដើមទុនដែលជាផ្នែកមួយនៃភាគលាភ ។

## ពន្ធពន្យារដែលកើតពីការបញ្ចូលអាជីវកម្មរួមគ្នា

៦៦ ដូចបានពន្យល់នៅក្នុងកថាខណ្ឌ១៩ និង២៦(គ) ភាពខុសគ្នាបណ្តោះអាសន្នអាចកើតឡើងនៅក្នុងការបញ្ចូលអាជីវកម្មរួមគ្នា។ ដោយអនុលោមតាម ស.រ.ហ.អ.ក ៣ អង្គភាពទទួលស្គាល់ទ្រព្យសកម្មពន្ធពន្យារដែលមាន(រហូតដល់តែទ្រព្យសកម្មពន្ធពន្យារនោះបំពេញលក្ខខណ្ឌលក្ខណៈវិនិច្ឆ័យទទួលស្គាល់នៅក្នុងកថាខណ្ឌ ២៤) ឬ បំណុលពន្ធពន្យារជាទ្រព្យសកម្ម និងបំណុលអាចកំណត់បាននៅថ្ងៃទិញ ។ នៅឆ្នាំបន្តបន្ទាប់ទ្រព្យសកម្ម ពន្ធពន្យារ និងបំណុលពន្ធពន្យារទាំងនោះប៉ះពាល់ដល់ទឹកប្រាក់ នៃមូលនិធិពាណិជ្ជកម្ម ឬ(Bargain Purchase gain) ដែលអង្គភាពទទួលស្គាល់ ។ ប៉ុន្តែអនុលោមតាមកថាខណ្ឌ ១៥(ក) អង្គភាពមិនទទួលស្គាល់បំណុល ពន្ធពន្យារដែលកើតឡើងពីការទទួលស្គាល់លើកដំបូងនៃមូលនិធិពាណិជ្ជកម្ម

៦៧ ជាលទ្ធផលនៃការបញ្ចូលអាជីវកម្មរួមគ្នា ភវនីយភាពនៃការទទួលស្គាល់ទ្រព្យសកម្មពន្ធពន្យារមិនការទិញអាជីវកម្មរបស់ក្រុមហ៊ុនទិញអាចផ្លាស់ប្តូរ ។ អង្គភាពទិញអាចពិចារណាថាវាទំនងថាវានឹងទទួលបានមកវិញនូវទ្រព្យសកម្មពន្ធពន្យារផ្ទាល់ខ្លួន ដែលមិនត្រូវបានទទួលស្គាល់មុនពេលបញ្ចូលអាជីវកម្មរួមគ្នា ។ ឧទាហរណ៍ អង្គភាពទិញអាចមានលទ្ធផលដើម្បីប្រើប្រាស់អត្ថប្រយោជន៍នៃប្រាក់ខាតពន្ធមិនបានប្រើទល់នឹងប្រាក់ចំណេញ ជាប់ពន្ធនាពេលអនាគតរបស់អង្គភាពលក់ ។ ជាជម្រើសជាលទ្ធផល នៃការបញ្ចូលអាជីវកម្មរួមគ្នា វាអាចមិនទំនងទៀតទេដែលថាប្រាក់ចំណេញជាប់ពន្ធអនាគតនឹងអនុញ្ញាតិឲ្យទ្រព្យសកម្មពន្ធពន្យារត្រូវទទួលបានមកវិញ ។ នៅក្នុងករណីបែបនេះ អង្គភាពទិញទទួលស្គាល់ការប្រែប្រួលនៅក្នុង ទ្រព្យសកម្មពន្ធពន្យារ នៅក្នុងគ្រានៃការបញ្ចូលអាជីវកម្មរួមគ្នា ប៉ុន្តែមិនបញ្ចូលទ្រព្យសកម្មពន្ធពន្យារជាផ្នែកនៃការធ្វើគណនេយ្យកម្មសម្រាប់ការបញ្ចូលអាជីវកម្មរួមគ្នា ។ ដូច្នេះ អង្គភាពទិញមិនពិចារណានៅក្នុងការវាស់វែង មូលនិធិពាណិជ្ជកម្ម ឬ Bargain Purchase gain ដែលអង្គភាពទទួលស្គាល់នៅក្នុងការបញ្ចូលអាជីវកម្មរួមគ្នា ។

៦៨ អត្ថប្រយោជន៍ ដែលមានសក្តានុពលនៃប្រាក់ខាតពន្ធលើប្រាក់ចំណូលរបស់អង្គភាពលក់ដែលយោងបន្តទៅខាងមុខ ឬទ្រព្យសកម្មពន្ធពន្យារមិនបំពេញលក្ខណៈវិនិច្ឆ័យ សម្រាប់ការទទួលស្គាល់ដាច់ដោយឡែកនៅពេលដែលការបញ្ចូលអាជីវកម្មរួមគ្នា ត្រូវបានគេកត់ត្រាលើកដំបូង ប៉ុន្តែការបញ្ចូលអាជីវកម្មរួមគ្នាអាចត្រូវបានទទួលស្គាល់នៅឆ្នាំបន្តបន្ទាប់។ អង្គភាព

ត្រូវទទួលស្គាល់អត្ថប្រយោជន៍ពន្ធពន្យារបានទិញ ដែលអង្គភាពទទួលស្គាល់បន្ទាប់ពីការបញ្ចូលអាជីវកម្មរួមគ្នាដូចខាងក្រោម÷

(ក) អត្ថប្រយោជន៍ពន្ធពន្យារបានទិញដែលបានទទួលស្គាល់នៅក្នុងគ្រា វាស់វែងដែលកើតចេញពីព័ត៌មានថ្មីអំពីហេតុការណ៍ និងកាលៈទេសៈ ដែលបានកើតនៅថ្ងៃទិញត្រូវបានប្រើដើម្បីកាត់បន្ថយតម្លៃពិតគណនេយ្យ នៃមូលនិធិពាណិជ្ជកម្មណាមួយដែលទាក់ទងនឹងការទិញអាជីវកម្មនោះ ។ ប្រសិនបើតម្លៃពិតគណនេយ្យនៃមូលនិធិពាណិជកម្មស្មើសូន្យ នោះ អត្ថប្រយោជន៍ពន្ធពន្យារ ដែលនៅសល់ត្រូវបានទទួលស្គាល់នៅក្នុងរបាយ-ការណ៍ចំណេញឬខាត ។

(ខ) គ្រប់អត្ថប្រយោជន៍ពន្ធពន្យារបានទិញដែលបានទទួលស្គាល់ត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ចំណេញ ឬខាត (ឬប្រសិនបើស្តង់ដារនេះតម្រូវឲ្យរាយការណ៍ខាងក្រៅរបាយការណ៍ចំណេញឬខាត) ។

## ពន្ធពន្យារ និងពន្ធបច្ចុប្បន្នដែលកើតចេញពីប្រតិបត្តិការទូទាត់ដោយភាគហ៊ុន

៦៨ក នៅក្នុងទីកន្លែងពន្ធខ្លះ អង្គភាពទទួលការកាត់ពន្ធ (ពោលគឺទឹកប្រាក់ដែលអាចកាត់កងបាននៅក្នុងការកំណត់ប្រាក់ចំណេញជាប់ពន្ធ) ដែលទាក់ទិននឹងប្រាក់កំរៃដែលបានបង់ជាភាគហ៊ុនសិទ្ធិពិសេសភាគហ៊ុន ឬឧបករណ៍ទុនផ្សេងទៀតរបស់អង្គភាព។ ទឹកប្រាក់នៃការកាត់បន្ថយពន្ធនោះអាចខុស

ពីចំណាយប្រាក់កំរៃប្ញូកបន្តពាក់ព័ន្ធ ហើយអាចកើតឡើងនៅក្នុងគ្រាគណនេយ្យក្រោយ ។ ឧទាហរណ៍ប្រទេសខ្លះ អង្គភាពមួយអាចទទួលស្គាល់ចំណាយសម្រាប់ការចំណាយលើការប្រើសេវារបស់និយោជិកដែលបានទទួលជាតម្លៃតបស្នង សម្រាប់សិទ្ធិភាគហ៊ុនពិសេសដែលបានផ្តល់ដោយអនុលោមតាម ស.រ.ហ.អ.ក ២ *ការទូទាត់ផ្អែកលើភាគហ៊ុន* និងមិនទទួលបានការកាត់បន្ថយពន្ធរហូតដល់ សិទ្ធិពិសេសត្រូវបានអនុវត្តជាមួយការវាស់វែងការកាត់បន្ថយពន្ធដែលផ្អែកលើតម្លៃភាគហ៊ុនរបស់អង្គភាពនៅថ្ងៃអនុវត្តសិទ្ធិ ។

៦៨ខ ដូចគ្នានឹងចំណាយលើការស្រាវជ្រាវ ដែលបានពិភាក្សារួចហើយនៅក្នុងកថាខណ្ឌ ៩ និង២៦(ខ) នៃស្តង់ដារនេះភាពខុសគ្នារវាងមូលដ្ឋានពន្ធនៃសេវានិយោជិកដែលបានទទួលមកត្រឹមថ្ងៃបិទបញ្ជី (ជាចំនួនទឹកប្រាក់ដែលអាជ្ញាធរពន្ធនឹងអនុញ្ញាតិជាការកាត់កងនៅក្នុងគ្រាអនាគត) និងតម្លៃពិតគណនេយ្យស្មើនឹងសូន្យ គឺជាភាពខុសគ្នាបណ្តោះអាសន្ន ដែលអាចកាត់កងបានដែលនាំឱ្យមានទ្រព្យសកម្មពន្ធពន្យារ ។ ប្រសិនបើទឹកប្រាក់ដែលអាជ្ញាធរពន្ធដារនឹងអនុញ្ញាតិជាការកាត់កងនៅក្នុងគ្រាអនាគត មិនត្រូវបានគេដឹងនៅចុងគ្រាទេនោះ ទឹកប្រាក់នោះត្រូវបានប៉ាន់ស្មានដោយផ្អែកលើអាជ្ញារធរពន្ធដារនៅចុងគ្រា។ ឧទាហរណ៍ ប្រសិនបើទឹកប្រាក់ដែលអាជ្ញាធរពន្ធដារនឹងអនុញ្ញាតិឱ្យកាត់កងនៅក្នុងគ្រាអនាគតគឺអាស្រ័យលើតម្លៃភាគហ៊ុនរបស់អង្គភាព នៅថ្ងៃនាពេលអនាគត នោះការវាស់វែងនៃ ភាពខុសគ្នាបណ្តោះអាសន្ន អាចកាត់កងបានត្រូវបានផ្អែកតម្លៃភាគហ៊ុនរបស់អង្គភាពនៅចុងក្រោយ។

៦៨គ ដូចបានកំណត់ចំណាំនៅក្នុងកថាខណ្ឌ៦៨ក ទឹកប្រាក់នៃការកាត់កងពន្ធ (ឬ ការកាត់កងពន្ធបានប៉ាន់ស្មាន សម្រាប់ពេលអនាគត ដែលបាន វាស់វែង តាមកថាខណ្ឌ ៦៨ខ ) អាចខុសពីចំណាយលើប្រាក់កំរៃបូកបន្ថែមដែលទាក់ទិន។ កថាខណ្ឌ ៥៨ នៃស្តង់ដារនៃតម្រូវថាពន្ធពន្យារ និងពន្ធបច្ចុប្បន្ន ត្រូវបានគេទទួលស្គាល់ជាចំណូល ឬចំណាយហើយ ត្រូវបានបញ្ចូលក្នុង របាយការណ៍ចំណេញ ឬខាតសម្រាប់គ្រាលើកលែងរហូតដល់តែពន្ធកើត

ឡើងពីប្រតិបត្តិការឬព្រឹត្តិការដែលត្រូវបានទទួលស្គាល់ នៅក្នុងគ្រាដូចគ្នា ឬនៅក្នុងគ្រាខុសគ្នា ខាងក្រៅរបាយការណ៍ចំណេញឬខាត ឬ(ខ)ការបញ្ចូលអាជីវកម្មរួមគ្នា ។ ប្រសិនបើទឹកប្រាក់នៃការកាត់កងពន្ធ (ឬ ការកាត់កងពន្ធបានប៉ាន់ស្មានសម្រាប់ពេលអនាគត)

លើសទឹកប្រាក់នៃចំណាយ ប្រាក់កំរៃបូកបន្ថែមពាក់ព័ន្ធនេះបង្ហាញថា ការកាត់ប្រាក់ពន្ធទាក់ទិនមិនតែ ចំពោះចំណាយលើប្រាក់កំរៃ ប៉ុន្តែក៏ចំពោះធាតុនៃគណនីមូលនិធិផងដែរ។ នៅក្នុងស្ថានភាពនេះ ផ្នែកលើសនៃពន្ធបច្ចុប្បន្ន ឬពន្ធពន្យារ ដែលជាប់ ពាក់ពន្ធ័ត្រូវ បានទទួលស្គាល់ដោយផ្ទាល់នៅក្នុងគណនីមូលនិធិ ។

## ការបង្ហាញ

### ទ្រព្យសកម្មពន្ធ និង បំណុលពន្ធ

៦៩-៧០ [លុបចោល]

**កាត់កង**

**៧១ អង្គភាពមួយត្រូវកាត់កងទ្រព្យសកម្មពន្ធបច្ចុប្បន្ន និងបំណុលពន្ធបច្ចុប្បន្ន ប្រសិនបើ និងប្រសិនបើតែអង្គភាពៈ**

**(ក) មានសិទ្ធិតាមផ្លូវច្បាប់ដើម្បីកាត់កងទឹកប្រាក់ដែលបានទទួលស្គាល់ និង**

**(ខ) មានបំណងទូទាត់តាមមូលដ្ឋានសុទ្ធ ឬ មានបំណងនឹងទទួលស្គាល់ទ្រព្យសកម្មនិងទូទាត់បំណុលស្របពេលជាមួយគ្នា ។**

៧២ ទោះបីទ្រព្យសកម្មពន្ធបច្ចុប្បន្ន និងបំណុលពន្ធបច្ចុប្បន្នត្រូវបានទទួលស្គាល់និងវាស់វែងដាច់ដោយឡែក ក៏ពួកគេត្រូវបានកាត់កងនៅក្នុងរបាយ-ការណ៍ស្ថានភាពហិរញ្ញវត្ថុដែលជាកម្មវត្ថុនៃលក្ខណៈវិនិច្ឆ័យដែលស្រដៀងទៅនឹងលក្ខណៈវិនិច្ឆ័យ ដែលបាន បង្កើតសម្រាប់ឧបករណ៍ហិរញ្ញវត្ថុនៅក្នុង ស.គ.អ.ក ៣២ ។ អង្គភាពមួយ ជាធម្មតានឹងមានសិទ្ធិតាមផ្លូវច្បាប់ ដើម្បីកាត់កងទ្រព្យសកម្មពន្ធពន្យារទល់នឹងបំណុលពន្ធបច្ចុប្បន្ននៅពេលដែលពន្ធទាំងនោះទាក់ទិននឹងពន្ធលើ ប្រាក់ចំណូល ដែលកំណត់ដោយ អាជ្ញាធរពន្ធដូចគ្នា និងអាជ្ញាធរពន្ធ អនុញ្ញាតិឲ្យអង្គភាពដើម្បីទូទាត់ ឬ ទទួលការសងទោលសុទ្ធ ។

៧៣ នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរួម ទ្រព្យសកម្មពន្ធបច្ចុប្បន្ននៃអង្គភាពមួយនៅក្នុងក្រុមត្រូវបានកាត់កងទល់នឹងបំណុលពន្ធបច្ចុប្បន្ននៃអង្គភាពផ្សេងទៀតនៅក្នុងក្រុម ប្រសិនបើនិងតែប្រសិនបើ អង្គភាពដែលពាក់ព័ន្ធមាន

សិទ្ធិអំណាចផ្លូវច្បាប់ ដើម្បីធ្វើការទូទាត់ឬទទួលការទូទាត់ទោលសុទ្ធ ហើយ អង្គភាពមានបំណងនឹងធ្វើការទូទាត់ ឬទទួលការទូទាត់តាម របៀបសុទ្ធ ឬនឹងទទួលបានមកវិញនូវទ្រព្យសកម្មនិងទូទាត់បំណុលស្របពេលជាមួយគ្នា។

**៧៤** **អង្គភាពមួយត្រូវកាត់កងទ្រព្យសកម្មពន្ធពន្យារនិងបំណុលពន្ធពន្យារ ប្រសិន និងតែប្រសិនបើៈ**

(ក) **អង្គភាពមានសិទ្ធិតាមផ្លូវច្បាប់ដើម្បីកាត់កងទ្រព្យសកម្មពន្ធបច្ចុប្បន្ន ទល់នឹងបំណុលពន្ធបច្ចុប្បន្ន និង**

(ខ) **ទ្រព្យសកម្មពន្ធពន្យារ និងបំណុលពន្ធពន្យារទាក់ទិននឹងពន្ធលើប្រាក់ ចំណូលដែលកំណត់ដោយអាជ្ញាធរពន្ធ លើៈ**

**(១)** **អង្គភាពជាប់ពន្ធដូចគ្នា ឬ**

**(២)** **អង្គភាពជាប់ពន្ធខុសគ្នាដែលមានបំណងទូទាត់បំណុលពន្ធបច្ចុប្បន្ន និងទ្រព្យសកម្មពន្ធ**

**បច្ចុប្បន្នតាមមូលដ្ឋានសុទ្ធ ឬដើម្បីទទួលស្គាល់ទ្រព្យសកម្ម និងទូទាត់បំណុលស្របពេលគ្នា នៅក្នុងគ្រាអនាគតនីមួយៗ ដែលទឹកប្រាក់ធំៗនៃបំណុលពន្ធពន្យារ ឬទ្រព្យសកម្មពន្ធពន្យារត្រូវបាន រំពឹងថានឹងត្រូវទូទាត់ឬនឹងត្រូវទទួលបានមកវិញ ។**

៧៥ ដើម្បីជៀសវាងតម្រូវការលើការកំណត់ពេលវេលាលម្អិតនៃការត្រឡប់វិញនៃភាពខុសគ្នាបណ្តោះអាសន្ន ស្តង់ដារនេះតម្រូវឲ្យអង្គភាពធ្វើការកាត់កង ពន្ធពន្យារទល់នឹងបំណុលពន្ធពន្យារនៃអង្គភាព

ជាប់ពន្ធដូចគ្នា ប្រសិនបើ និងតែប្រសិនបើ ពន្ធទាំងនោះទាក់ទងនឹងពន្ធលើប្រាក់ចំណូល ដែលកំណត់ដោយអាជ្ញាធរពន្ធដូចគ្នា ហើយអង្គភាពមានសិទ្ធិតាមផ្លូវច្បាប់ ដើម្បីកាត់កងទ្រព្យសកម្មពន្ធបច្ចុប្បន្នទល់នឹងបំណុលពន្ធបច្ចុប្បន្ន ។

៧៦ នៅក្នុងកាលៈទេសៈដ៏កម្រ អង្គភាពអាចមានសិទ្ធិតាមផ្លូវច្បាប់នៃការកាត់កង និងគោលបំណងដើម្បីទូទាត់ចំនួនសុទ្ធ សម្រាប់គ្រាមួយចំនួន ប៉ុន្តែមិន សម្រាប់គ្រាផ្សេងទេ។ នៅក្នុងកាលៈទេសៈដ៏កំរបែបបេះការកំណត់តារាង ពេលវេលាលម្អិតអាចត្រូវបានតម្រូវឱ្យបង្កើតប្រកបដោយជឿជាក់ថា តើ បំណុលពន្ធពន្យារនៃអង្គភាពជាប់ពន្ធមួយនឹងឱ្យមានការបង់ពន្ធកើតឡើងនៅក្នុងគ្រាដូចគ្រាដែលទ្រព្យសកម្មពន្ធពន្យារនៃអង្គភាពជាប់ពន្ធផ្សេងមួយទៀត នឹងនាំឱ្យមានការបង់ពន្ធថយចុះដោយអង្គភាពជាប់ពន្ធទី២ ។

**ចំណាយពន្ធ**

**ចំណាយពន្ធ (ចំណូល) ដែលទាក់ទងនឹងរបាយការណ៍ចំណេញ ឬខាតពីសកម្មភាពធម្មតា**

**៧៧ ចំណាយពន្ធ(ចំណូល) ដែលទាក់ទងនឹងរបាយការណ៍ចំណេញ ឬខាតពីសកម្មធម្មតាត្រូវបានបង្ហាញ នៅក្នុងរបាយការណ៍លទ្ធផលលម្អិត ។**

**៧៧ក ប្រសិនបើអង្គភាពមួយបង្ហាញសមាសធាតុនៃរបាយការណ៍ចំណេញ ឬខាតនៅក្នុងរបាយការណ៍លទ្ធផលដាច់ដោយឡែកដូចបានរៀបរាប់នៅក្នុងកថាខណ្ឌ៨១ នៃ ស.គ.អ.ក ១ *ការបង្ហាញរបាយការណ៍ហិរញ្ញវត្ថុ* (បានកែប្រែក្នុង ឆ្នាំ២០០៧) វាតំណាងឱ្យចំណាយពន្ធ (ចំណូល)**

**ដែលទាក់ទងនឹងប្រាក់ចំណេញ ឬខាតពីសកម្មភាពធម្មតានៅក្នុងរបាយ-ការណ៍ ដាច់ដោយឡែកនោះ។**

**ភាពខុសគ្នាពីការប្តូរប្រាក់លើបំណុល និងទ្រព្យសកម្មពន្ធពន្យាបរទេស**

៧៨ ស.គ.អ.ក ២១ តម្រូវឱ្យភាពខុសគ្នាពីការប្តូរប្រាក់ជាក់លាក់ត្រូវបានទទួលស្គាល់ជាចំណូល ឬចំណាយប៉ុន្តែមិនបានបញ្ជាក់ពីភាពខុសគ្នានោះត្រូវបានបង្ហាញនៅក្នុងរបាយការណ៍លទ្ធផលលម្អិតនោះទេ។ ដូច្នេះពេលភាពខុសគ្នាពីការប្តូរប្រាក់លើបំណុល ឬទ្រព្យសកម្មពន្ធពន្យារបរទេសត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍លទ្ធផលលម្អិត នោះភាពខុសគ្នាអាចត្រូវបានចាត់ថ្នាក់ជាចំណាយពន្ធពន្យារ (ចំណូល) ប្រសិនបើការបង្ហាញត្រូវបានចាត់ទុកថាមានប្រយោជន៍ខ្លាំងបំផុតចំពោះអ្នកប្រើប្រាស់របាយ-ការណ៍ហិរញ្ញវត្ថុ។

## ការលាតត្រដាង

**៧៩ សមាសធាតុសំខាន់ៗនៃចំណាយពន្ធ (ចំណូល) ត្រូវបានលាតត្រដាងដាច់ដោយឡែក ។**

៨០ សមាសធាតុនៃចំណាយពន្ធ (ចំណូល) អាចបញ្ចូលៈ

(ក) ចំណាយពន្ធបច្ចុប្បន្ន (ចំណូល)

(ខ)

ការកែសំរួលណាមួយដែលបានទទួលស្គាល់នៅក្នុងគ្រាសម្រាប់ពន្ធ បច្ចុប្បន្ននៃគ្រាមុន

(គ) ទឹកប្រាក់នៃចំណាយ (ចំណូល) ពន្ធពន្យារដែលទាក់ទងនឹងការបង្កើត និងការត្រឡប់វិញនៃភាពខុសគ្នាបណ្ដោះអាសន្ន

(ឃ) ទឹកប្រាក់នៃចំណាយ (ចំណូល) ពន្ធពន្យារ ដែលទាក់ទងនឹងការផ្លាស់ប្ដូរអត្រាពន្ធ ឬ ការការតាក់តែង ពន្ធថ្មី

(ង) ទឹកប្រាក់នៃអត្ថប្រយោជន៍ដែលកើតឡើងពីប្រាក់ខាតពន្ធមិនបានទទួលស្គាល់ឥណទានពន្ធ ឬភាពខុសគ្នាបណ្ដោះអាសន្ននៃគ្រាមុនដែលត្រូវបានប្រើដើម្បីកាត់បន្ថយចំណាយពន្ធបច្ចុប្បន្ន

(ច) ទឹកប្រាក់នៃអត្ថប្រយោជន៍ពីប្រាក់ខាតពន្ធមិនបានទទួលស្គាល់ឥណទានពន្ធ ឬភាពខុសគ្នាបណ្ដោះអាសន្ននៃគ្រាមុន ដែលត្រូវបានប្រើ ដើម្បីកាត់បន្ថយចំណាយពន្ធពន្យារ

(ឆ) ចំណាយពន្ធពន្យារដែលកើតចេញពីការធ្លាក់ចុះតម្លៃ ឬការត្រឡប់វិញនៃការធ្លាក់ចុះតម្លៃគ្រាមុន នៃទ្រព្យសកម្មពន្ធពន្យារដោយអនុលោមតាម កថាខណ្ឌ ៥៦ និង

(ជ) ទឹកប្រាក់នៃចំណាយពន្ធ (ចំណូល) ដែលទាក់ទងនឹងការផ្លាស់ប្ដូរទាំងនោះនៅក្នុង គោលនយោបាយគណនេយ្យ និងកំហុសឆ្គងដែលត្រូវបាន បញ្ចូលនៅក្នុងរបាយការណ៍ចំណេញ ឬខាតដោយអនុលោមតាម ស.គ.អ.ក ៨ ពីព្រោះពួកគេអាចមិនអាចត្រូវបានកត់ត្រាត្រឡប់ថយ ក្រោយទេ ។

៨១ **ខាងក្រោមត្រូវបានលាតត្រដាងដាច់ដោយផងដែរនូវ÷**

(ក) ប្រាក់ពន្ធពន្យារ និងប្រាក់ពន្ធបច្ចុប្បន្នសរុបដែលទាក់ទងនឹងធាតុដែល ត្រូវបានគិតបញ្ចូល ឬ ចុះខាងឥណទាន ដោយផ្ទាល់ទៅក្នុង មូលនិធិ (សូមមើល កថាខណ្ឌ ៦២ក)

(ក១) ទឹកប្រាក់នៃពន្ធលើប្រាក់ចំណូលដែលទាក់ទងនឹងសមាសធាតុនីមួយៗ នៃចំណូលលម្អិតផ្សេងទៀត (សូមមើល កថាខណ្ឌ៦២ និង ស.គ.អ.ក ១ (បានកែប្រែក្នុងឆ្នាំ ២០០៧)

(ខ) [លុបចោល]

(គ) ការពន្យល់នៃទំនាក់ទំនងរវាងចំណាយពន្ធ (ចំណូល) និងប្រាក់ចំណេញគណនេយ្យនៅក្នុងទម្រង់ មួយឬទាំងពីរៈ

(១) ការសម្របសម្រួលលេខរវាងចំណាយពន្ធ (ចំណូល) និងផលិតផលនៃប្រាក់ចំណេញគណនេយ្យគុណ នឹងអត្រាពន្ធដែលអាចប្រើបានដោយបង្ហាញពីមូលដ្ឋានដែលអត្រាពន្ធត្រូវបានគណនាផង ឬ

(២) ការសម្របសម្រួលលេខរវាងអត្រាពន្ធមធ្យមមានប្រសិទ្ធិភាព និងអត្រាពន្ធដែលអាចអនុវត្តបានដោយបង្ហាញផងដែរពីមូលដ្ឋានដែលអត្រាពន្ធអាចអនុវត្តបានត្រូវបានគណនា

(ឃ) ការពន្យល់ពីការផ្លាស់ប្តូរអត្រាពន្ធដែលអាចអនុវត្តបានដោយប្រៀប ធៀបទៅនឹងគ្រាគណនេយ្យមុន

(ង) ទឹកប្រាក់ (និងថ្ងៃអស់សុពលភាព ប្រសិនបើមាន) នៃភាពខុសគ្នាបណ្តោះអាសន្នដែលអាចកាត់កងបាន ប្រាក់ខាតពន្ធដែល

មិនបានប្រើ និង ឥណទានពន្ធដែលមិនបានប្រើដែលមិនមានទ្រព្យសកម្មពន្ធពន្យារ ត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ

(ច) ទឹកប្រាក់សរុបនៃភាពខុសគ្នាដែលជាប់ពាក់ពន្ធ័នឹងការវិនិយោគនៅក្នុងក្រុមហ៊ុនបុត្រសម្ព័ន្ធ សាខា និងក្រុមហ៊ុនញាតិសម្ព័ន្ធ និងភាគកម្ម នៅក្នុងក្រុមហ៊ុនរួមទុន ដែលបំណុលពន្ធពន្យារមិនត្រូវបានទទួលស្គាល់ (សូមមើកថាខណ្ឌ៣៩)

(ឆ) ទាក់ទងនឹងប្រភេទនីមួយៗនៃភាពខុសគ្នាបណ្តោះអាសន្ន និងទាក់ទង នឹងប្រភេទនីមួយនៃប្រាក់ខាតពន្ធមិនបានប្រើនិងឥណទានពន្ធមិនបានប្រើៈ

(១) ទឹកប្រាក់នៃទ្រព្យសកម្មពន្ធពន្យារ និងបំណុលពន្ធពន្យារ ដែលបាន ទទួលស្គាល់នៅក្នុងរបាយការណ៍ ស្ថានភាពហិរញ្ញវត្ថុសម្រាប់គ្រានីមួយៗ ដែលបានដាក់បង្ហាញ

(២) ទឹកប្រាក់នៃចំណូលពន្ធពន្យារ ឬចំណាយពន្ធពន្យារ ដែលបានទទួលស្គាល់នៅក្នុងរបាយការណ៍ប្រាក់ចំណេញ ឬខាតប្រសិនបើនេះមិនកើតចេញពីការផ្លាស់ប្តូរនៅក្នុងទឹកប្រាក់ដែលបានទទួលស្គាល់នៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ

(ជ) ទាក់ទងនឹងប្រតិបត្តិការមិនបន្ត ចំណាយពន្ធដែលទាក់ទងនឹងៈ

(១) ចំណេញ ឬខាតពីភាពមិនបន្ត និង

(២) ប្រាក់ចំណេញឬខាតពីសកម្មភាពធម្មតានៃប្រតិបត្តិការមិនបន្តពីគ្រារួមជាមួយទឹកប្រាក់ស្របគ្នាសម្រាប់គ្រាមុននីមួយៗ ដែល បានដាក់បង្ហាញ

(ឈ) ទឹកប្រាក់នៃផលវិបាកពន្ធលើប្រាក់ចំណូលនៃភាគលាភចំពោះម្ចាស់ភាគហ៊ុនរបស់អង្គភាពដែលត្រូវបានស្នើសុំឬប្រកាសឱ្យដឹងមុនពេលរបាយការណ៍ហិរញ្ញវត្ថុត្រូវបានអនុញ្ញាតឱ្យបោះផ្សាយ ប៉ុន្តែមិនត្រូវបាន ទទួលស្គាល់ជាបំណុលនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុទេ ។

(ញ) ប្រសិនបើការបញ្ចូលអាជីវកម្មរួមគ្នាដែលអង្គភាពគឺជាអង្គភាពទិញបង្កឱ្យមានការផ្លាស់ប្តូរក្នុងទឹកប្រាក់ ដែលបានទទួលស្គាល់សម្រាប់ទ្រព្យសកម្ម ពន្ធពន្យារមុនពេលទិញ (សូមមើលកថាខណ្ឌ ៦៧) ទឹកប្រាក់នៃការផ្លាស់ ប្តូរនោះនឹង

(ដ) ប្រសិនបើអត្ថប្រយោជន៍ពន្ធពន្យារដែលបានទិញនៅក្នុងការបញ្ចូលអាជីវកម្មរួមគ្នាមិនត្រូវបានទទួលស្គាល់នៅថ្ងៃទិញ ប៉ុន្តែកាលៈទេសៈ ដែលបណ្តាលឱ្យមានអត្ថប្រយោជន៍ពន្ធពន្យារនឹងត្រូវបានទទួលស្គាល់ ។

៨២ អង្គភាពមួយត្រូវលាតត្រដាងទឹកប្រាក់នៃទ្រព្យសកម្មពន្ធពន្យារ និងលក្ខណៈ នៃភស្តុតាងដែលគាំដល់ ការទទួលស្គាល់ពេល÷

(ក) ការប្រើប្រាស់នៃទ្រព្យសកម្មពន្ធពន្យារផ្អែកលើប្រាក់ចំណេញជាប់ពន្ធនាពេលអនាគតលើសប្រាក់ចំណេញដែលកើតចេញពី

ការត្រឡប់វិញនៃភាព ខុសគ្នាបណ្តោះអាសន្នជាប់ពន្ធដែលមានស្រាប់និង

(ខ) អង្គភាពបានរងការខាតបង់នៅក្នុងគ្រាបច្ចុប្បន្នឬគ្រាខាងមុខ នៅក្នុងទីកន្លែងពន្ធចំពោះទ្រព្យសកម្មពន្ធ ពន្យារមានការ ពាក់ព័ន្ធ ។

៨២ក នៅក្នុងហេតុការណ៍ដែលបានរៀបរាប់នៅក្នុងកថាខណ្ឌ ៥២ក អង្គភាពត្រូវលាតត្រដាងពីលក្ខណៈនៃវិបាកពន្ធលើប្រាក់ចំណេញដែលមានសក្តានុពល ដែលអាចកើតចេញពីការទូទាត់ភាគលាភទៅឱ្យ ម្ចាស់ហ៊ុន។ លើសពីនេះទៅទៀត អង្គភាពត្រូវលាតត្រដាងពីទឹកប្រាក់នៃវិបាកពន្ធលើប្រាក់ចំណូលដែលមាន សក្តានុពលដែលជាក់ស្តែងអាចកំណត់បាន និងថាតើមានវិបាកពន្ធលើប្រាក់ចំណូលដែលមានសក្តានុពលណាមួយដែលមិនអាចកំណត់បាន ។

៨៣ [លុបចោល]

៨៤ ការលាតត្រដាងដែលតម្រូវដោយ កថាខណ្ឌ ៨១(គ) ផ្តល់លទ្ធផលឱ្យអ្នកប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុដើម្បីយល់ថាទំនាក់ទំនងរវាងចំណាយពន្ធ (ចំណូល) និងប្រាក់ចំណេញគណនេយ្យគឺមិនមានភាពប្រក្រតី និងដើម្បីយល់កត្តាសំខាន់ៗ ដែលអាចប៉ះពាល់ដល់ទំនាក់ទំនងនោះក្នុងពេលអនាគត ។ ទំនាក់ទំនងរវាងចំណាយពន្ធ(ចំណូល) និងប្រាក់ចំណេញគណនេយ្យអាចប៉ះពាល់ដោយកត្តាទាំងឡាយដូចចំណូលដែលត្រូវបានលើកលែងពន្ធចំណាយ ដែលមិនអាចកាត់កងបាននៅក្នុងការកំណត់ប្រាក់ចំណេញជាប់ពន្ធ (ប្រាក់ខាតពន្ធ) ឥទ្ធិពលនៃអត្រាពន្ធបរទេស ។

៨៥ ក្នុងការពន្យលពីទំនាក់ទំនងរវាងចំណាយពន្ធ(ចំណូល) និងប្រាក់ចំណេញគណនេយ្យអង្គភាពមួយប្រើអត្រាពន្ធ ដែលអាចអនុវត្តបានដែលផ្តល់ព័ត៌មានមាន អត្ថន័យខ្លាំងបំផុតទៅឲ្យ អ្នកប្រើប្រាស់របាយការណ៍ហិរញ្ញ-វត្ថុ ។ ជាញឹកញាប់ អត្រាដែលមានអត្ថន័យច្រើនបំផុត គឺជាអត្រាពន្ធក្នុងប្រទេសដែលអង្គភាពតាំងនៅ ដោយសរុបបញ្ចូលអត្រាពន្ធ ដែលបានប្រើសម្រាប់ពន្ធថ្នាក់ជាតិជាមួយនឹងអត្រា
ដែលបានប្រើសម្រាប់ពន្ធក្នុងប្រទេស
ដែលត្រូវបានគណនាជាសំខាន់លើកម្រិតស្រដៀងគ្នានៃកម្រិតប្រាក់ចំណេញ (ប្រាក់ខាតពន្ធ)ជាប់ពន្ធ ។ ប៉ុន្តែសម្រាប់អង្គភាពមួយដែលកំពុងប្រតិបត្តិការ នៅក្នុងប្រទេសមួយចំនួន វាអាចកាន់តែមានប្រយោជន៍ក្នុងបញ្ចូលគ្នានូវ ការសម្របសម្រួលដាច់ដោយឡែក ដែលបានរៀបចំដោយប្រើអត្រាពន្ធក្នុងស្រុកនៅក្នុងប្រទេស នីមួយៗ។ ឧទាហរណ៍ខាងក្រោមនិងពន្យល់ពីរបៀប ដែលការជ្រើសរើសនៃអត្រាពន្ធដែលអាចអនុវត្តបានប៉ះពាល់ ដល់ការ បង្ហាញនៃការសម្របសម្រួលជាលេខ ។

| **ឧទាហរណ៍ដែលពន្យល់កថាខណ្ឌ ៨៥** |
|---|
| នៅក្នុងឆ្នាំ ១៩ X ២ អង្គភាពមួយមានប្រាក់ចំណេញគណនេយ្យនៅក្នុងប្រទេសផ្ទាល់របស់គេ (ប្រទេស ក) ១៥០០ (ឆ្នាំ១៩X១: ២០០០) និងនៅក្នុងប្រទេស ខ ១៥០០ (១៩x១: ៥០០) ។ អត្រាពន្ធ ៣០% នៅក្នុងប្រទេស ក និង ២០% នៅក្នុងប្រទេស ខ។ នៅក្នុងប្រទេស ក ចំណាយស្មើនឹង១០០ (១៩x១:២០០) មិនអាចកាត់កងបានសម្រាប់ |

គោលបំណងពន្ធ។

ខាងក្រោមគឺជាឧទាហរណ៍នៃការសម្របសម្រួលនៃអត្រាពន្ធក្នុងប្រទេស។

| | ១៩X១ | ១៩X២ |
|---|---|---|
| ប្រាក់ចំណេញគណនេយ្យ | 2,500 | 3,000 |
| ពន្ធតាមអត្រាក្នុងប្រទេស 30% | 750 | 900 |
| ឥទ្ធិពលពន្ធនៃចំណាយដែលមិនអាចកាត់កងបានសម្រាប់គោល បំណងពន្ធ | 60 | 30 |
| ឥទ្ធិពលនៃអត្រាពន្ធទាបជាងនៅក្នុងប្រទេស ខ | (50) | (150) |
| ចំណាយពន្ធ | 760 | 780 |

ខាងក្រោម គឺជាឧទាហរណ៍នៃការសម្របសម្រួលដែលត្រូវបានរៀបចំដោយការ បញ្ចូលគ្នានូវការសម្របសម្រួលដាច់ដោយឡែកសម្រាប់ប្រទេសនីមួយៗ។ ក្រោមវិធីសាស្ត្រនេះ ឥទ្ធិពលនៃភាពខុសគ្នារវាងអត្រាពន្ធក្នុងប្រទេសរបស់អង្គភាពរាយការណ៍ និងអត្រាពន្ធក្នុងស្រុក នៅក្នុងទីកន្លែងផ្សេងទៀតមិនកើតឡើងជាធាតុដាច់ដោយឡែកទេនៅក្នុងការសម្របសម្រួល។ អង្គភាពមួយអាចត្រូវការដើម្បី ពិភាក្សាពីឥទ្ធិពលនៃការផ្លាស់ប្តូរសំខាន់ៗនៅក្នុងអត្រាពន្ធ ឬនៅក្នុងការបញ្ចូលគ្នានៃប្រាក់ចំណេញដែលបានរកបាននៅក្នុងទីកន្លែងផ្សេងគ្នា ដើម្បីពន្យល់ពីការផ្លាស់ប្តូរនៅក្នុងអត្រាពន្ធ ដែល

*អាចអនុវត្តបាន ដូចបានរៀបរាប់នៅក្នុងកថាខណ្ឌ ៨១(ឃ)។*

| | | |
|---|---|---|
| *ប្រាក់ចំណេញគណនេយ្យ* | *2,500* | *3,000* |
| *ពន្ធតាមអត្រាក្នុងស្រុកដែលអនុវត្តចំពោះប្រាក់ចំណេញ នៅក្នុងប្រទេសដែលបានពាក់ព័ន្ធ* | *700* | *750* |
| *ឥទ្ធិពលពន្ធនៃចំណាយដែលមិនអាចកាត់កងបានសម្រាប់គោលបំណងពន្ធ* | *60* | *30* |
| *ចំណាយពន្ធ* | *760* | *780* |

៨៦ អត្រាមធ្យមប្រសិទ្ធិភាពគឺជាចំណាយពន្ធ (ចំណូល) ដែលចែកដោយប្រាក់ចំណេញគណនេយ្យ។

៨៧ ជាញឹកញាប់វាមិនអាចអនុវត្តបានទេក្នុងការគណនាទឹកប្រាក់នៃបំណុលពន្ធពន្យារដែលបានទទួលស្គាល់ ដែលកើតចេញពីការវិនិយោគនៅក្នុងក្រុមហ៊ុនបុត្រសម្ព័ន្ធសាខា និងក្រុមហ៊ុនញ្ញាតិសម្ព័ន្ធ និងភាគកម្មនៅក្នុងក្រុមហ៊ុនរួមទុន (សូមមើលកថាខណ្ឌ៣៩) ។ ដូច្នេះ ស្តង់ដារនេះតម្រូវឱ្យអង្គភាពមួយលាតត្រដាង ពីទឹកប្រាក់សរុបនៃភាពខុសគ្នាបណ្តោះអាសន្នកំពុងប្រើ ប៉ុន្តែមិនតម្រូវឱ្យមានការលាតត្រដាងនៃបំណុលពន្ធពន្យារ។ ទោះ បីជាយ៉ាងណាក៏ដោយពេលដែលអាចអនុបាន អង្គភាពត្រូវបានលើកទឹក ចិត្តឱ្យលាតត្រដាងទឹកប្រាក់នៃបំណុលពន្ធពន្យារដែល

មិនបានទទួល ស្គាល់ ពីព្រោះអ្នកប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុអាចយល់ឃើញថា ព័ត៌មានបែបនេះអាចមានប្រយោជន៍។

៨៧ក កថាខណ្ឌ ៨២ក តម្រូវឱ្យអង្គភាពមួយលាតត្រដាងពីលក្ខណៈនៃវិបាកពន្ធលើប្រាក់ចំណេញដែលមានសក្តានុពលដែលនឹងកើតចេញពីការបង់ ភាគលាភទៅឱ្យម្ចាស់ភាគហ៊ុន។ អង្គភាពមួយលាតត្រដាងពីលក្ខណៈសំខាន់ៗនៃប្រព័ន្ធពន្ធលើប្រាក់ចំណូល និងកត្តាដែលនឹងមានឥទ្ធិពលលើ ទឹកប្រាក់នៃវិបាកពន្ធលើប្រាក់ចំណេញដែលមានសក្តានុពលនៃភាគលាភ ។

៨៧ខ ពេលខ្លះអាចនឹងមិនអាចអនុវត្តបានដើម្បីគណនាទឹកប្រាក់សរុបនៃវិបាកពន្ធលើប្រាក់ចំណូលដែលមានសក្តានុពលដែលអាចកើតចេញពីការបង់ភាគលាភទៅឱ្យម្ចាស់ភាគហ៊ុន ។ នេះអាចជាករណីមួយ ឧទាហរណ៍ថានៅពេលអង្គភាពមានចំនួនក្រុមហ៊ុនបុត្រសម្ព័ន្ធក្រៅប្រទេសច្រើន។ ប៉ុន្តែទោះបីជានៅក្នុងកាលៈទេសៈ បែបនេះក៏ដោយក៏ផ្នែកខ្លះនៃទឹកប្រាក់សរុបអាចកំណត់បានដោយងាយ ។ ឧទាហរណ៍ នៅក្នុងបណ្តុំក្រុមហ៊ុនរួមក្រុមហ៊ុនមេ និងក្រុមហ៊ុនបុត្រសម្ព័ន្ធខ្លះអាចបង់ពន្ធលើប្រាក់ចំណូលតាមអត្រាខ្ពស់លើប្រាក់ចំណេញមិនទាន់បែងចែក ហើយអាចដឹងពីទឹកប្រាក់ដែល នឹងអាចត្រូវបង្វិលសងវិញនៅលើការទូទាត់ នៃភាគលាភអនាគតចំពោះម្ចាស់ភាគហ៊ុនពីប្រាក់ចំណេញរក្សាទុករួម ។ នៅក្នុងករណីនេះទឹកប្រាក់ អាចបង្វិលសងវិញនោះត្រូវបានលាតត្រដាង ។ ប្រសិនបើអាចអនុវត្តបាន អង្គភាពក៏ត្រូវបានលាតត្រដាងបង្ហាញ ថាមានវិបាកពន្ធលើប្រាក់ចំណេញបន្ថែម ដែលមានសក្តានុពលមិនអាចកំណត់បានពេលអនុវត្តជាក់ស្តែង ។ នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុដាច់ដោយឡែករបស់

ក្រុមហ៊ុនមេ ប្រសិនបើមាន ការលាតត្រដាងនៃវិបាក ពន្ធលើប្រាក់ចំណូល ដែលមានសក្តានុពលមានការទាក់ទិននឹងប្រាក់ចំណេញរក្សាទុក របស់ក្រុមហ៊ុនមេ ។

៨៧គ អង្គភាពមួយដែលបានតម្រូវ ដើម្បីផ្តល់ការលាតត្រដាងនៅក្នុង កថាខណ្ឌ ៨២ក ក៏អាចត្រូវបានតម្រូវឲ្យមានការបង្ហាញ ដែលទាក់ទងចំពោះភាពខុស គ្នាបណ្តោះអាសន្នជាប់ជាមួយនឹងការវិនិយោគនៅក្នុងក្រុមហ៊ុនបុត្រសម្ព័ន្ធ សាខា និងក្រុមហ៊ុនញ្ញាតិសម្ព័ន្ធ ឬភាគកម្មនៅក្នុងក្រុមហ៊ុនរួមទុន។ នៅ ក្នុងករណីបែបនេះ អង្គភាពមួយពិចារណាពីករណីនេះនៅក្នុងការកំណត់ ព័ត៌មានដែលត្រូវលាតត្រដាងតាម កថាខណ្ឌ៨២ក ។ ឧទាហរណ៍ អង្គភាពមួយអាចត្រូវបានតម្រូវឲ្យ លាតត្រដាងពីទឹកប្រាក់សរុបនៃ ភាពខុសគ្នាបណ្តោះអាសន្នដែលជាប់ជាមួយការវិនិយោគនៅក្នុងក្រុមហ៊ុនបុត្រសម្ព័ន្ធ សម្រាប់ក្រុមហ៊ុនបុត្រសម្ព័ន្ធ ដែលពុំមានបំណុលពន្ធពន្យារ ត្រូវបានទទួលស្គាល់ (សូមបើកថាខណ្ឌ៨១(ង)) ។ ប្រសិនបើគេមិនអាចគណនាពីទឹកប្រាក់នៃបំណុល ពន្ធពន្យារដែលមិនបានទទួលស្គាល់ (សូមកថាខណ្ឌ ៨៧) នោះអាចនឹងមានទឹកប្រាក់នៃវិបាកពន្ធលើប្រាក់ចំណូលនៃភាគលាភដែលមានសក្តានុពលជាក់ស្តែងមិនអាចកំណត់បានដែលទាក់ទិននឹងក្រុមហ៊ុនសម្ព័ន្ធទាំងនេះ។

៨៨ អង្គភាពមួយលាតត្រដាងពីបំណុលយថាហេតុ និងទ្រព្យសកម្មយថាហេតុ ដែលពាក់ព័ន្ធព័ន្ធដោយអនុលោមតាម ស.គ.អ.ក ៣៧ *សំវិធានធន បំណុលយថាហេតុ និងទ្រព្យសកម្មយថាហេតុ* ។ ឧទាហរណ៍ បំណុលយថា

ហេតុ និងទ្រព្យសកម្មយថាហេតុអាចកើតពីជំលោះ ដែលមិនទាន់បាន ដោះស្រាយជាមួយនឹងអាជ្ញាធរពន្ធ។ ស្រដៀងគ្នានេះពេលដែលការផ្លាស់ ប្តូរអត្រាពន្ធ ឬច្បាប់ពន្ធដែលត្រូវបាអនុវម័ត ឬប្រកាសបន្ទាប់ពីគ្រារាយ-ការណ៍ អង្គភាពមួយលាតត្រដាងពីឥទ្ធិពលសំខាន់ៗ នៃការផ្លាស់ប្តូរទាំង នោះលើទ្រព្យសកម្ម និងបំណុលពន្ធពន្យារ និងពន្ធបច្ចុប្បន្ន (សូមមើល ស.គ.អ.ក ១០ *ព្រឹត្តិការណ៍បន្ទាប់ពីគ្រារាយការណ៍)*។

## កាលបរិច្ឆេទប្រសិទ្ធិភាព

៨៩ ស្តង់ដារនេះអនុវត្ត សម្រាប់របាយការណ៍ហិរញ្ញវត្ថុ ដែលគ្របដណ្តប់គ្រា ដែលចាប់ផ្តើមនៅថ្ងៃទី ឬបន្ទាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ១៩៩៨ លើកលែង ដូចមាន ចែងនៅក្នុងកថាខណ្ឌ ៩១ ។ ប្រសិនបើអង្គភាព អនុវត្តស្តង់ដារ នេះសម្រាប់ របាយការណ៍ហិរញ្ញវត្ថុ ដែលគ្របដណ្តប់គ្រាដែលចាប់ ផ្តើមមុន ថ្ងៃទី០១ ខែមករា ឆ្នាំ១៩៩៨ អង្គភាពត្រូវលាត ត្រដាងពីហេតុការណ៍ ដែលអង្គភាព បានអនុវត្តស្តង់ដារនេះជំនួស ស.គ.អ.ក ១២ *គណនេយ្យ សម្រាប់ពន្ធ លើប្រាក់ចំណូល* ដែលបានអនុម័តឆ្នាំ ១៩៧៩ ។

៩០ ស្តង់ដារនេះជំនួសឲ្យ ស.គ.អ.ក ១២ *គណនេយ្យសម្រាប់ពន្ធលើប្រាក់ ចំណូល* ដែលបានអនុម័តក្នុង ឆ្នាំ១៩៧៩ ។

៩១ កថាខណ្ឌ៥២ក ៥២ខ ៦៥ក ៨១(១) ៨២ក ៨៧ក ៨៧ក និងការលុប ចោលនៃ កថាខណ្ឌ៣ និង៥០ចូលជាធរមានសម្រាប់

របាយការណ៍ហិរញ្ញវត្ថុ ប្រចាំឆ្នាំ ដែលគ្របដណ្តប់គ្រាដែលចាំផ្តើម នៅថ្ងៃទី១ ឬបន្ទាប់ពី ថ្ងៃទី០១ ខែមករា ឆ្នាំ២០០១ ។ ការប្រើមុនត្រូវបានលើកទឹកចិត្ត។ ប្រសិនការប្រើ មុនប៉ះពាល់ដល់របាយការណ៍ហិរញ្ញវត្ថុ អង្គភាពត្រូវលាតត្រដាងពីហេតុ- ការណ៍នោះ ។

៩២ ស.គ.អ.ក ១ (ដូចមានកែប្រែក្នុងឆ្នាំ ២០០៧) មានកែប្រែវាក្យស័ព្ទដែលបានប្រើនៅក្នុង ស.រ.ហ.អ.ក។ លើសពីនេះទៅទៀត វាត្រូវបានគេកែប្រែកថាខណ្ឌ ២៣ ៥២ ៦០ ៦២ ៦៣ ៧៥ ៦៨គ ៧៧ និង៨១ បានលុបចោលកថាខណ្ឌ៦១ និងបន្ថែម កថាខណ្ឌ ៦១ក ៦២ក និង៧៧ក។ អង្គភាពមួយត្រូវអនុវត្តការកែប្រែ
ទាំងនោះសម្រាប់គ្រាទាំងឡាយដែលចាប់ ផ្តើម នៅថ្ងៃទី១ ឬបន្ទាប់ថ្ងៃទី១ ខែមករា ឆ្នាំ២០០៩។ ប្រសិនបើអង្គភាព ប្រើមុននូវ ស.គ.អ.ក ១ (បានកែប្រែឆ្នាំ២០០៧) សម្រាប់គ្រាមុន នោះការ កែប្រែត្រូវបានអនុវត្តសម្រាប់គ្រាមុននោះ ។

៩៣ កថាខណ្ឌ៦៨
ត្រូវបានអនុវត្តសម្រាប់ពេលទៅមុខចាប់ពីថ្ងៃចូលជាធរមាននៃ
ស.រ.ហ.អ.ក ៣ (ដូចបានកែប្រែក្នុងឆ្នាំ ២០០៨) ចំពោះការទទួលស្គាល់នៃទ្រព្យសកម្មពន្ធពន្យារដែលបានទិញនៅក្នុងការបញ្ចូលអាជីវកម្មរួមគ្នា ។

៩៤ ដូច្នេះ អង្គភាពមិនត្រូវកែសំរួលគណនេយ្យសម្រាប់ការបញ្ចូលអាជីវកម្មរួមគ្នានៅគ្រាមុននោះទេ ប្រសិនបើអត្ថប្រយោជន៍ពន្ធខកខានមិនបំពេញលក្ខខណៈវិនិច្ឆ័យសម្រាប់ការទទួលស្គាល់ដាច់ដោយឡែកត្រឹមថ្ងៃទិញ និងត្រូវបានទទួលស្គាល់បន្ទាប់ពីថ្ងៃទិញ ប្រសិនបើអត្ថប្រយោជន៍ ត្រូវបាន

ទទួលស្គាល់នៅក្នុងគ្រាវាស់វែង និងកើតចេញពីព័ត៌មានថ្មីអំពីហេតុការណ៍ និងកាលៈទេសៈដែលបានកើតឡើងនៅថ្ងៃទិញ។ អត្ថប្រយោជន៍ពន្ធផ្សេងទៀតដែលបានទទួលស្គាល់ត្រូវបានទទួលនៅក្នុងរបាយការណ៍ចំណេញឬខាត(ឬប្រសិនស្តង់ដារនេះបានតម្រូវត្រូវនៅខាងក្រៅរបាយការណ៍ចំណេញ ឬខាត)។

៩៥ ស.រ.ហ.អ.ក ៣ (ដូចបានកែប្រែក្នុងឆ្នាំ ២០០៨) បានធ្វើវិសោធនកម្មកថាខណ្ឌ ២១ និង ៦៧ និង បានបន្ថែមកថាខណ្ឌ ៣២ក និង៨១(ញ) និង(ដ)។ អង្គភាពមួយត្រូវប្រើការធ្វើវិសោធនកម្មទាំងនោះសម្រាប់គ្រាប្រចាំ ឆ្នាំដែលចាប់ផ្តើមនៅថ្ងៃទី០១ ឬ បន្ទាប់ពីថ្ងៃទី១ ខែកក្កដា ឆ្នាំ២០០៩។ ប្រសិនបើអង្គភាព មួយប្រើ ស.រ.ហ.អ.ក ៣ (បានកែប្រែនៅឆ្នាំ ២០០៨) សម្រាប់គ្រាមុន នោះការធ្វើវិសោធនកម្មទាំងនោះ ក៏ត្រូវបានប្រើសម្រាប់ គ្រាមុននោះដែរ ។

៩៦ [លុបចោល]

៩៧ ស.រ.ហ.អ.ក ៩ បានបោះផ្សាយក្នុង ខែតុលា ឆ្នាំ២០១០ បានកែប្រែកថាខណ្ឌ ២០ និងលុបចោលកថាខណ្ឌ ៩៦។ អង្គភាពត្រូវប្រើការធ្វើវិសោធនកម្មទាំងនោះនៅពេលដែលអង្គភាពអនុវត្ត ស.រ.ហ.អ.ក ៩ ដូចបានបោះផ្សាយនៅក្នុងខែតុលា ឆ្នាំ ២០១០ ។

៩៨ កថាខណ្ឌ៥២ ត្រូវបានដាក់លេខឡើងវិញ ជាលេខ ៥១ក កថាខណ្ឌ១០ និងឧទាហរណ៍បន្ទាប់ពីកថាខណ្ឌ ៥១ក ត្រូវបានធ្វើវិសោធនកម្ម ហើយកថាខណ្ឌ ៥១ខ និង ៥១គ និងឧទាហរណ៍ខាងក្រោម និងកថាខណ្ឌ ៥១ឃ ៥១ង និង ៩៩ ត្រូវបានបន្ថែមដោយ*ពន្ធពន្យា: ការទទួលបាន*

*មកវិញនៃទ្រព្យសកម្មកំពុងប្រើ* បានបោះផ្សាយឲ្យប្រើនៅក្នុង ខែធ្នូ ឆ្នាំ ២០១០។ អង្គភាពមួយត្រូវអនុវត្តការធ្វើវិសោធនកម្មទាំងនោះសម្រាប់គ្រាប្រចាំឆ្នាំដែលចាប់ផ្ដើមនៅថ្ងៃទី១ ឬ បន្ទាប់ទី១ ខែ មករា ឆ្នាំ ២០១២។ ការអនុវត្តមុនត្រូវបានអនុញ្ញាតិ។ ប្រសិនបើអង្គភាពមួយប្រើវិសោធនកម្មសម្រាប់គ្រាមុនអង្គផាពត្រូវលាតត្រដាងពីហេតុការណ៍នោះ ។

**ការដកចេញនៃ គ.ប.ស. ២១**

---

៩៩ ការធ្វើវិសោធនកម្មដែលបានធ្វើឡើងដោយ *ពន្ធពន្យា: ការទទួលបានមកវិញនៃទ្រព្យសកម្មកំពុងប្រើ* បានបោះផ្សាយនៅក្នុងខែធ្នូ ឆ្នាំ២០១០ ជំនួសឲ្យ គ.ប.ស. លេខ២១ *ពន្ធលើប្រាក់ចំណូលការទទួលបានមកវិញនៃទ្រព្យសកម្មវាយតម្លៃរួច មិនអាចដករំលស់បាន ។*

ក្រុមប្រឹក្សាជាតិគណនេយ្យ
ក.ជ.គ គឺជាស្ថាប័នបញ្ញត្តិករនៃវិស័យគណនេយ្យ និងសវនកម្មនៅកម្ពុជា
អាស័យដ្ឋាន: ផ្លូវ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
អ៊ីម៉ែល: info@naccambodia.gov.kh | គេហទំព័រ: www.naccambodia.gov.kh

ក.ជ.គ រក្សាសិទ្ធិក្នុងការកែប្រែស្តង់ដាទៅតាមការវិវត្តក្នុងក្របខណ្ឌអន្តរជាតិ